Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

# បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា




## ការធ្វើឱ្យប្រសើរឡើងនូវភាពរឹងមាំផ្នែកម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រធានបទពិសេស

**ការវិវឌ្ឍន៍ថ្មីនៃវិស័យហិរញ្ញវត្ថុៈ ឱកាសនិងហានិភ័យ**

WORLD BANK GROUP

ខែ មេសា ឆ្នាំ ២០១៦

# ការធ្វើឱ្យប្រសើរឡើងនូវភាពរឹងមាំផ្នែកម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

## ខែ មេសា ឆ្នាំ ២០១៦

WORLD BANK GROUP

@ រក្សាសិទ្ធិគ្រប់យ៉ាង

បច្ចុប្បន្នភាពសេដ្ឋកិច្ចប្រទេសកម្ពុជាគឺជាផលិតផលរបស់ធនាគារពិភពលោក។

របកគំហើញ បំណាកស្រាយ និងសេចក្តីសន្និដ្ឋានដែលមានបញ្ជាក់នៅក្នុងរបាយការណ៍បច្ចុប្បន្នភាពនេះគឺជារបកគំហើញ បំណកស្រាយ និងសេចក្តីសន្និដ្ឋានរបស់បុគ្គលិកធនាគារពិភពលោក និងមិនឆ្លុះបញ្ចាំងទស្សនៈអ្នកគ្រប់គ្រង ក្រុមប្រឹក្សាប្រតិបត្តិធនាគារ ឬរដ្ឋាភិបាលដែលពួកគេតំណាងឡើយ។

ធនាគារពិភពលោកមិនធានាភាពត្រឹមត្រូវនៃទិន្នន័យដែលបានដាក់បញ្ចូលនៅក្នុងកិច្ចការនេះឡើយ។

## អារម្ភកថា និងសេចក្តីថ្លែងអំណរគុណ

របាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា (CEU) គឺជាផលិតផលរបស់បុគ្គលិករបស់ធនាគារពិភពលោកនេះ។ របាយការណ៍នេះត្រូវបានរៀបចំដោយលោក លី សូដេត និងដាក់បញ្ចូលនូវការរួមចំណែករបស់លោក មីហ្គែល អេឌូអាដូ សាន់ឆេស ម៉ាទីន (Miguel Eduardo Sánchez Martín) ផ្នែកម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តសាកលនៃការគ្រប់គ្រងសារពើពន្ធ (MFM GP) ។ កញ្ញា លីនណា គឺជាជំនួយការស្រាវជ្រាវ។ ក្រុមនេះធ្វើការក្រោមការដឹកនាំរបស់លោក ម៉ាធូ អា វើហ្គីស (Mathew A. Verghis) ប្រធានគ្រប់គ្រងការអនុវត្តន៍, MFM GP។ រ៉ាតឆាដា អាណាន តាវ៉ាស៊ីលប៉ា (Ratchada Anantavrasilpa) និង ខុលលីន ម៉ាសឺនិក (Colleen Mascenik) មកពីផ្នែកអនុវត្តសាកលនៃហិរញ្ញវត្ថុ និងទីផ្សារ (FAM) GP បានរួមវិភាគទានប្រធានបទពិសេសអំពីការវិវឌ្ឍន៍ថ្មីៗនៃវិស័យហិរញ្ញវត្ថុ ឱកាស និងហានិភ័យដែលត្រូវបានពិនិត្យដោយលោក ជេមស៍ ស៊ីវ៉ាដ (James Seward) ប្រធានគ្រប់គ្រងការអនុវត្តន៍ FAM GP។ ក្រុមការងារសូមថ្លែងអំណរគុណចំពោះមតិយោបល់ដំបូន្មាន និងការណែនាំដែលផ្តល់ដោយលោក អ៊ុលរិច ហ្សាកៅ (Ulrich Zachau) នាយកប្រចាំកម្ពុជា និង ស្ហាប៊ី អាលី ម៉ូហ៊ីប (Shabih Ali Mohib) ប្រធានកម្មវិធី។

របាយការណ៍នេះត្រូវបានផលិតរៀងរាល់ឆមាស ដើម្បីផ្តល់ព័ត៌មានថ្មីៗអំពីការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ របាយការណ៍នេះត្រូវបានបោះពុម្ព និងចែកចាយទូលំទូលាយទៅឲ្យអាជ្ញាធរកម្ពុជា សហគមន៍ដៃគូអភិវឌ្ឍន៍វិស័យឯកជន ក្រុមស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងស្ថាប័នសិក្សាស្រាវជ្រាវ។ បច្ចុប្បន្នភាពនេះត្រូវបានកំណត់ពេលឲ្យត្រូវគ្នាជាមួយការបោះពុម្ពផ្សាយរៀងរាល់ប្រាំមួយខែម្តងនូវបច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីខាងកើត និងតំបន់ប៉ាស៊ីហ្វិក ដោយ MFM GP នៃធនាគារពិភពលោក។

យើងទទួលបានធាតុចូល មតិយោបល់ និងសំណើមានតម្លៃពីលោក អាម៉ាដ អាសាន (Ahmad Ahsan) ការិយាល័យប្រធានផ្នែកសេដ្ឋកិច្ចអាស៊ីខាងកើត និងតំបន់ប៉ាស៊ីហ្វិក ប្រធានអង្គភាពវិភាគសេដ្ឋកិច្ច លោក ស៊ើកហ្គី ហ្សូរីយ៉ា (Sergiy Zorya) GP កសិកម្ម លោកស្រី ឃែរ៉ូឡៃណា មេជា ម៉ានទីឡា (Carolina Mejia-Mantilla) GP ភាពក្រីក្រ និង លោក ចូសេ ឌើ លូណា ម៉ាទីណេស (Jose De Luna Martinez) GP ហិរញ្ញវត្ថុ និងទីផ្សារ។ របាយការណ៍នេះក៏បានទទួលដំបូន្មាន មតិយោបល់ និងទស្សនៈរបស់ភាគីពាក់ព័ន្ធនានាក្នុងរាជរដ្ឋាភិបាលកម្ពុជា វិស័យឯកជន ស្ថាប័នដៃគូអភិវឌ្ឍន៍ និងស្ថាប័នសិក្សាស្រាវជ្រាវ។ ក្រុមរៀបរៀងរបាយការណ៍នេះ សូមថ្លែងអំណរគុណជាពន្លឹកចំពោះពេលវេលា និងធាតុចូលរបស់ពួកគេ។

យើងខ្ញុំសូមថ្លែងនូវសេចក្តីដឹងគុណដ៏ជ្រាលជ្រៅចំពោះអាជ្ញាធរកម្ពុជា ពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជាចំពោះកិច្ចសហប្រតិបត្តិការ និងការគាំទ្រក្នុងការរៀបចំរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះ។

ក្រុមទំនាក់ទំនងនៃការិយាល័យធនាគារពិភពលោកនៅកម្ពុជា រួមមាន លោក ប៊ូ សារឿន និងសំអឿន សុភីនិតបានរៀបចំការផ្តល់ព័ត៌មានដល់ប្រព័ន្ធផ្សព្វផ្សាយ ការបង្ហាញលើបណ្តាញអិនធើនែត និងការផ្សព្វផ្សាយ។

ចំពោះព័ត៌មានអំពីធនាគារពិភពលោក និងសកម្មភាពរបស់ធនាគារនេះនៅកម្ពុជា សូមចូលមើលគេហទំព័ររបស់យើងតាមអាស័យដ្ឋាន www.worldbank.org/cambodia។

ដើម្បីឲ្យមានឈ្មោះនៅក្នុងបញ្ជីចែកចាយរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះ និងឯកសារបោះពុម្ពផ្សាយពាក់ព័ន្ធ សូមទាក់ទង កញ្ញា គី លីនណា (lky@worldbank.org) ។ ចំពោះសំណួរលើខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ សូមទាក់ទង លោក ប៊ូ សារឿន (sbou@worldbank.org) ។

## តារាងមាតិកា


ក. ខ្លឹមសារសង្ខេប.......... 1
ខ. ការអភិវឌ្ឍសេដ្ឋកិច្ចកាលពីពេលថ្មីៗ.......... 6
ទិដ្ឋភាពទូទៅ.......... 6
វិស័យពិតផលិត.......... 7
ក). សម្លៀកបំពាក់.......... 7
ខ). វិស័យស្បែកជើង និង ទំនិញកសិកម្ម.......... 9
គ). សំណង់និងអចលនទ្រព្យ.......... 10
ឃ). ទេសចរណ៍.......... 11
ង). កសិកម្ម.......... 12
ការងារ ប្រាក់ចំណូល និងការប្រើប្រាស់.......... 14
ភាពក្រីក្រ.......... 16
វិស័យក្រៅប្រទេស.......... 16
ក). ការនាំចេញ.......... 17
ខ).ការនាំចូល.......... 17
អតិផរណា.......... 17
វិស័យរូបិយវត្ថុ.......... 18
ក). រូបិយវត្ថុសរុប អត្រាការប្រាក់និងអត្រាប្តូរប្រាក់.......... 18
ខ). វិស័យធនាគារ.......... 19
វិស័យសារពើពន្ធ.......... 21
ក). សមាសភាពចំណូល.......... 21
ខ). សមាសភាពចំណាយ.......... 22
គ). សមតុល្យសារពើពន្ធ.......... 23
ឃ). ថវិកាប្រចាំឆ្នាំសម្រាប់ឆ្នាំ 2016.......... 23
គ. ទស្សនៈវិស័យនិងហានិភ័យ.......... 26
ឃ. សារគន្លឹះ និងជម្រើសគោលនយោបាយ.......... 28
ង. ប្រធានបទពិសេស- ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ: ឱកាស និងហានិភ័យ.......... 31
ក). ទិដ្ឋភាពទូទៅ និងនិន្នាការនៃវិស័យហិរញ្ញវត្ថុ.......... 31
ខ). វិស័យធនាគារ.......... 32
គ). វិស័យមីក្រូហិរញ្ញវត្ថុ.......... 34
ឃ). វិស័យធានារ៉ាប់រង.......... 36
ង). ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ការប្រឆាំងការលាងលុយកខ្វក់ និងការរាយការណ៍ 37
ច). សារគន្លឹះ.......... 38
កម្ពុជា: សូចនាករសំខាន់ៗ.......... 41

## ក. ខ្លឹមសារសង្ខេប

*ខណៈពេលដែលនៅតែមានភាពរឹងមាំ កំណើនក្នុងឆ្នាំ 2015 បានធ្លាក់ចុះបន្តិចមកត្រឹម 7.0 ភាគរយ ទាបជាងកំណើន 7.1 ភាគរយដែលសម្រេចបាននៅឆ្នាំ 2014។ លទ្ធផលអនុវត្តនៃវិស័យកាត់ដេរ មានភាពប្រសើរឡើងក្នុងឆ្នាំ 2015 ខណៈដែលសេដ្ឋកិច្ចមានសញ្ញាថមថយ និងបន្តមានភាពទន់ខ្សោយក្នុងវិស័យទេសចរណ៍ និងវិស័យកសិកម្ម។ កំណើនពិតប្រាកដរបស់ប្រទេសកម្ពុជា ត្រូវបានព្យាករណ៍ថានឹងនៅតែមានសុខភាពល្អក្នុងកម្រិត 6.9 ភាគរយនៅឆ្នាំ 2016 មួយចំណែកដោយសារមានការបង្កើនឡើងយ៉ាងច្រើន នូវចំណាយរបស់រដ្ឋាភិបាល។ ការនាំចេញសម្លៀកបំពាក់យ៉ាងច្រើន អាចជួយប៉ះប៉ូវការធ្លាក់ចុះក្នុងវិស័យកសិកម្ម ខណៈពេលដែលវិស័យសំណង់ត្រូវបានគេរំពឹងថា នឹងនៅតែបន្តជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច។ ហានិភ័យចំពោះទស្សនវិស័យនេះ រួមមាន សក្តានុពលនៃបញ្ហាការងារដែលកើតមានជាថ្មី ការបន្តឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក ការងើបឡើងវិញយឺតនៃសេដ្ឋកិច្ចនៅអឺរ៉ុប និងផលប៉ះពាល់ពីការធ្លាក់ចុះសេដ្ឋកិច្ចរបស់ចិន។ និន្នាការធ្លាក់ចុះនៃភាពក្រីក្រត្រូវបានរំពឹងថា នឹងបន្តធ្លាក់ចុះទៅទៀត ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ទោះបីជាមានល្បឿនយឺតជាងមុន ក្នុងបរិបទនៃការថមថយកំណើនសេដ្ឋកិច្ចកសិកម្មក្តី។*

### *ការអភិវឌ្ឍន៍ថ្មីៗ*

**កំណើនដឹកមុខដោយការនាំចេញ របស់ប្រទេសកម្ពុជាបានកើនសន្ទុះបន្ទាប់ពីត្រីមាសទីពីរនៃឆ្នាំមុន ហើយកំណើនពិត ត្រូវបានប៉ាន់ប្រមាណថាបានកើនដល់ 7.0 ភាគរយក្នុងឆ្នាំ 2015។**

បន្ទាប់ពីការថមថយនៅដើមឆ្នាំ 2015 ការនាំចេញសម្លៀកបំពាក់ ដែលជាកត្តាចម្បងមួយក្នុងការជំរុញកំណើនសេដ្ឋកិច្ច បានស្ទុះងើបឡើងវិញនៅក្នុងឆមាសទីពីរក្នុងដដែល ដោយមានអត្រាកំណើនជាក់ស្តែងពីមួយឆ្នាំទៅមួយឆ្នាំស្មើនឹង 12.3 ភាគរយ ធៀបនឹង 9.2 ភាគរយ ក្នុងឆ្នាំ 2014។ ការមានស្ថេរភាពល្អនៃទីផ្សារការងារគួបផ្សំជាមួយនឹងការឈានឡើងបន្តិចម្តងៗ លើខ្សែសង្វាក់តម្លៃ ទំនងជាបានជួយវិស័យនេះឲ្យបន្តរីកចម្រើនកាន់តែធំ ដែលអូសទាញដោយនិរន្តរភាព នៃវិនិយោគផ្ទាល់ពីបរទេស ចូលទៅក្នុងវិស័យកាត់ដេរ ទោះបីការអនុម័តបានធ្លាក់ចុះក្តី។ ចំនួនភ្ញៀវទេសចរសរុបនៅឆ្នាំ 2015 បានកើនឡើង 6.1 ភាគរយ (ភ្ញៀវទេសចរមានចំនួន 4,78 លាននាក់) ធៀបនឹង 6.9 ភាគរយក្នុងឆ្នាំ 2014 បើទោះជាមានការងើបឡើងវិញនូវសកម្មភាពនៃវិស័យទេសចរណ៍នៅក្នុងប្រទេសថៃ និងនៅបណ្តាប្រទេសជិតខាងក្តី។ ផលិតកម្មស្រូវនៅឆ្នាំ 2015 ត្រូវបានប៉ាន់ស្មានដោយអាជ្ញាធរ ថាមានចំនួនទាបជាងឆ្នាំ 2014 បណ្តាលមកពីគ្រោះរាំងស្ងួត ការធ្លាក់ចុះនូវការបង្កើនទិន្នផល និងដោយសារការធ្លាក់ថ្លៃទំនិញកសិកម្ម ដែលធ្វើឲ្យប៉ះពាល់ផងដែរដល់កំណើនវិស័យកសិកម្ម។

**ការកើនឡើងនូវការនាំចេញ និងការធ្លាក់ចុះថ្លៃប្រេងបានធ្វើឲ្យស្ថានភាពពាណិជ្ជកម្មក្រៅប្រទេស (External Position) មានភាពប្រសើរឡើង។** ឱនភាពគណនីចរន្តបានចុះថយដល់ 10.8 ភាគរយ នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ 2015 ធៀបនឹង 11.9 ភាគរយនៅឆ្នាំ 2014។ ឱនភាពនេះ ត្រូវបានផ្តល់ហិរញ្ញប្បទានដោយលំហូរចូលយ៉ាងច្រើននូវវិនិយោគផ្ទាល់ពីបរទេស ដែលត្រូវបានប៉ាន់ស្មានថាមានរហូតដល់ 1.8 ពាន់លានដុល្លា (ឬ10ភាគរយនៃ ផសស)ក្នុងឆ្នាំ 2015។លទ្ធផលអនុវត្តន៍ពីក្រៅស្រុករឹងមាំនេះ ធ្វើឲ្យទុនបម្រុងអន្តរជាតិដុលការកើនឡើងយ៉ាងឆាប់រហ័ស គឺកើនឡើងដល់

5.6ពាន់លានដុល្លា (ឬស្មើនឹងការនាំចូលចំនួន4.4 ខែ) នៅចុងឆ្នាំ 2015 ធៀបនឹង 4.6ពាន់លានដុល្លាក្នុងឆ្នាំ2014 ។

**ការបន្តពង្រីកខ្លួនយ៉ាងឆាប់រហ័ស នៃវិស័យហិរញ្ញវត្ថុបាននាំមកនូវកំណើនសេដ្ឋកិច្ច និងកំណើនអតិផរណានៅចុងឆ្នាំ 2015។** កំណើនឥណទានក្នុងស្រុកបានកើនឡើងបន្ថែមដល់ 27 ភាគរយ នៅឆ្នាំ 2015 ធៀបនឹងឆ្នាំមុន ជម្រុញដោយកំណើនតម្រូវការក្នុងស្រុកសម្រាប់ការប្រើប្រាស់ និងសំណង់។ ទន្ទឹមនឹងនេះ ក្នុងឆ្នាំ 2015 កំណើនប្រាក់បញ្ញើវិស័យឯកជន បានធ្លាក់ចុះចំនួនពាក់កណ្តាល មកត្រឹម 16.6 ភាគរយ ធៀបនឹងឆ្នាំមុន។ ជាលទ្ធផល អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើបានកើនឡើងដល់ 95.6 ភាគរយ។ ក្នុងខែកុម្ភៈឆ្នាំ 2016 ការកើនឡើងនូវតម្រូវការក្នុងស្រុក ក៏បានធ្វើឲ្យអតិផរណាកើនឡើងដល់ 2.3 ភាគរយផងដែរ ធៀបនឹងឆ្នាំមុន។ ប្រាក់រៀលកម្ពុជាបានឡើងថ្លៃបន្តិច គឺឡើងដល់ 4,008រៀលក្នុងមួយដុល្លារសហរដ្ឋអាមេរិក ក្នុងខែកុម្ភៈឆ្នាំ2016 ធៀបនឹង 4,075 រៀលក្នុងមួយដុល្លារ ក្នុងខែធ្នូ ឆ្នាំ2014។ ប្រាក់រៀលនៅតែបន្តឡើងថ្លៃធៀបនឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាមផងដែរ ខណៈដែលអត្រាប្តូរប្រាក់ខ្វែងពិត (REER) កាន់តែមានតម្លៃបន្ថែមទៀត។

**លទ្ធផលអនុវត្តន៍ផ្នែកសារពើពន្ធមានភាពប្រសើរឡើងដោយសារកំណើនប្រាក់ចំណូលយ៉ាងច្រើន និងការបន្ថយចំណាយដែលបន្តកាត់បន្ថយឱនភាពសារពើពន្ធរួម។** ចំណូលពន្ធបានកើនឡើងប្រមាណ 10 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2010 ដល់ 15.1 ភាគរយ ក្នុងឆ្នាំ 2015 ដោយសារការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង និងកំណើនសេដ្ឋកិច្ចរឹងមាំ។ ការប្រមូលចំណូលក្នុងស្រុកសរុបបានកើនឡើងប្រមាណជា 17.5 ភាគរយ នៃផសស ក្នុងឆ្នាំ 2015 ខណៈដែលការចំណាយត្រូវបានគេរំពឹងថានឹងមានត្រឹមតែ 20.5 ភាគរយនៃ ផសស ទោះជាមានកំណើនសម្ពាធប្រាក់ខែក្តី។ ឱនភាពរួមរបស់រដ្ឋាភិបាលរួមមាន ជំនួយឥតសំណងបានរួមតូចត្រឹម 0.8 ភាគរយ នៃ ផសស នៅឆ្នាំ 2015 ធៀបនឹង 1.4 ភាគរយ ក្នុងឆ្នាំ 2014 ទោះជាសមាសភាគជំនួយឥតសំណងថយចុះក្តី។ ចំណាត់ថ្នាក់សម្ពាធបំណុលរបស់ប្រទេសកម្ពុជានៅក្នុងរបាយការណ៍ចុងក្រោយរបស់ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិអំពីការវិភាគនិរន្តរភាពបំណុលនៅតែមានកម្រិតទាប។

### *ទស្សនៈវិស័យ*

**កំណើនត្រូវបានរំពឹងថានឹងស្មើ 6.9 ភាគរយ នៅឆ្នាំ 2016 មួយផ្នែកគឺ ដោយសារការបង្កើនចំណាយយ៉ាងច្រើនរបស់រាជរដ្ឋាភិបាល។** ការនាំចេញនៃវិស័យកាត់ដេរយ៉ាងខ្លាំងត្រូវបានរំពឹងថា នឹងជួយកាត់កងចំណុចខ្សោយនៅក្នុងវិស័យកសិកម្ម ខណៈពេលដែលការសាងសង់ដែលដឹកមុខដោយការវិនិយោគដោយផ្ទាល់ពីបរទេសត្រូវបានរំពឹងថា នឹងនៅតែជាក្បាលម៉ាស៊ីនចម្បងនៃកំណើនសេដ្ឋកិច្ច។ កំណើននាំចេញរឹងមាំក៏នឹងគាំទ្រ ក្នុងការធ្វើឲ្យឱនភាពគណនីចរន្តមានទំហំកាន់តែតូចផងដែរ។ ប្រកាសរបស់ធនាគារជាតិ ដែលបានចេញក្នុងខែមីនាឆ្នាំ 2016 តម្រូវឲ្យធនាគារបង្កើនដើមទុនទ្វេដង។ ប្រកាសនេះត្រូវបានរំពឹងថានឹងជួយពង្រឹងធនាគារនានា ឲ្យអាចទប់ទល់បានចំពោះការពង្រីកខ្លួនយ៉ាងឆាប់រហ័សនៃវិស័យធនាគារ។ ថវិកាឆ្នាំ 2016 ឆ្លុះបញ្ចាំងគោលនយោបាយសារពើពន្ធ ទូលំទូលាយ ដោយបង្កើនចំណាយចំនួន 3.6 ភាគរយ នៃ ផសស ក្នុងនោះ តម្លើងប្រាក់ឈ្នួល 1.4 ភាគរយ ហើយចំណែកផ្សេងទៀតគឺចំណាយមូលធន និងចំណាយមិនមែនប្រាក់ឈ្នួល។

**ការកាត់បន្ថយភាពក្រីក្របន្ថែមទៀតត្រូវបានរំពឹងថានឹងប្រព្រឹត្តទៅសម្រាប់គ្រួសារទាំងនៅទីប្រជុំជន និងនៅជនបទ ទូទាំងឆ្នាំ 2015-2016 ។** សម្រាប់គ្រួសារនៅតាមទីប្រជុំជន គឺតាមរយៈវិស័យសេដ្ឋកិច្ចដែលពួកគេចូលរួម (ភាគច្រើនគឺ វិស័យសំណង់ និងសេវាកម្ម) ។ សម្រាប់គ្រួសារនៅជនបទ គឺមានការកើនឡើងនូវប្រភពនៃប្រាក់ចំណូលខុសៗគ្នា លើប្រាក់ចំណូលពីការធ្វើការងារដោយខ្លួនឯងក្រៅពីការងារកសិកម្ម។

**ក្នុងរយៈពេលមធ្យម កំណើនត្រូវបានរំពឹងថានឹងនៅតែស្មើពី 6 ទៅ 7 ភាគរយ នៅក្នុងបរិបទនៃការកើនឡើង នៃការប្រកួតប្រជែងក្រៅស្រុក។** ដោយសារមូលដ្ឋានផលិត និងនាំចេញមានទំហំតូច ហើយការនាំចេញសម្លៀកបំពាក់ (ប្រហែល 70 ភាគរយនៃចំនួនសរុប) ប្រមូលផ្តុំនៅទីផ្សារសហភាពអឺរ៉ុប និង ទីផ្សារសហរដ្ឋអាមេរិក សេដ្ឋកិច្ចកម្ពុជាត្រូវប្រឈមមុខជាខ្លាំង ទៅនឹងការនាំចេញ ដែលមានភាពប្រកួតប្រជែងកាន់តែខ្លាំងឡើង។ ជាមួយនឹងភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) រវាងវៀតណាម និង សហភាពអឺរ៉ុប ការវិនិយោគ និងការនាំចេញពីកម្ពុជាមានហានិភ័យជាខ្លាំង លុះណាតែឧបសគ្គចម្បងៗ ដូចជាការចំណាយខ្ពស់លើថាមពល ឧបសគ្គផ្លូវច្បាប់ក្នុងការធ្វើអាជីវកម្ម និងឧបសគ្គហេដ្ឋារចនាសម្ព័ន្ធត្រូវបានដោះស្រាយដោយជោគជ័យ[1]។ ប្រការនេះអាចរាំងស្ទះបន្តិចម្តងៗចំពោះកំណើន វៀរលែងតែកំណែទម្រង់ ដែលមានលក្ខណៈរចនាសម្ព័ន្ធត្រូវបានពិភាក្សានៅក្នុងផ្នែកសារសំខាន់ៗខាងក្រោម ត្រូវបានយកចិត្តទុកដាក់ដោះស្រាយ។

**វិស័យហិរញ្ញវត្ថុរីកចម្រើនយ៉ាងឆាប់រហ័ស បានទ្រទ្រង់ដល់កំណើន ប៉ុន្តែក៏បង្កឱ្យមានបញ្ហាប្រឈមមួយចំនួនផងដែរ។** កំណើនឥណទាន 38 ភាគរយ ដល់វិស័យសំណង់បានបន្តកើនឡើង យ៉ាងឆាប់រហ័សនៅក្នុងឆ្នាំ 2015។ ខណៈពេលដែលកំពុងត្រូវបានការពារ ពីការប្រែប្រួលហិរញ្ញវត្ថុនៅបរទេស សេដ្ឋកិច្ចកម្ពុជានៅតែពឹងផ្អែកលើលំហូរប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស នៅតាមគ្រឹះស្ថានធនាគារ។ ខណៈមានលទ្ធភាពតិចតួចសម្រាប់គោលនយោបាយរូបិយវត្ថុ និងខណៈគ្មានលទ្ធភាពដើម្បីឲ្យធនាគារជាតិ ធ្វើជាអ្នកផ្តល់ប្រាក់កម្ចីជាជម្រើសចុងក្រោយ ដោយសារតែដុល្លារូបនីយកម្មកម្រិតខ្ពស់ ទន្ទឹមគ្នានឹងអវត្តមាននៃទីផ្សារអន្តរធនាគារ ការបន្តកើនឡើងខ្ពស់នៃឥណទានក្នុងស្រុក ធ្វើឲ្យហានិភ័យកើនឡើង ចំពោះស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា។

**ហានិភ័យផ្សេងទៀតចំពោះទស្សនវិស័យនេះ:** រួមមានសក្តានុពលនៃបញ្ហាពលកម្ម ការបន្តឡើងថ្លៃប្រាក់ដុល្លារអាមេរិកនៅក្នុងបរិបទនៃដុល្លារូបនីយកម្ម ការងើបឡើងវិញយឺតនៃសេដ្ឋកិច្ចនៅអឺរ៉ុប ឥទ្ធិពលពីការចុះថយនៃសេដ្ឋកិច្ចចិន។ ភាពតានតឹងនៃសេដ្ឋកិច្ចចិននឹងប៉ះពាល់ដល់ចក្ខុវិស័យកំណើន សំខាន់គឺដោយសារតែការមកដល់នៃភ្ញៀវទេសចរចិន អាចមានចំនួនកាន់តែតិចក្នុងរយៈពេលខ្លី និងលំហូរចូលយឺតនៃវិនិយោគផ្ទាល់ពីបរទេសក្នុងរយៈពេលមធ្យម។ ខណៈពេលដែលកម្ពុជាទំនងជាត្រូវបានការពារពីការប្រែប្រួលហិរញ្ញវត្ថុ ដោយសារទីផ្សារមូលធនរបស់កម្ពុជា មានកម្រិតប៉ុន្តែលំហូរចូលធនាគារ ដែលនៅតែជាចំណុចរសើបចំពោះទំនុកចិត្តសាធារណៈ និងចំពោះទស្សនៈអំពីទីផ្សារ។

## *សារគន្លឹះ និងជម្រើសគោលនយោបាយ*

**ការប្រមូលផ្តុំនៅក្នុងទីផ្សារនាំចេញ របស់សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ក្នុងសភាពនៃការបាត់បង់បន្តិចម្តងៗនូវភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម តម្រូវឱ្យធ្វើកំណែទម្រង់រចនាសម្ព័ន្ធសំដៅជំរុញ ភាពប្រកួតប្រជែង។** ដូចបានរៀបរាប់ខាងលើ សេដ្ឋកិច្ចកម្ពុជាកំពុងប្រឈមមុខនឹងការប្រកួតប្រជែងកាន់តែខ្លាំង ក្នុងខណៈដែលអាចមានផលប៉ះពាល់អវិជ្ជមានមកលើកម្ពុជា ពីសំណាក់កិច្ចព្រមព្រៀង TPP និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងវៀតណាម និងសហភាពអឺរ៉ុបក្នុងមធ្យមទៅរយៈពេលវែងព្រមទាំងការងើប ឡើងនៃប្រទេសមីយ៉ាន់ម៉ា។ ជម្រើសគោលនយោ បាយមួយចំនួនដែលមានគោលដៅពឹងផ្អែកលើភាពប្រកួតប្រជែង ក្រៅប្រទេសរួមមានភាពការកែលម្អ បរិយាកាសធុរកិច្ចរួមការវិនិយោគ

[1] សូមអានរបាយការណ៍ពីស្ថានស្តីពី Cambodia Investment Climate Assessment (2014)នៅលើគេហទំព័រ http://documents.worldbank.org/curated/en/2014/01/23946799/cambodia-investment-climate-assessment-2014-creating-opportunities-firms-cambodia

លើមូលធនមនុស្ស និងការដោះស្រាយគម្លាតផ្នែកហេដ្ឋារចនាសម្ព័ន្ធ។

**ការកែលម្អបរិយាកាសធុរកិច្ចជារួមនឹងបង្កើនភាពប្រកួតប្រជែងតាមវិស័យនានា ដែលទ្រទ្រង់ពិពិធកម្មផលិតផល និងទីផ្សារ** ហើយក៏ជួយដល់ក្រុមហ៊ុននានាឲ្យត្រៀមខ្លួនបានល្អ ដើម្បីទាញយកប្រយោជន៍ពីគោលដៅទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយដែលបានកំណត់ដោយសហគមន៍សេដ្ឋកិច្ចអាស៊ាន។ កម្លាំងពលកម្មដែលត្រូវបានបណ្តុះបណ្តាល និងមានជំនាញប្រសើរជាងមុន នឹងមុខជាជួយទាញយកប្រយោជន៍ពីភាគលាភប្រជាសាស្ត្រ (demographic dividend) របស់ប្រទេសកម្ពុជា។ ការដោះស្រាយឧបសគ្គសំខាន់ៗពោលគឺ ចំណាយខ្ពស់លើថ្លៃថាមពល និងឧបសគ្គផ្នែកហេដ្ឋារចនាសម្ព័ន្ធ តម្រូវឲ្យបង្កើនវិនិយោគសាធារណៈដើម្បីធានាដល់ភាពប្រកួតប្រជែងក្រៅប្រទេស។

**ដើម្បីឲ្យនៅតែមានភាពប្រកួតប្រជែង អាជ្ញាធរក៏អាចពិចារណាអំពីការបង្កើនវិភាជន៍ថវិកាបន្ត ដល់គម្រោងវិនិយោគដែលមានផលិតភាព និងដែលមានភាពប្រកួតប្រជែង។** ក្នុងរយៈពេលមធ្យម ប្រាក់កម្ចីសម្បទានអាចមកកាន់តែច្រើនពីប្រភពក្នុងតំបន់ ដូចជាធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ដែលទើបបង្កើតថ្មី ព្រមទាំងពីប្រភពទ្វេភាគី ដូចជាប្រទេសជប៉ុន និងប្រទេសចិនជាដើម។ ការធ្លាក់ចុះជាលំដាប់នូវវិនិយោគសាធារណៈដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ក៏មុខជាតម្រូវ ឱ្យមានការឆ្លើយតបរយៈពេលខ្លីដែលវិភាជន៍ថវិកាបន្ថែមទៀតបានមកពីថវិការដ្ឋ។ ការផ្តល់អាទិភាពនៃការចំណាយដោយប្រុងប្រយ័ត្ន និងការបន្តប្រមូលប្រាក់ចំណូលអោយបានច្រើន នឹងជួយធ្វើឱ្យដំណើរការនៃការបង្កើនវិនិយោគសាធារណៈនេះ អាចប្រព្រឹត្តទៅបានប្រសិនបើ អាចទប់ការកើននៃបញ្ជីប្រាក់ខែ។ ទន្ទឹមនឹងនេះដែរ ចាំបាច់ត្រូវពង្រឹងបន្ថែមទៀតនូវច្បាប់ និងបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងគម្រោងវិនិយោគមូលធន ដូចការប្រមើលមើលដោយការវាយតម្លៃការគ្រប់គ្រងវិនិយោគសាធារណៈ ដែលកំពុងស្ថិតនៅក្នុងការពិភាក្សានៅឡើយ។

**ជាចុងក្រោយ យកល្អគប្បីបន្តលើកកម្ពស់ការត្រួត ពិនិត្យ និងសម្របសម្រួល បទប្បញ្ញត្តិ និងការការពារអតិថិជនដើម្បីការពារស្ថិរភាពហិរញ្ញវត្ថុ ក្នុងខណៈពេលមានកំណើនឥណទានឆាប់រហ័ស។** កង្វះព័ត៌មាន និង ទីផ្សារ ‘ធនាគារស្រមោល (shadow banking)’ ធ្វើឲ្យលំបាក ក្នុងការកំណត់ទំហំហានិភ័យឲ្យបានត្រឹមត្រូវ។ កិច្ចការបន្ទាន់ និងសំខាន់បំផុត ត្រូវដោះស្រាយចំណុចខ្វះខាតមួយចំនួនអំពីការប្រមូលទិន្នន័យ និងសមត្ថភាពត្រួតពិនិត្យ។ ដំណោះស្រាយនេះ រួមបញ្ចូលទាំងការកែលម្អឥណទានមិនដំណើរការ ផលប៉ះពាល់នៃការយល់ញាតិ និងផលប៉ះពាល់ដែលបណ្តាលមកពីហានិភ័យរបស់ប្រទេស ក្នុងពេលដែលការបង្កើតប្រព័ន្ធព្រមានជាមុននៅមិនទាន់រួចរាល់។ ជាមួយគ្នានេះក៏ត្រូវកែលម្អការសម្របសម្រួលអន្តរស្ថាប័ន តាមរយៈការពង្រឹងកិច្ចសហការដែលមានស្រាប់។ ទីពីរ ចាំបាច់ត្រូវពង្រឹងបន្ថែមទៀតនូវក្របខ័ណ្ឌច្បាប់ផងដែរ ដើម្បីធានាឱ្យបាននូវស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ។ កាលពីពេលថ្មីៗកន្លងទៅនេះ អាជ្ញាធរបានដាក់ចេញនូវវិធានការសំខាន់ៗមួយចំនួន ក្នុងនោះ រួមមានកាតព្វកិច្ចបង្កើនទុនរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ទុនបម្រុងកាតព្វកិច្ចសម្រាប់ការខ្ចីប្រាក់ពីបរទេស និងអនុបាតគ្របដណ្តប់សាច់ប្រាក់ងាយស្រួល។ ជាចុងក្រោយ កំណើនយ៉ាងឆាប់រហ័សក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ក៏តម្រូវឱ្យមានការការពារ និងបង្កើនចំណេះដឹងរបស់អតិថិជន លើផ្នែកហិរញ្ញវត្ថុផងដែរ។

# ក្រឡេកមើលសេដ្ឋកិច្ចកម្ពុជា

### កម្ពុជាបន្តមានកំណើនដោយសារការនាំចេញ...

កំណើន ផសស ពិត បន្តមានភាពរឹងមាំ(ភាគរយ)




ប្រភព: ការប៉ាន់ស្មានរបស់អាជ្ញាធរនិងបុគ្គលិកធនាគារ
e = estimate; p = projection

### ...ជាមួយនឹងការកើនឡើងនូវផលិតកម្មសម្លៀកបំពាក់និងស្បែកជើង ...

ការនាំចេញសម្លៀកបំពាក់និងស្បែកជើងកើនឡើងក្នុងឆ្នាំ 2015




ប្រភព: ការប៉ាន់ស្មានរបស់អាជ្ញាធរកម្ពុជា

### ...និងការអភិវឌ្ឍស៊ីជម្រៅនៃវិស័យសំណង់ ...

គម្រោងសំណង់ដែលបានទទួលការយល់ព្រម
(លានដុល្លារអាមេរិក ពីដើមឆ្នាំដល់បច្ចុប្បន្ន)




ប្រភព: ការប៉ាន់ស្មានរបស់អាជ្ញាធរកម្ពុជា

### ... ទូទាត់ជាមួយការធ្លាក់ចុះនៃវិស័យកសិកម្ម...

ផលិតកម្មស្រូវក្នុងមួយឆ្នាំ(លានតោន)




ប្រភព: ការប៉ាន់ស្មានរបស់អាជ្ញាធរកម្ពុជា

### ... ខណៈលំហូរចូលFDIផ្តល់ហិរញ្ញប្បទានចំពោះវិស័យក្រៅប្រទេស

ឱនភាពពាណិជ្ជកម្ម គណនីចរន្ត និងវិនិយោគផ្ទាល់ពីបរទេស
(ភាគរយនៃ ផសស)




ប្រភព: ការប៉ាន់ស្មានរបស់អាជ្ញាធរនិងបុគ្គលិកធនាគារ

### ...និងកំណើននៃការប្រមូលចំណូលជួយពង្រឹងផ្នែកសារពើពន្ធ

ឱនភាពសារពើពន្ធទូទៅរបស់រដ្ឋាភិបាល(ភាគរយនៃ ផសស)




ប្រភព: ការប៉ាន់ស្មានរបស់អាជ្ញាធរកម្ពុជា
b= ថវិកា

## ខ. ការអភិវឌ្ឍសេដ្ឋកិច្ចកាលពីពេលថ្មីៗ

### ទិដ្ឋភាពទូទៅ

**កំណើនដែលដឹកមុខដោយការនាំចេញរបស់កម្ពុជាបានបន្តទោះបីជាប្រាក់ដុល្លារអាមេរិកឡើងថ្លៃក្តី។** នៅឆ្នាំ 2015 ការនាំចេញសម្លៀកបំពាក់ ជាកត្តាជំរុញចម្បង នាំឲ្យមានកំណើនទឹកប្រាក់នាំចេញកើនឡើង ក្នុងអត្រាកំណើន 12.3 ភាគរយ ធៀបនឹងឆ្នាំមុន ដែលមានអត្រា 9.2 ភាគរយ ក្នុងឆ្នាំ 2014[2]។ ទទួលបាននូវស្ថិរទីផ្សារការងារ និងការផ្លាស់ប្តូរបន្តិចម្តងៗ ទៅរកផលិតផលដែលមានតម្លៃបន្ថែមខ្ពស់ជាង ទំនងជាបានជួយវិស័យនេះឲ្យកែតម្រូវ និងពង្រីកខ្លួន ទោះបីជាប្រាក់ដុល្លាអាមេរិកឡើងថ្លៃក្តី។

**វិស័យសំខាន់ចំនួនពីរ គឺសម្លៀកបំពាក់និងស្បែកជើង និងសំណង់ (និងអចលនទ្រព្យ) ត្រូវបានប៉ាន់ប្រមាណថាបានរួមចំណែកពាក់កណ្តាលនៃកំណើនសរុបកាលពីឆ្នាំមុន។** វិស័យកាត់ដេរនិងស្បែកជើងគឺជាវិស័យសកម្មបំផុត ដែលរួមចំណែកធំបំផុតចំពោះកំណើន ស្មើនឹងមួយភាគបីនៃកំណើនពិតនៅក្នុងឆ្នាំ បន្ទាប់មកគឺវិស័យសំណង់ (និងអចលនទ្រព្យ) ដែលបានរួមចំណែកប្រហែលមួយភាគប្រាំមួយនៃចំនួនសរុប។ តាមការព្យាករណ៍មុននេះ កំណើនៃនវិស័យទេសចរណ៍បានបន្តធ្លាក់ចុះក្នុងឆ្នាំ 2015 ចំណែកឯវិស័យកសិកម្មនៅទ្រឹង។ ដូច្នេះកំណើនមានភាពរឹងមាំ ហើយអាជ្ញាធរបានកែសម្រួលការប៉ាន់ស្មានថាកំណើនស្មើនឹង 7.0 ភាគរយក្នុងឆ្នាំ 2015 ទាបជាងបន្តិចធៀបនឹង 7.1 ភាគរយ ដែលសម្រេចបានក្នុងឆ្នាំ 2014 (រូបភាពលេខ 1)។

**ក្នុងឆ្នាំ 2016 កំណើនត្រូវបានរំពឹងថានឹងនៅតែរឹងមាំក្នុងកម្រិត 6.9 ភាគរយ។** លទ្ធផលអនុវត្តន៍នៃវិស័យកាត់ដេរនិងស្បែកជើងប្រព្រឹត្តទៅបានល្អប្រសើរ ជួយទូទាត់ចំណុចខ្សោយក្នុងផលិតកម្មកសិកម្ម ចំណែកឯសកម្មភាពសំណង់ត្រូវបានរំពឹងថា នឹងចុះថយបន្តិចដោយសារចំនួនគម្រោងដែលបានអនុម័ត ធ្លាក់ចុះនៅក្នុងឆ្នាំ 2015។ វិស័យទេសចរណ៍ត្រូវបានរំពឹងថានឹងមានភាពប្រសើរឡើង ខណៈដែលមានសកម្មភាពទេសចរណ៍នៅក្នុងប្រទេសជិតខាង ពិសេសនៅប្រទេសថៃ នៅពេលដែលវិស័យទេសចរណ៍ថ្មីរបស់កម្ពុជាពឹងផ្អែកលើវិស័យទេសចរណ៍របស់ថៃ ដែលមានការអភិវឌ្ឍខ្ពស់ជាង។

**ហានិភ័យចំពោះទស្សនវិស័យនេះ** រួមមាន លទ្ធភាពអាចកើតមានវើដើបរំជួលការងារជាថ្មី ប្រាក់ដុល្លារអាមេរិកឡើងថ្លៃ ការងើបឡើងវិញយឺតៗនៃសេដ្ឋកិច្ចនៅអឺរ៉ុប និង ផលប៉ះពាល់ពីការធ្លាក់ចុះសេដ្ឋកិច្ចរបស់ចិន។ សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកជាខ្លាំងលើការនាំចេញ ពិសេសការនាំចេញសម្លៀកបំពាក់ និងស្បែកជើងទៅកាន់គោលដៅចម្បងទាំងពីរគឺសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចចិននឹងប៉ះពាល់ដល់ទិដ្ឋភាពកំណើន ដោយសារតែការមកដល់នៃភ្ញៀវទេសចរចិនធ្លាក់ចុះក្នុងរយៈពេលខ្លី និងដោយសារលំហូរចូលនៃវិនិយោគផ្ទាល់ពីបរទេសតិចក្នុងរយៈពេលមធ្យម។ ដីការលំបាកនៃសេដ្ឋកិច្ចចិននឹងប៉ះពាល់ដល់ចក្ខុវិស័យកំណើនសេដ្ឋកិច្ចចម្បង ដោយសារតែភ្ញៀវទេសចរមានសក្តានុពលទាបជាងប្រទេសចិន ក្នុងរយៈពេលខ្លី និងលំហូរចូល FDI យឺតនៅក្នុងរយៈពេលមធ្យម។

**រូបទី 1: លទ្ធផលអនុវត្តន៍នៃវិស័យកាត់ដេរនិងស្បែកជើងមានភាពប្រសើរឡើង កាត់កងផលិតកម្មកសិកម្មនៅទ្រឹងនៅក្នុងឆ្នាំ 2015។** ការចូលរួមចំណែកដល់កំណើនពិតប្រចាំឆ្នាំ (ក្នុងភាគរយ)



ប្រភព: ការប៉ាន់ស្មានរបស់អាជ្ញាធរនិងបុគ្គលិកធនាគារ

កម្ពុជាទំនងជា ត្រូវបានការពារពីការប្រែប្រួលហិរញ្ញវត្ថុសកលដោយសារទីផ្សារទុនមានកំណត់។ ទោះជាយ៉ាងណាក្តី គួរកត់សម្គាល់ថាលំហូរធនាគារក្នុងទម្រង់ជាប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស នៅតែជាបញ្ហារសើបចំពោះទំនុកចិត្តសាធារណជន និងការយល់ឃើញអំពីទីផ្សារ ជាកត្តាសំខាន់ក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចបានល្អប្រសើរ។

## វិស័យពិតផលិត

### ក). សម្លៀកបំពាក់

**នៅឆ្នាំ 2015 ការផលិតសម្លៀកបំពាក់ ដែលភាគច្រើនត្រូវបាននាំចេញ ជាកត្តាចម្បងក្នុងការជំរុញកំណើន ឲ្យកើនឡើង 12.3 ភាគរយ គិតលើតម្លៃនាំចេញ ធៀបនឹង 9.2 ភាគរយ ក្នុងឆ្នាំ 2014** (រូបភាពទី 2)[3] ។ ការវិលត្រឡប់នៃទីផ្សារការងារមកកាន់ស្ថិរភាព និងការប្តូរទៅកាន់ផលិតផលដែលមានតម្លៃបន្ថែមខ្ពស់[4] ទំនងជាបានជួយពង្រឹកវិស័យនេះ ជំនះបានឧបសគ្គក្នុងស្រុក ទោះបីជាក្នុងបរិបទ នៃប្រាក់ដុល្លារអាមេរិកឡើងថ្លៃក្តី។

**ខណៈពេលដែលបរិមាណនៃការនាំចេញសម្លៀកបំពាក់នៅតែបន្តជំរុញឱ្យមានកំណើននាំចេញ ការរួមចំណែកពីថ្លៃបានចាប់ផ្តើមកើនឡើងកាលពីពេលថ្មីៗ** (តារាងលេខ 1) ។ បរិមាណកើនឡើងបានបន្តជំរុញឱ្យមានកំណើននាំចេញសម្លៀកបំពាក់ ក្នុងរយៈពេលបួនឆ្នាំកន្លងមក ខណៈដែលការរួមចំណែកពីកំណើនថ្លៃក្នុងឆ្នាំ 2015 មានលក្ខណៈប្រសើរឡើង ត្រូវជា 28 ភាគរយនៃបរិមាណទឹកប្រាក់ ពីការនាំចេញសម្លៀកបំពាក់សរុប ក្នុងឆ្នាំ 2015 (តារាងលេខ 1) ។ នេះហាក់បីដូចបង្ហាញថាប្រទេសកម្ពុជាកំពុងប្តូរជាបណ្តើរៗ ចូលទៅក្នុងផលិតផលដែលមានតម្លៃបន្ថែមខ្ពស់។

**តារាងទី 1: បរិមាណ និងកំណើនថ្លៃ បានរួមចំណែក 71.9 ភាគរយ និង 28.1 ភាគរយ រៀងគ្នា ក្នុងឆ្នាំ 2015**

| កំណើនដោយសារ: | 2012 | | 2013 | | 2014 | | 2015 | |
|---|---|---|---|---|---|---|---|---|
| | លានដុល្លាអាមេរិក | (%) | លានដុល្លាអាមេរិក | (%) | លានដុល្លាអាមេរិក | (%) | លានដុល្លាអាមេរិក | (%) |
| *បរិមាណ* | *418.0* | *149.4* | *573.5* | *76.2* | *561.8* | *121.3* | *487.2* | *71.9* |
| *ថ្លៃ* | *-138.2* | *-49.4* | *178.8* | *23.8* | *-98.8* | *-21.3* | *190.7* | ***28.1*** |
| *សរុប* | 279.9 | 100.0 | 752.3 | 100.0 | 463.0 | 100.0 | 677.9 | 100.0 |

ប្រភព: ការប៉ាន់ស្មានរបស់អាជ្ញាធរនិងបុគ្គលិកធនាគារ

**ការនាំចេញសំលៀកបំពាក់ទៅកាន់សហភាពអឺរ៉ុបដែលជាទីផ្សារនាំចេញធំជាងគេ ស្រូបយក 42 ភាគរយនៃការនាំចេញសម្លៀកបំពាក់សរុប និងបន្តជំរុញកំណើន នាំចេញសម្លៀកបំពាក់រួមរបស់ប្រទេសកម្ពុជា។** ទោះជាយ៉ាងណាក្តី ការនាំចេញសម្លៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក ដែលស្មើនឹង 31 ភាគរយ នៃការនាំចេញសម្លៀកបំពាក់សរុប បានឈានដល់ចំណុចកំពូលរួចទៅហើយ។ ខណៈមាននិន្នាការធ្លាក់ចុះកាលពីប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ថ្លៃនាំចេញសម្លៀកបំពាក់ទាំងទៅទីផ្សារសហភាពអឺរ៉ុប និងអាមេរិក (រូបភាពទី 2) មានកម្រិតខ្ពស់ល្អ ក្នុងឆ្នាំ 2015 ទោះជាមានការប្រកួតប្រជែងក្នុងបរិបទនៃការឡើងថ្លៃប្រាក់ដុល្លាក្តី។

[3] តួលេខផ្អែកលើទិន្នន័យរបស់គយ។ អាចមានភាពខុសគ្នាចំពោះតួលេខដែលបង្ហាញដោយស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាល។

[4] ខណៈដែលវិស័យកាត់ដេរទំនងជាប្តូរទៅកាន់ផលិតផលដែលមានតម្លៃបន្ថែមកាន់តែខ្ពស់ក្នុងឆ្នាំ 2015 ចាំបាច់ត្រូវពិនិត្យមើលផលិតផល និងថ្លៃនាំចេញលំអិត ដើម្បីបញ្ជាក់ចំណុចនេះ។

**ការនាំចេញសម្លៀកបំពាក់ទៅកាន់សហភាពអឺរ៉ុបនាំមកភាគច្រើននៃកំណើននៃការនាំចេញនៅឆ្នាំ 2015 ហើយក៏មានពិពិធកម្មនៃការនាំចេញទៅកាន់គោលដៅផ្សេងៗទៀត ផងដែរ។** ក្នុងកំណើនសរុបនៃការនាំចេញសម្លៀកបំពាក់ តម្លៃជាទឹកប្រាក់មានចំនួន 678 លានដុល្លាអាមេរិក (ឬ 12.3 ភាគរយ) ក្នុងឆ្នាំ 2015 ក្នុងនោះ 60.8 ភាគរយបានមកពីកំណើននៃការនាំចេញទៅសហភាពអឺរ៉ុប 20.3 ភាគរយ កំណើននាំចេញទៅជប៉ុន និង 19.1 ភាគរយ បានមកពីកំណើនក្នុងការនាំចេញទៅកាន់គោលដៅផ្សេងទៀតក្រៅពីសហរដ្ឋអាមេរិក (តារាងទី 2 ) ។ ប៉ុន្តែបរិមាណទឹកប្រាក់នាំចេញសម្លៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិកឡើងដល់កម្រិតខ្ពស់បំផុតនៅឆ្នាំ 2014 និងបាននៅទ្រឹងចាប់តាំងពីពេលនោះមក។

**រូបទី 2: តម្លៃនាំចេញទៅកាន់សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក បានបញ្ចប់ក្នុងឆ្នាំ 2015** (ដុល្លាអាមេរិក ក្នុងមួយឡូត៍)




ប្រភព: អាជ្ញាធរកម្ពុជា

**តារាងទី 2: តម្លៃនៃការនាំចេញសម្លៀកបំពាក់ទៅកាន់សហភាពអឺរ៉ុបបានរួមចំណែកច្រើនបំផុត ស្មើនឹង 60.8 ភាគរយ នៃកំណើនសរុប។** (លានដុល្លាសហរដ្ឋអាមេរិក)

| | 2014 | 2015 | *បម្រែបម្រួល* | *គិតជា %* |
|---|---|---|---|---|
| តម្លៃនាំចេញសរុបក្នុងនោះ: | 5,489.3 | 6,167.2 | *677.9* | *100* |
| **សហភាពអឺរ៉ុប** | **2,172.8** | **2,585.0** | ***412.2*** | ***60.8*** |
| អាមេរិក | 1,889.3 | 1,888.2 | *-1.2* | *-0.2* |
| ជប៉ុន | 326.5 | 463.9 | *137.4* | *20.3* |
| ផ្សេងទៀត | 1,100.6 | 1,230.1 | *129.5* | *19.1* |

ប្រភព: អាជ្ញាធរកម្ពុជា

**គិតជាបរិមាណផលិតផល ការនាំចេញសម្លៀកបំពាក់សរុបបានកើនឡើង 14 លានឡូត៍ (ឬ 8.9 ភាគរយ ធៀបនឹងឆ្នាំមុន) ក្នុងឆ្នាំ 2015។** ក្នុងនោះ 78.3 ភាគរយបានមកពីកំណើនបរិមាណផលិតផលសម្លៀកបំពាក់នាំចេញទៅសហភាពអឺរ៉ុប 14.2 ភាគរយ នាំចេញទៅប្រទេសជប៉ុន និង 19.3 ភាគរយ បានមកពីកំណើនបរិមាណនាំចេញសម្លៀកបំពាក់ទៅគោលដៅផ្សេងទៀត(ក្រៅពីសហរដ្ឋអាមេរិក) (តារាងទី 3) ។ ផ្ទុយទៅវិញ បរិមាណនាំចេញសម្លៀកបំពាក់ទៅទីផ្សារអាមេរិកបានធ្លាក់ចុះ ជាមួយនឹងការរួមចំណែកអវិជ្ជមានចំនួន 12 ភាគរយ។

**តារាងទី 3: បរិមាណនាំចេញសម្លៀកបំពាក់ទៅកាន់សហភាពអឺរ៉ុបបានរួមចំណែកច្រើនបំផុតស្មើនឹង 78.3 ភាគរយ នៃកំណើនសរុបនៃបរិមាណសម្លៀកបំពាក់នាំចេញ។** (លានឡូត៍)

| | 2014 | 2015 | *បម្រែបម្រួល* | *ចំណែក %* |
|---|---|---|---|---|
| បរិមាណសរុបក្នុងនោះ: | 159.1 | 173.2 | *14.1* | *100* |
| **សហភាពអឺរ៉ុប** | **57.2** | **68.3** | ***11.1*** | ***78.3*** |
| សរដ្ឋអាមេរិក | 70.4 | 68.7 | *-1.7* | *-11.9* |
| ជប៉ុន | 5.0 | 7.0 | *2.0* | *14.2* |
| ក្រៅពីនេះ | 26.5 | 29.2 | *2.7* | *19.3* |

ប្រភព: អាជ្ញាធរកម្ពុជា

**ការនាំចេញសម្លៀកបំពាក់ក្នុងឆ្នាំ 2015 ត្រូវបានទ្រទ្រង់ដោយការងើបឡើងវិញបន្តិចម្តងៗនៅក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់ចម្បងៗ ជាពិសេសនៅសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។** ការងើបឡើងវិញនេះដែលមានកម្លាំងរុញច្រានក្នុងឆ្នាំ 2015 ត្រូវបានជំរុញដោយតម្រូវការក្នុងស្រុកកាន់តែខ្លាំង នៅក្នុងប្រទេសទាំងនោះនៅពេលដែលទីផ្សារការងារ និងស្ថានភាពឥណទានមានភាពប្រសើរឡើង[5]។ លទ្ធផលនៃការ នាំចេញសំលៀកបំពាក់ ត្រូវបានរំពឹងថានឹងនៅតែមានភាពរឹងមាំក្នុងឆ្នាំ 2016 ក្នុងសភាពដែលការនាំចូលក្រណាត់មានកំណើនខ្ពស់ ព្រោះក្រណាត់ជាវត្ថុធាតុដើមសំខាន់

[5] Global Economic Prospects, Spillovers amid Weak Growth, ខែ មករា ឆ្នាំ 2016.

សម្រាប់ផលិតកម្មសម្លៀកបំពាក់។

## ខ). វិស័យស្បែកជើង និង ទំនិញកសិកម្ម

**វិស័យស្បែកជើងកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ជាប្រភពចម្បងមួយនៃការនាំចេញ ភាគច្រើនត្រូវបាននាំចេញទៅទីផ្សារសហភាពអឺរ៉ុប។** ការនាំចេញស្បែកជើងបាននិងកំពុងកើនឡើងឆាប់រហ័ស ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំចំនួន 35 ភាគរយ ក្នុងរយៈពេលប្រាំឆ្នាំកន្លងមក។ បរិមាណទឹកប្រាក់នាំចេញស្បែកជើងចំនួនសរុបបានកើនឡើងដល់ 660 លានដុល្លាអាមេរិកក្នុងឆ្នាំ 2015 (តារាងលេខ 4) ពីត្រឹម 108 លានដុល្លាអាមេរិក ក្នុងឆ្នាំ 2009។ ប៉ុន្តែកំណើនខ្ពស់នៃការនាំចេញអង្ករ និងកៅស៊ូនៅឆ្នាំ 2015 ទំនងជាអាចចាត់ទុកថាជាលទ្ធផលនៃឥទ្ធិពលពីមូលដ្ឋានទាប នៅពេលដែលអត្រាកំណើនធ្លាក់ចុះ 20 ភាគរយ ឆ្នាំធៀបនឹងឆ្នាំ ដែលកើតឡើងចំពោះការនាំចេញកៅស៊ូ និងអង្ករក្នុងឆ្នាំ 2014។

**បច្ចុប្បន្ននេះប្រទេសកម្ពុជាទទួលបានការអនុគ្រោះលើអ្វីៗគ្រប់យ៉ាង លើកលែងតែអាវុធ (EBA) ពីសហភាពអឺរ៉ុបចំពោះការនាំចេញសម្លៀកបំពាក់របស់ខ្លួន។** ទោះយ៉ាងណាក្តី ការប្រកួតប្រជែងត្រូវបានរំពឹងថាមានលក្ខណៈកាន់តែខ្លាំងក្លា នៅពេលដែលសេរីភាវូបនីយកម្មពន្ធគយលើសម្លៀកបំពាក់ចូលជាធរមាន ក្រោម កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងសហភាពអឺរ៉ុបនិងប្រទេសវៀតណាម។ ស្រដៀងគ្នានេះដែរ ការនាំចេញសម្លៀកបំពាក់របស់ប្រទេសកម្ពុជា ទៅកាន់សហរដ្ឋ អាមេរិកទំនងជាប្រឈមមុខនឹងការប្រកួតប្រជែងកាន់តែតឹងតែងនៅពេលដែលសមាជិកនៃភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP) ទទួលបានការអនុគ្រោះ។ (សូមមើលអប់ទី1 សម្រាប់ព័ត៌មានលម្អិតបន្ថែមស្តីពីកិច្ចព្រមព្រៀងTPP)

### ប្រអប់ទី 1: ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក[1]

នៅថ្ងៃទី 4 តុលាឆ្នាំ 2015 ប្រទេសចំនួន 12 នៅតំបន់ប៉ាស៊ីហ្វិកបានបញ្ចប់ការចរចាស្តីពីភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP) ។ ប្រសិនបើហត្ថលេខីទាំងអស់ផ្តល់សច្ចាប័ន កិច្ចព្រមព្រៀងនេះអាចបង្កើនផលិតផលក្នុងស្រុកសរុបនៅប្រទេសជាសមាជិក ជាមធ្យម 1.1 ភាគរយ នៅឆ្នាំ 2030។ ទន្ទឹមនឹងនេះ កិច្ចព្រមព្រៀងនេះក៏អាចបង្កើនពាណិជ្ជកម្មរបស់បណ្តាប្រទេសជាសមាជិកចំនួន 11 ភាគរយ នៅឆ្នាំ 2030 ដែលតំណាងឱ្យការជម្រុញកំណើនពាណិជ្ជកម្មក្នុងតំបន់ដែលបានធ្លាក់ចុះមកត្រឹមប្រមាណជា 5 ភាគរយ ជាមធ្យម ក្នុងអំឡុងឆ្នាំ 2010-14 គឺធ្លាក់ចុះពី 10 ភាគរយ ក្នុងអំឡុងឆ្នាំ 1990-2007 ។ ដើម្បីឲ្យវិសាលភាពដែលថាអត្ថប្រយោជន៍នៃកំណែទម្រង់ នៅក្នុងប្រទេសសមាជិក TPP មានឥទ្ធិពលជាវិជ្ជមានសម្រាប់ពិភពលោកទាំងមូល ផលប៉ះពាល់អវិជ្ជមាននៃកិច្ចព្រមព្រៀងនេះ ដែលបណ្តាលមកពីការបង្វែរពាណិជ្ជកម្ម និងការបាត់បង់ភាពអនុគ្រោះមកលើប្រទេសមិនមែនសមាជិក នឹងមានទំហំតិចតួចប៉ុណ្ណោះ។ សារៈសំខាន់ជាសាកលនៃកិច្ចព្រមព្រៀងនេះអាស្រ័យលើបញ្ហា ថាតើកិច្ចព្រមព្រៀងនេះទទួលកម្លាំងជំរុញទូលំទូលាយពីអន្តរជាតិ ដែរឬយ៉ាងណា។

ផលចំណេញរបស់ TPP ភាគច្រើន នឹងបានមកពីការកាត់បន្ថយវិធានការមិនមែនពន្ធ ដែលផ្តល់ផលចំណេញដល់សេវាកម្មនានា។ សម្រាប់សមាជិក TPP ត្រឹមតែ 15 ភាគរយ នៃកំណើន ផសស ប៉ុណ្ណោះដែលបានមកពីការកាត់ពន្ធគយ ផ្ទុយទៅវិញ ការកាត់ដោយវិធានការមិនមែនពន្ធចំពោះទំនិញ នឹងស្មើ 53 ភាគរយ ហើយការកាត់ដោយវិធានការមិនមែនពន្ធចំពោះសេវា នឹងស្មើ 31 ភាគរយនៃកំណើនសរុបនៃ ផសស ។

ផលចំណេញធំបំផុតក្នុង ផសស ត្រូវបានរំពឹងថានឹងមាននៅក្នុងបណ្តាប្រទេសសមាជិកបើកចំហរតូចៗ ដូចជា វៀតណាម 10 ភាគរយ និងម៉ាឡេស៊ី 8 ភាគរយ។ ប្រទេសទាំងពីរនឹងទទួលផលចំណេញពីការបន្ថយពន្ធគយ និងវិធានការមិនមែនពន្ធគយនៅក្នុងទីផ្សារនាំចេញធំៗ និងនៅក្នុងស្រុក និងពីទីតាំងរឹងមាំនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ តាមរយៈសមាហរណកម្មស៊ីជម្រៅ។ TPP អាចពន្លឿនការផ្លាស់ប្តូរដែលមានលក្ខណៈរចនាសម្ព័ន្ធរវាងឧស្សាហកម្មផ្អែកលើឧត្តមភាពធៀប និងសេដ្ឋកិច្ចមាត្រដ្ឋាន។ វិស័យអតិពលកម្មដែលមានជំនាញ (ដូចជា សារធាតុគីមី យានយន្ត និងគ្រឿងយន្ត) ទំនងជាពង្រីកខ្លួនបានឆាប់រហ័សជាងនៅក្នុងប្រទេស ដែលមានសេដ្ឋកិច្ចជឿនលឿន ផ្ទុយទៅវិញវិស័យអតិពលកម្មគ្មានជំនាញ (ដូចជា វាយនភ័ណ្ឌ សម្លៀកបំពាក់ និងផលិតផលលោហៈ ទំនងជាពង្រីកខ្លួនបានកាន់តែឆាប់រហ័សនក្នុងបណ្តាប្រទេសសមាជិកមួយចំនួនដែលមានទីផ្សារកំពុងរីកចម្រើន។

[1] ប្រទេសទាំង 12 គឺ អូស្ត្រាលី ប្រ៊ុយណេ កាណាដា ឈីលី ជប៉ុន ម៉ាឡេស៊ី ម៉ិចស៊ិក នូវែលហ្សេឡង់ ប៉េរូ សង្ហបុរី សហរដ្ឋអាមេរិក និងវៀតណាម។

ប្រភព: January 2016 Global Economic Prospects, Spillovers amid Weak Growth, January 2016, World Bank

**តារាងទី 4: ការកើនឡើងនូវការនាំចេញស្បែកជើងនិងអង្ករ មួយផ្នែកធំគឺដោយសារការបង្កើនការនាំចេញទៅកាន់សហភាពអឺរ៉ុប**

| នាំចេញ (លានដុល្លាអាមេរិក) | 2013 | | 2014 | | 2015 | |
|---|---|---|---|---|---|---|
| | បរិមាណទឹកប្រាក់ | % បំរែបំរួលធៀបនឹងឆ្នាំមុន | បរិមាណទឹកប្រាក់ | % បំរែបំរួលធៀបនឹងឆ្នាំមុន | បរិមាណទឹកប្រាក់ | % បំរែបំរួលធៀបនឹងឆ្នាំមុន |
| ស្បែកជើង | 360.35 | 21.2 | 471.24 | 30.7 | 659.89 | 40.0 |
| អង្ករ | 262.27 | 92.8 | 210.4 | -19.7 | 315.30 | 49.8 |
| កៅស៊ូ | 175.17 | 6.5 | 138.69 | -20.8 | 165.39 | 19.2 |

ប្រភព: អាជ្ញាធរកម្ពុជា

## គ). សំណង់និងអចលនទ្រព្យ

**ការសាងសង់នៅតែមានលក្ខណៈរស់រវើក។** វិស័យសំណង់បន្តរីកចម្រើនយ៉ាងលឿន ពិសេសអគារលំនៅដ្ឋាន និងអគារពាណិជ្ជកម្មប្រណីតខ្ពស់ៗ ប្រមូលផ្តុំនៅចំកណ្តាលរាជធានីភ្នំពេញ។ ប៉ុន្តែកំណើននៃការចេញលិខិតអនុញ្ញាតសាងសង់ប្រចាំឆ្នាំ 2015 បានចុះថយ និងកើនឡើងត្រឹមតែ 2.3 ភាគរយ ប៉ុណ្ណោះធៀបនឹងឆ្នាំមុន ខណៈដែលការចេញលិខិតអនុញ្ញាតសាងសង់មានកំណើន 17.5 ភាគរយកាលឆ្នាំ 2014 (រូបលេខ 3)។ ការពង្រីកវិស័យសំណង់នេះ នៅតែបន្តកើនឡើងកាន់តែលឿន ដោយផ្តោតជាពិសេសលើអគារប្រណីតកើនឡើងខ្ពស់ លំនៅដ្ឋាន និងពាណិជ្ជកម្មបានប្រមូលផ្តុំនៅកណ្តាលរាជធានីភ្នំពេញ។ កំណើននៅក្នុងការអនុម័តលិខិតអនុញ្ញាតសាងសង់ប្រចាំឆ្នាំ ទោះជាយ៉ាងណាក្តី បានធ្លាក់ចុះពង្រីកដោយគ្រាន់តែ 2.3 ភាគរយពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងឆ្នាំ 2015 បើធៀបនឹង 17.5 ភាគរយពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងឆ្នាំ 2014 (រូបទី 3) ។

**រូបភាពទី 3. តម្រូវការអគារសំណង់ដែលមានតម្លៃខ្ពស់កំពុងកើនឡើង ដូចបានឃើញក្នុងការកើនឡើងនូវចំណាយជាមធ្យមក្នុងមួយម៉ែត្រការ៉េ ខណៈដែលចំនួនគម្រោងសាងសង់ដែលបានអនុម័តបានធ្លាក់ចុះ**




ប្រភព: អាជ្ញាធរកម្ពុជា

**ការកើនឡើងនូវការនាំចូលបរិក្ខារ និងសម្ភារៈសំណង់រាប់ទាំងផលិតផលដែកថែប បន្តទ្រទ្រង់ដល់សន្ទុះរីកចម្រើននៃការសាងសង់** (រូបទី 4) ។ នៅពេលដែលទីផ្សារក្នុងស្រុកមានទំហំតូច ការស្មានទុកជាមុនអំពីឱកាស ដែលកើតមានឡើង ពីការអនុវត្តសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ 2016 បន្តទ្រទ្រង់ដល់ការពង្រីកវិស័យសំណង់។ ការណ៍នេះត្រូវបានសម្រួលដោយរបបពាណិជ្ជកម្មសេរី និងការវិនិយោគរបស់ប្រទេសកម្ពុជា។

**រូបភាពទី 4: បរិមាណនាំចូលបរិក្ខារសំណង់ និងការនាំចូលដែកកំពុងកើនឡើងដោយសារសន្ទុះរីកចម្រើននៃការសាងសង់សព្វថ្ងៃ**




ប្រភព: អាជ្ញាធរកម្ពុជា

**បទពិសោធន៍អន្តរជាតិបង្ហាញថា ការសាងសង់មានតួនាទីតែពិសេសក្នុងកំណើនសេដ្ឋកិច្ច** និងជារឿយៗការសាងសង់ជាឧបករណ៍ស្ទង់ ដ៏សំខាន់នៃស្ថានភាពសេដ្ឋកិច្ច។ ការសាងសង់ធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់ប្រទេសមួយកើនឡើង ជាកត្តាសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចរយៈពេលវែង។ ការអនុវត្តនៃ

វិស័យសំណង់ធ្វើឲ្យប៉ះពាល់ដល់ និងត្រូវរងឥទ្ធិពលពីស្ថានភាពសេដ្ឋកិច្ចទូទៅ។ ទោះបីជាទូទៅមានទំហំតូចជាងវិស័យផ្សេងទៀត សកម្មភាពសាងសង់មានឥទ្ធិពលយ៉ាងខ្លាំងលើលទ្ធផល និងការងារនៃសេដ្ឋកិច្ចទាំងមូល ដោយសារវិស័យនេះអន្តរទំនាក់ទំនងជាមួយវិស័យដទៃទៀត[6]។

**រូបទី 5: ភាគរយសំណង់និងអចលនវត្ថុនៅក្នុងគម្រោងវិនិយោគបរទេសដែលបានអនុម័តសរុប (អចលនទ្រព្យ)** (គិតជាភាគរយ)




ប្រភព: អាជ្ញាធរកម្ពុជា

សន្ទុះរីកចម្រើននៃវិស័យសំណង់ និងអចលនទ្រព្យកំពុងជួបកំណើនហានិភ័យ ដោយសារសន្ទុះនៃការរីកចម្រើននេះបានជំរុញឲ្យមានបរិកប្ប (Speculation) ថ្លៃដី និងថ្លៃផ្ទះនៅទូទាំងរាជធានីភ្នំពេញ និងនៅក្នុងទីប្រជុំជនផ្សេងទៀតក៏ដូចជាធ្វើឲ្យមានកំណើនឥណទានយ៉ាងឆាប់រហ័ស ដែលអាចនាំដល់ការកើតឡើងនូវសេដ្ឋកិច្ចពពុះជាយថាហេតុ។ ទោះជាយ៉ាងណាក្តី ខុសពីការអភិវឌ្ឍលំនៅដ្ឋានតាមបែបប្រពៃណី ដែលហិរញ្ញប្បទានភាគច្រើនបានមកពីប្រភពក្នុងស្រុក ការអភិវឌ្ឍអគារលំនៅដ្ឋាន និងពាណិជ្ជកម្មទំនើបខ្ពស់ៗ មួយផ្នែកធំ ជាការវិនិយោគទុនរួមគ្នារវាងដៃគូក្នុងស្រុកនិងដៃគូអន្តរជាតិ ហើយហិរញ្ញប្បទានចម្បងបានមកពីការវិនិយោគផ្ទាល់ពីបរទេស (រូបទី 5)។

## ឃ). ទេសចរណ៍

**វិស័យទេសចរណ៍បានបន្ថយល្បឿន។** ការមកដល់នៃចំនួនភ្ញៀវទេសចរក្នុងឆ្នាំ 2015 បានកើនឡើង 6.1 ភាគរយធៀបនឹងឆ្នាំមុន (មានភ្ញៀវទេសចរហូតដល់ 4.8 លាននាក់) ធៀបនឹង 6.9 ភាគរយ នៅក្នុងឆ្នាំ 2014 (តារាងទី 5)។ ក្នុងឆ្នាំ 2015 ការមកដល់នៃចំនួនភ្ញៀវទេសចរតាមផ្លូវអាកាសបានបន្ថយល្បឿនច្រើនបំផុត គឺមានកំណើន 8.9 ភាគរយ ធៀបនឹងឆ្នាំមុន គឺឆ្នាំ 2014 ដែលមានកំណើន 12.7 ភាគរយ។ ប៉ុន្តែការងើបឡើងវិញពីដំបូងនៃសកម្មភាពទេសចរណ៍ក្នុងតំបន់ ពិសេសនៅប្រទេសថៃត្រូវបានរំពឹងថា នឹងមានឥទ្ធិពលវិជ្ជមានចំពោះការមកដល់នៃភ្ញៀវមកកាន់ប្រទេសកម្ពុជា។

**តារាងទី 5: កំណើនការមកដល់នៃភ្ញៀវទេសចរមកកាន់ប្រទេសកម្ពុជាបានធ្លាក់ចុះបន្ថែមទៀតនៅក្នុងឆ្នាំ 2015 ប៉ុន្តែកំណើននៃការមកដល់របស់ភ្ញៀវទេសចរមកកាន់ប្រទេសថៃត្រូវបានរំពឹងថានឹងមានផលវិជ្ជមានមកលើសកម្មភាពទេសចរណ៍នៅក្នុងប្រទេសកម្ពុជា។** (ការមកដល់របស់ភ្ញៀវទេសចរ លាននាក់)

| | កម្ពុជា | | | ថៃ | | | វៀតណាម | | |
|---|---|---|---|---|---|---|---|---|---|
| | 2013 | 2014 | 2015 | 2013 | 2014 | 2015 | 2013 | 2014 | 2015 |
| ការមកដល់សរុប | 4.2 | 4.5 | 4.8 | 26.5 | 24.8 | 29.3 | 7.5 | 7.8 | 7.9 |
| បំរែបំរួល (ធៀបឆ្នាំមុន) | 17.5% | 6.9% | 6.1% | 18.8% | -6.4% | 17.7% | 12.5% | 3.8% | 0.8% |
| ក្នុងនោះ: មកតាមផ្លូវអាកាស | 2.0 | 2.3 | 2.5 | 15.4 | 15.5 | 18.4* | 6.0 | 6.2 | 6.3 |
| បំរែបំរួល (ធៀបឆ្នាំមុន) | 17.2% | 12.7% | 8.9% | 8.7% | 1.0% | 18.6% | 6.8% | 4.0% | 0.8% |

ប្រភព: អាជ្ញាធរកម្ពុជា, TAT, ក្រសួងវប្បធម៌ កីឡា និងទេសចរណ៍វៀតណាម

* ផ្អែកលើចំនួនមកដល់ពីខែមករា-ខែតុលា ឆ្នាំ 2015

**ការបន្ថយល្បឿននៃកំណើននូវចំនួនភ្ញៀវទេសចរក្នុងឆ្នាំ 2015 បានធ្វើឲ្យនូវការប្រមូលចំណូលនៅឧទ្យានបុរាណអង្គរដែលជាតំបន់ទាក់ទាញភ្ញៀវទេសចរធំជាងគេនៅកម្ពុជាកើនយឺត** (រូបភាពទី 6) ។

[6] កម្លាំងជម្រុញស្អិតនៅពីក្រោយសន្ទុះរីកចម្រើន និងការផ្ទុះបែកក្នុងវិស័យសំណង់នៅអឺរ៉ុប Yan Sun, Pritha Mitra, and Alejandro Simone, IMF Working Paper, WP/13/181.

ក្នុងឆ្នាំ 2015 ចំនួនភ្ញៀវទេសចរដែលបានមកទស្សនាឧទ្យាននេះកើនឡើងតែ 2 ភាគរយ ដល់ចំនួន 2.1 លាននាក់ ហើយចំណូលពីឧទ្យានបុរាណនេះកើនឡើងត្រឹមតែ 1.2 ភាគរយដល់ 60.05 លានដុល្លាអាមេរិកប៉ុណ្ណោះ[7] ។

**រូបទី 6: ចំនួនភ្ញៀវទេសចរដែលបានមកទស្សនាទីលានបុរាណអង្គរ បានថយល្បឿន ដូចការថយល្បឿននូវប្រាក់ចំណូល នៅទីលាននេះដែរ**




ប្រភព: អាជ្ញាធរកម្ពុជា

**ទ្វីបអាស៊ីបានក្លាយជាប្រភពចម្បង នៃភ្ញៀវទេសចរដែលរួមចំណែកជិត 85 ភាគរយនៃចំនួនភ្ញៀវសរុបមកដល់ប្រទេសកម្ពុជា ក្នុងរយៈពេលប្រាំឆ្នាំកន្លងមក** (តារាងលេខ 6) ។ កម្ពុជាបានទទួលជោគជ័យក្នុងការទាក់ទាញភ្ញៀវទេសចរបរទេស ដែលការមកដល់របស់ភ្ញៀវក្នុងឆ្នាំ 2015 មានចំនួន 4.8 លាននាក់ ស្ទើរតែស្មើពីរដងនៃចំនួនភ្ញៀវចំនួន 2.5 លាននាក់ដែលមកដល់កម្ពុជាក្នុងឆ្នាំ 2010។ ទោះយ៉ាងណាក្តី វិស័យ ទេសចរណ៍ហាក់ដូចជាពឹងផ្អែកកាន់ខ្លាំងលើការ មកដល់នៃភ្ញៀវទេសចរមកពីតំបន់អាស៊ី ជាមួយនឹងការមកដល់នៃភ្ញៀវទេសចរពីអឺរ៉ុប ដែលថយល្បឿនតាំងពីឆ្នាំ 2010 មកម្ល៉េះ។ ប្រទេសជិតខាងកម្ពុជាគឺប្រទេស វៀតណាម ចិន ឡាវ និងថៃបានរួមចំណែកប្រមាណជា 70 ភាគរយ នៃចំនួនភ្ញៀវទេសចរសរុបដែលបានកើនឡើង 2.2 លាននាក់ពីឆ្នាំ 2010 ដល់ឆ្នាំ 2015 ។

[7]យោងតាមអាជ្ញាធរអប្សរា សម្រាប់ព័ត៌មានបន្ថែម សូមអាន http://apsaraauthority.gov.kh/?page=detail&menu1=649&ctype=document&id=649&ref_id=13&lg=kh

**តារាងទី 6: ទ្វីបអាស៊ីបានក្លាយទៅជាប្រភពសំខាន់នៃភ្ញៀវទេសចរដែលចូលរួមចំណែកជិត 85 ភាគរយនៃចំនួនមកដល់នៃភ្ញៀវទេសចរសរុបដែលបានកើនឡើងក្នុងរយៈពេលប្រាំឆ្នាំកន្លងមក។** ការរួមចំណែកដល់កំណើនភ្ញៀវទេសចរតាមប្រទេសប្រភពដើមចាប់តាំងពីឆ្នាំ 2011 (គិតជាភាគរយ)

| | 2011 | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|
| **អាស៊ី** | **80.1** | **84.1** | **83.7** | **84.6** | **84.2** |
| វៀតណាម | 26.7 | 23.1 | 20.0 | 19.6 | 20.9 |
| ចិន | 18.6 | 14.5 | 16.8 | 19.2 | 25.5 |
| ឡាវ | 9.7 | 15.0 | 18.9 | 18.4 | 13.8 |
| ថៃ | -8.7 | 4.9 | 4.2 | 6.5 | 8.9 |
| **អឺរ៉ុប** | **14.3** | **11.3** | **12.3** | **11.2** | **10.1** |
| អាមេរិក | 4.9 | 4.2 | 3.8 | 3.9 | 5.1 |
| អាហ្វ្រិក | 0.4 | 0.1 | 0.1 | 0.1 | 0.2 |
| មជ្ឈិមបូព៌ា | 0.3 | 0.3 | 0.2 | 0.2 | 0.3 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 |

ប្រភព: អាជ្ញាធរកម្ពុជា

**កំណើនការមកដល់នៃចំនួនភ្ញៀវទេសចរ ទៅកាន់ប្រទេសថៃ (រួមទាំងការមកដល់តាមផ្លូវអាកាស) ជាសញ្ញាល្អសម្រាប់ការបង្កើនចំនួនភ្ញៀវទេសចរ មកកាន់ប្រទេសកម្ពុជា** ដោយសារវិស័យទេសចរណ៍កម្ពុជាជាវិស័យថ្មី វិស័យនេះផ្អែកលើវិស័យទេសចរណ៍ ប្រទេសថៃដែលមានការអភិវឌ្ឍច្រើនជាង។

## ង). កសិកម្ម

**បន្ទាប់ពីមានអត្រាកំណើនខ្ពស់អស់រយៈពេលវែង ជាមធ្យមស្មើ 5.5 ភាគរយ គិតតាមអត្រាកំណើនពិត ក្នុងអំឡុងឆ្នាំ 2005-13 មក ផសស នៃវិស័យកសិកម្មមានកំណើនត្រឹមតែ 0.3 ភាគរយប៉ុណ្ណោះ នៅឆ្នាំ 2015 និង 0.2 ភាគរយ នៅឆ្នាំ 2014** (រូបភាពទី 7)។ ស្ថានភាពអាកាសធាតុមិនសូវអំណោយផល ពិសេសភ្លៀងធ្លាក់មិនទៀងទាត់ រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមាន លើផលិតកម្មកសិកម្ម។ ដោយសារតែការធ្វើស្រែ នៅតែជាការធ្វើស្រែបែបប្រពៃណី ការធ្លាក់ចុះថ្លៃស្រូវអង្ករទំនងជាមិនសូវមានផលប៉ះពាល់អវិជ្ជមាន មកលើផលិតកម្មស្រូវឡើយ

(ខុសពីប្រភេទផលិតកម្មកសិកម្មផ្សេងទៀត ដូចជា កៅស៊ូ និងដំឡូងមី ជាដើម)[8] ។

**រូបទី 7: កំណើន ផសស កសិកម្មមានកំណើនតិចតួច ត្រឹមតែ 0.3 ភាគរយ ក្នុងឆ្នាំ 2014 និង 0.2 ភាគរយ ក្នុងឆ្នាំ 2015 ធៀបនឹងឆ្នាំមុន។** (គិតតាមថ្លៃថេរឆ្នាំ 2000 តម្លៃ បំរែបំរួលគិតជា %)




ប្រភព: អាជ្ញាធរកម្ពុជា
e= ប៉ាន់ស្មាន

**វិស័យកសិកម្មនៅតែបន្តពឹងផ្អែកជាខ្លាំង លើការ ផលិតស្រូវរដូវវស្សា។** ទោះបីជាមានកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើឱ្យប្រសើរឡើង នូវប្រព័ន្ធស្រោចស្រពរបស់កម្ពុជា និងការធ្វើពិពិធកម្មផលិតកម្មដំណាំក្តី វិស័យកសិកម្មនៅតែបន្តពឹងផ្អែកជាខ្លាំង លើផលិតកម្មស្រូវរដូវវស្សាដែលជាពឹងផ្អែកជាខ្លាំងលើទឹកភ្លៀង។ ជាលទ្ធផលនៅឆ្នាំ 2015 ផលិតកម្មស្រូវ ត្រូវបានអាជ្ញាធរប៉ាន់ប្រមាណថាធ្លាក់ចុះ 1.1 ភាគរយ ធៀបនឹងឆ្នាំមុន (តារាងទី 7)។ លើសពីនេះទៀតកសិករកំពុងប្រឈមមុខនឹងការធ្លាក់ចុះថ្លៃទំនិញកសិកម្ម ដែលមានផលប៉ះពាល់អវិជ្ជមាន ដល់ប្រាក់ចំណូលរបស់ពួកគេ។ សភាពការណ៍នេះ តម្រូវឱ្យមានផលិតភាពខ្ពស់ ដើម្បីទប់ទល់នឹងថ្លៃទាប និងសម្រាប់ការធ្វើពិពិធកម្ម ចំពោះដំណាំអតិផលដែលត្រូវការទឹកតិច។

**តារាងទី 7: ផលិតកម្មស្រូវយឺតពេលក្នុងឆ្នាំ 2015/16 ជាងក្នុងឆ្នាំ2014/15 ដោយសារតែស្ថានភាពអាកាសធាតុមិនស្វអំណោយផល ។**

| ផលិតកម្មស្រូវ | 2014/15 | 2015/16e | បំរែបំរួល (%) |
|---|---|---|---|
| **ផ្ទៃដីដាំដុះ** (លានហ.ត.) | **3.056** | **3.027** | **-0.9** |
| *ក្នុងនោះ: រដូវវស្សា* | *2.565* | *2.562* | *-0.1* |
| **ផ្ទៃដីប្រមូលផល** (លានហ.ត.) | **3.029** | **2.996** | **-1.0** |
| *ក្នុងនោះ: រដូវវស្សា* | *2.538* | *2.536* | *-0.1* |
| **ផលិតកម្ម** (លានតោន) | **9.227** | **9.329** | **-1.1** |
| *ក្នុងនោះ: រដូវវស្សា* | *7.144* | *7.175* | *0.4* |
| ដំណាំផ្សេងទៀត (ផ្ទៃដីដាំដុះគិតជាហិកតា) | ត្រឹមខែកុម្ភៈ 2015 | ត្រឹមខែកុម្ភៈ 2016 | បំរែបំរួល (%) |
| ពោត | 24,312 | 23,483 | -3.4 |
| ដំឡូង | 12,887 | 19,641 | 52.4 |
| សណ្តែក | 11,442 | 13,582 | 18.7 |

ប្រភព: អាជ្ញាធរកម្ពុជា (final wet and estimated dry season rice production, February 2016), http://www.maff.gov.kh/reports/67-monthlyreport.html

**រូបទី 8: ផលិតកម្មស្រូវឡើងដល់កម្រិតខ្ពស់បំផុតនៅឆ្នាំ 2013 និងចាប់តាំងពីនោះមកបានធ្លាក់ចុះ** (លានតោន)




ប្រភព: អាជ្ញាធរកម្ពុជា
e=ប៉ាន់ស្មាន

**ការធ្វើទំនើបកម្មវិស័យកសិកម្មនឹងជួយធ្វើឲ្យផលិតភាពមាននិរន្តរភាពក្នុងរយៈពេលវែង។** ដូចបានពិភាក្សានៅក្នុងបញ្ហាមួយចំនួននៃបាយការណ៍បច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជាឆ្នាំ 2015 របាយការណ៍កាលពីពេលថ្មីៗរបស់ធនាគារពិភពលោក ដែលមានចំណងជើងថា "*Cambodian Agriculture in Transition: Opportunities and Risks (កសិកម្មកម្ពុជាក្នុងអន្តរកាល: កាលានុវត្តភាព និងហានិភ័យ)*"[9]បានលើកឡើងថា ការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចកម្ពុជា ក៏អាចបង្ហាញការធ្លាក់ចុះ

[8] ចំណុចនេះបណ្តាលមកពីការធ្លាក់ចុះនៃផ្ទៃដីធ្វើស្រែដែលមានទំហំតិចជាងផ្ទៃដីប្រមូលផល (និងផលិតកម្មស្រូវ)។

[9] របាយការណ៍ពីស្ការអាចរកបាននៅលើគេហទំព័រ http://documents.worldbank.org/curated/en/2015/08/24919384/cambodian-agriculture-transition-opportunities-risks.

កំណើនរយៈពេលវែងផងដែរ វៀរលែងតែកត្តាផលិតភាពសរុប មានសភាពប្រសើរឡើង។ រូបលេខ 8 និងលេខ 9 បង្ហាញថា ផលិតកម្មស្រូវបានឡើងដល់កម្រិតខ្ពស់បំផុតចំនួន 9.39 លានតោន ក្នុងឆ្នាំ 2013 និងបានធ្លាក់ចុះចាប់តាំងពីពេលនោះមក ទន្ទឹមនឹងការធ្លាក់ចុះកំណើនទិន្នផលស្រូវ។

**រូបទី 9: កំណើនទិន្នផល និងកំណើននៃការពង្រីកផ្ទៃដីដាំដុះយឺតធ្វើឲ្យផលិតកម្មស្រូវប្រចាំឆ្នាំនៅទ្រឹង និងធ្លាក់ចុះចាប់តាំងពីឆ្នាំ 2013 មក**




ប្រភព: អាជ្ញាធរកម្ពុជា

**នៅក្នុងបរិបទនៃថ្លៃកសិផលអន្តរជាតិធ្លាក់ចុះ បញ្ហាប្រឈមថ្មីកើតឡើង។** ខណៈពេលដែលថ្លៃស្បៀងកើនឡើងជាសាកលនៅឆ្នាំ 2008 សភាពការណ៍នេះបានផ្តល់ឱកាសដល់ការជម្រុញកំណើនកសិកម្ម និងធ្វើឲ្យការពង្រីកដីកសិកម្មទទួលបានផលចំណេញ ការធ្លាក់ចុះនៃថ្លៃស្បៀងអាហារនាពេលថ្មីៗ នៅទូទាំងពិភពលោក និងទីផ្សារអង្ករពិភពលោកដែលមានការប្រកួតប្រជែងកាន់តែច្រើន ជាមួយនឹងការចូលមកសាជាថ្មី របស់ប្រទេសថៃ និងមីយ៉ាន់ម៉ា បានដាក់សម្ពាធលើប្រទេសកម្ពុជា។ យកល្អ គួរផ្តោតការយកចិត្តទុកដាក់ប្តូរពីផលិតកម្មកម្រិតខ្ពស់ និងការនាំចេញ ទៅកាន់ជំណាំស្រូវដែលបានធ្វើពិពិធកម្ម លក្ខណៈពាណិជ្ជកម្ម និងធន់នឹងការប្រែប្រួលធាតុអាកាស និងដែលគាំទ្រដោយខ្សែសង្វាក់តម្លៃទំនើប និងការដឹកជញ្ជូនថោកតែមានប្រសិទ្ធភាព។ មានគោលនយោបាយបួនយ៉ាងដែលរបាយការណ៍ *"Cambodian Agriculture in Transition: Opportunities and Risks"* ផ្តល់អនុសាសន៍ ប្រសិនបើអនុវត្តរួមគ្នានូវសំណើគោលនយោបាយទាំងនោះ អាចនឹងជួយដល់ការផ្លាស់ប្តូរនេះ។ ទីមួយ គឺរក្សាឲ្យមានបរិយាកាសគោលនយោបាយកសិកម្ម ដែលវិស័យឯកជនងាយអនុវត្ត ជាមួយនឹងការបង្កើនការយកចិត្តទុកដាក់ក្នុងការកាត់បន្ថយបន្ទុកផ្នែកបទប្បញ្ញត្តិ ក្នុងវិស័យវត្ថុធាតុដើមកសិកម្ម។ ទីពីរ ត្រូវបានពង្រឹងនិរន្តរភាពបរិស្ថាននៃផលិតកម្មកសិកម្ម។ ទីបី ត្រូវធ្វើអោយប្រសើរឡើង នូវគុណភាពនៃកម្មវិធីកសិកម្មសាធារណៈ និងបង្កើនវិភាជន៍ថវិកាថវិកាជាតិសរុបទៅកាន់កម្មវិធីនានាដែលមានប្រសិទ្ធិភាពបន្ថែមទៀត។ ទីបួន គឺជួយអភិវឌ្ឍធុរកិច្ចកសិកម្ម និងឧស្សាហកម្មកែច្នៃកសិផល ។ (សូមមើលរបាយការណ៍ពេញលេញសម្រាប់អនុសាសន៍លម្អិតបន្ថែមទៀត)

## ការងារ ប្រាក់ចំណូល និងការប្រើប្រាស់

**ភាគលាភប្រជាសាស្ត្ររបស់ប្រទេសកម្ពុជា បានរួមចំណែកឆ្ពោះទៅរកការពង្រីកសេដ្ឋកិច្ច និងកំណើនប្រាក់ចំណូលក្នុងពលរដ្ឋម្នាក់។** កម្លាំងពលកម្មកំពុងកើនឡើងលឿនជាងចំនួនប្រជាជន ដែលពឹងផ្អែកលើវា រំដោះបាននូវធនធានសម្រាប់ការវិនិយោគ និងកំណើនប្រាក់ចំណូលគ្រួសារ។ ខុសពីប្រទេសជាច្រើនក្នុងតំបន់ ប្រទេសកម្ពុជាមានការកើនឡើងនូវចំនួនប្រជាជន ក្នុងវ័យធ្វើការ (15-64 ឆ្នាំ) ជិត 1.2 លាននាក់ កើនឡើងពី 8.8 លាន នៅឆ្នាំ 2009 ដល់ 10 លាននាក់នៅឆ្នាំ 2014 (តារាង 8) យោងតាម អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ 2014 (CSES)។ ជាមធ្យមកម្ពុជាបន្ថែមកម្លាំងពលកម្មរបស់ខ្លួនចំនួន 162,000 នាក់ ជារៀងរាល់ឆ្នាំ ក្នុងនោះមាន 159,000 នាក់ ត្រូវបានផ្តល់ការងារឲ្យធ្វើក្នុងវិស័យសេដ្ឋកិច្ច។

**តារាងលេខ 8: ចំនួនប្រជាជន និងកម្លាំងពលកម្មដែលមានអាយុពី (15-64 ឆ្នាំ) តាមភេទ និងតាមភូមិសាស្ត្រ ឆ្នាំ 2009 និងឆ្នាំ 2014** ( '000 ឯកតា និងភាគរយ)

| កម្លាំងពលកម្ម និងភេទ | CSES 2009 | | | | CSES 2014 | | | |
|---|---|---|---|---|---|---|---|---|
| | កម្ពុជា | ភ្នំពេញ | ទីប្រជុំជនដទៃ | ជនបទដទៃ | កម្ពុជា | ភ្នំពេញ | ទីប្រជុំជនដទៃ | ជនបទដទៃ |
| ចំនួនប្រជាជនសរុប | 13,967 | 1,383 | 1,428 | 11,156 | 15,184 | 1,794 | 1,796 | 11,594 |
| ចំនួនប្រ/ជសរុបក្នុងវ័យធ្វើការ | 8,865 | 1,001 | 956 | 6,907 | 10,001 | 1,361 | 1,219 | 7,421 |
| កម្លាំងពលកម្ម | 7,480 | 688 | 737 | 6,055 | 8,259 | 1,060 | 961 | 6,238 |
| អត្រាចូលរួមរបស់កម្លាំងពលកម្ម | | | | | | | | |
| ស្ត្រី | 80.4 | 61.5 | 72.7 | 84.3 | 77.5 | 72.2 | 71.1 | 79.6 |
| បុរស | 88.8 | 77.2 | 82.1 | 91.3 | 87.9 | 84.1 | 87.3 | 88.7 |
| ទាំងពីរភេទ | 84.4 | 68.7 | 77.2 | 87.7 | 82.6 | 77.9 | 78.8 | 84.1 |
| អត្រាមានការងារធ្វើ | | | | | | | | |
| ស្ត្រី | 80.3 | 61.4 | 72.6 | 84.2 | 77.4 | 72.0 | 71.0 | 79.4 |
| 84.1បុរស | 88.6 | 76.9 | 81.7 | 91.2 | 87.8 | 84.0 | 86.9 | 88.6 |
| ទាំងពីរភេទ | 84.3 | 68.5 | 77.0 | 87.6 | 82.4 | 77.8 | 78.6 | 83.9 |

ប្រភព:អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ 2014 (CSES) វិទ្យាស្ថានជាតិស្ថិតិ ខែ តុលា ឆ្នាំ 2015

**ប្រទេសកម្ពុជាក៏បានជួបប្រទះផងដែរ នូវការធ្លាក់ចុះ ជាខ្លាំង នូវចំណែកភាគរយនៃចំនួនអ្នកមានការងារធ្វើក្នុងវិស័យកសិកម្ម** ដែលផ្តោតលើការបង្កើនផលិតភាព ក្នុងពេលដែលវិស័យនេះ បន្តរួមចំណែកចំពោះកំណើនសេដ្ឋកិច្ច។ ចំណែកភាគរយនៃចំនួនប្រជាជនសរុបដែលធ្វើការក្នុងវិស័យកសិកម្ម (ដែលមានអាយុពី 15 ទៅ 64 ឆ្នាំ) បានធ្លាក់ចុះជិត 2.5 ភាគរយក្នុងមួយឆ្នាំក្នុងអំឡុង 2009-14 ធ្លាក់ចុះពី 57.6 ភាគរយ ក្នុងឆ្នាំ 2009 ដល់ 45.3 ភាគរយ ក្នុងឆ្នាំ 2014 បានកាត់បន្ថយការងារចំនួនកន្លះលាននាក់ (តារាងលេខ 9) ។ អំឡុងពេលនេះ ចំណែកភាគរយការងារ នៃវិស័យសេវាកម្ម និងវិស័យឧស្សាហកម្មបានកើនឡើងពី 26.5 ភាគរយ ដល់ 30.4 ភាគរយ (ជាមួយនឹងការងារបន្ថែមសម្រាប់ 0.8 លាននាក់) និងពីនិង 15.9 ភាគរយ ដល់ 24.3 ភាគរយ (ជាមួយនឹងការងារបន្ថែមសម្រាប់ 0.5 លាននាក់។

**តារាងលេខ 9: ចំណែកនៃចំនួនប្រជាជនដែលធ្វើការនៅក្នុងវិស័យកសិកម្មបានធ្លាក់ចុះពី 57.6 ភាគរយ ក្នុងឆ្នាំ 2009 ដល់ 45.3 ភាគរយ ក្នុងឆ្នាំ 2014 ធ្វើឲ្យបាត់បង់ការងារសម្រាប់កន្លះលាននាក់ ខណៈដែលវិស័យសេវាកម្មបានបង្កើតការងារសម្រាប់ 0.8 លាននាក់ និង វិស័យឧស្សាហកម្ម 0.5 លាននាក់។** ចំនួនអ្នកមានការងារធ្វើតាម វិស័យ។ (ពាន់នាក់)

| | 2009 | 2014 | +/- បំរែបំរួល |
|---|---|---|---|
| **ចំនួនអ្នកមានការងារធ្វើ** | 7,469 | 8,235 | 766 |
| **’000** | | | |
| កសិកម្ម (វិស័យទី1) 1/ | 4,302 | 3,730 | **-572** |
| ឧស្សាហកម្ម (វិស័យទី2) 2/ | 1,188 | 2,001 | 814 |
| សេវាកម្ម (វិស័យទី3) 3/ | 1,979 | 2,503 | 524 |
| **ចំណែក (%)** | | | |
| កសិកម្ម ((វិស័យទី1) | 57.6 | 45.3 | **-12.3** |
| ឧស្សាហកម្ម (វិស័យទី2) | 15.9 | 24.3 | 8.4 |
| សេវាកម្ម ((វិស័យទី3) | 26.5 | 30.4 | 3.9 |
| សរុប | 100 | 100 | |

ការប្រើចំណាត់ថ្នាក់វិស័យតាមស្តង់ដារអន្តរជាតិ (ISIC បប 4.0): 1: កសិកម្មរុក្ខាប្រមាញ់និងនេសាទ; 2: រ៉ែនិងការយកថ្ម កម្មន្តសាល ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ការផ្គត់ផ្គង់ឧស្ម័នម៉ាស៊ីនត្រជាក់ ការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងលូទឹក គ្រប់គ្រងសំរាម និងសកម្មភាពកែលម្អ និងសំណង់ 3: ការលក់ដុំលក់រាយ ការជួសជុល ការដឹកជញ្ជូន ការទុកដាក់ ការស្នាក់នៅ សេវាម្ហូបអាហារ ព័ត៌មាន ការប្រាស្រ័យទាក់ទង សកម្មភាពហិរញ្ញវត្ថុធានារ៉ាប់រង អចលនទ្រព្យ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ បច្ចេកទេស រដ្ឋបាល រដ្ឋបាលសាធារណៈ ការពារជាតិ ការអប់រំ សុខាភិបាល សិល្បៈ ការកំសាន្ត សកម្មភាពសេវាកម្មផ្សេងទៀត និងជាច្រើនទៀត។

ប្រភព: អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ 2014

**កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ធ្វើឲ្យប្រាក់ចំណូលសម្រាប់ពលរដ្ឋម្នាក់ៗ កើនឡើងទ្វេដងក្នុងអំឡុងឆ្នាំ 2009-14** (រូបទី 10) ។ ប្រាក់ចំណូលប្រចាំខែរបស់ជនបទដទៃទៀត បានកើនឡើងឆាប់រហ័សចំនួន 120 ភាគរយ ក្នុងអំឡុង 2009-14 កើនពី 121,000 រៀល នៅឆ្នាំ 2009 ដល់ 265,000 រៀល នៅឆ្នាំ 2014 ។

**រូបភាពទី 10: ប្រាក់ចំណូលក្នុងពលរដ្ឋម្នាក់នៃ "ជនបទផ្សេងទៀត" បានកើនឡើងលឿនបំផុតក្នុងអំឡុងឆ្នាំ 2009-14 ។** ប្រាក់ចំណូលមធ្យមប្រចាំខែ (គិតជាពាន់រៀល)




ប្រភព: អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា

នៅពេលដែលស្តង់ដានៃការរស់នៅ មានភាពប្រសើរឡើង ដូច្នេះចំណែកនៃការទទួលទានអាហារក្នុងការប្រើប្រាស់សរុបធ្លាក់ចុះពីឆ្នាំ 2009-14 (រូបភាពទី 11) ខណៈដែលភាគរយនៃគ្រួសារ ដែលជាម្ចាស់ទំនិញប្រើប្រាស់បានយូរ ដូចជា ទូរស័ព្ទដៃ ម៉ូតូ និងទូរទស្សន៍ បានកើនឡើងយ៉ាងឆាប់រហ័ស (តារាងទី 10 )។

**រូបទី 11: ចំណែកនៃការទទួលទានអាហារក្នុងការប្រើប្រាស់សរុបថយចុះតាមតំបន់ភូមិសាស្ត្រ** (ភាគរយ).




ប្រភព: អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ 2014

**តារាងទី 10: ភាពជាម្ចាស់នៃទំនិញប្រើប្រាស់បានយូរបានកើនឡើងយ៉ាងឆាប់រហ័សនៅទូទាំងដែនភូមិសាស្ត្រ។** ភាគរយនៃគ្រួសារដែលជាម្ចាស់ទំនិញប្រើប្រាស់បានយូរ (ភាគរយ)។

| មុខទំនិញប្រើបានយូរ | 2009 | | | | 2014 | | | |
|---|---|---|---|---|---|---|---|---|
| | កម្ពុជា | ភ្នំពេញ | ប្រជុំជនដទៃ | ជនបទដទៃ | កម្ពុជា | ភ្នំពេញ | ប្រជុំជនដទៃ | ជនបទដទៃ |
| វិទ្យុ | 43 | 41 | 45 | 42 | 33 | 34 | 28 | 33 |
| ទូរទស្សន៍ | 60 | 96 | 80 | 53 | 66 | 95 | 83 | 59 |
| ម៉ាញេ.ម៉ាស៊ីនចាក់សម្លេង* | 29 | 60 | 47 | 23 | 23 | 34 | 27 | 21 |
| ម៉ាញេស្តេរ៉េអូ | 14 | 40 | 16 | 10 | 5 | 19 | 4 | 3 |
| ទូរស័ព្ទដៃ | 44 | 93 | 70 | 35 | 83 | 96 | 90 | 80 |
| ផ្កាយរណប | 1 | 2 | 3 | 1 | 2 | 0 | 2 | 2 |
| កង់ | 68 | 45 | 61 | 71 | 61 | 42 | 60 | 64 |
| ម៉ូតូ | 49 | 86 | 67 | 43 | 66 | 90 | 74 | 61 |
| រថយន្ត | 4 | 20 | 8 | 2 | 5 | 20 | 9 | 2 |
| រថយន្តដឹកទំនិញ | 1 | 3 | 3 | 1 | 1 | 1 | 1 | 1 |
| កុំព្យូទ័រលើតុ | 3 | 25 | 7 | 1 | 6 | 28 | 11 | 2 |

## ភាពក្រីក្រ

**កំណើនសេដ្ឋកិច្ចខ្លាំងក្លាជានិរន្តរ៍ ក្នុងរយៈពេលពីរទសវត្សរ៍នេះ បានជះឥទ្ធិពលជាវិជ្ជមានយ៉ាងខ្លាំងលើការកាត់បន្ថយភាពក្រីក្រ និងការធ្លាក់ចុះនូវភាពក្រីក្រត្រូវបានគេរំពឹងថា នឹងបន្តសម្រាប់រយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។** លទ្ធផលនៃអង្កេតសង្គមកិច្ច-សេដ្ឋកិច្ចកម្ពុជាចុងក្រោយបំផុត បានពិភាក្សាចំណុចខាងលើដើម្បីបង្កើនការកាត់បន្ថយភាពក្រីក្រ រហូតដល់ឆ្នាំ 2014។ ផសស ក្នុងពលរដ្ឋម្នាក់ៗត្រូវបានរំពឹងថានឹងឡើងដល់ 1,145.1 ដុល្លាសហរដ្ឋអាមេរិក ក្នុងឆ្នាំ 2015 គឺកើនឡើង 5.6 ភាគរយ ពីកម្រិតដែលបានសង្កេតឃើញក្នុងឆ្នាំ 2014។

**ទោះយ៉ាងណាក្តី អត្រានៃភាពក្រីក្រតំបន់ជនបទ ត្រូវបានជឿថា នៅតែខ្ពស់ជាងតំបន់ទីក្រុង។** ខណៈដែលគ្រួសារនៅតាមជនបទ បានទទួលផលប្រយោជន៍នៃកំណើនក្នុងវិស័យកសិកម្ម នៅក្នុងរយៈពេល 2008-10 ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះកាន់តែច្រើន គ្រួសារទីក្រុងបានទទួលប្រយោជន៍ពីការពង្រីកវិស័យកាត់ដេរ និងសំណង់។ មានការរំពឹងថានឹងមានការកាត់បន្ថយបន្ថែមទៀតនូវភាពក្រីក្រ ទាំងគ្រួសារនៅទីក្រុង និងគ្រួសារនៅជនបទនៅទូទាំងឆ្នាំ 2015-2016 ។ សម្រាប់គ្រួសារនៅទីក្រុង លទ្ធភាពកាត់បន្ថយភាពក្រីក្រនេះកើតមានតាមរយៈវិស័យសេដ្ឋកិច្ចដែលពួកគេ ចូលរួម (ភាគច្រើនវិស័យសំណង់ និងសេវាកម្ម) ។ សម្រាប់គ្រួសារនៅជនបទ មានការកើនឡើងនូវប្រភពប្រាក់ចំណូលផ្សេងពីប្រាក់ចំណូល ដែលបានមកពីការងារដោយខ្លួនឯងក្រៅពីកសិកម្ម។

**គ្រួសារកម្ពុជានៅតែងាយរងគ្រោះខ្លាំង។** ភាពជោគជ័យកាលពីពេលថ្មីៗ ក្នុងកាត់បន្ថយភាពក្រីក្រធ្វើឲ្យគ្រួសារជាច្រើនកំពុងរស់នៅត្រឹមតែខាងលើបន្ទាត់នៃភាពក្រីក្រប៉ុណ្ណោះ។ ផលប៉ះពាល់នៃភាពអវិជ្ជមាន (ដូចជាគ្រោះរាំងស្ងួត ភាពរឹករវក្នុងតំបន់ ជាដើម) មកលើគ្រួសារក្រីក្រកាន់តែមានសភាពធ្ងន់ឡើង ដោយសារតែប្រព័ន្ធការពារសង្គមមានកម្រិត។

## វិស័យក្រៅប្រទេស

**ស្ថានភាពក្រៅប្រទេសរបស់កម្ពុជា នៅតែមានស្ថិរភាពដែលទ្រទ្រង់ដោយលំហូរចូលវិនិយោគផ្ទាល់ពីបរទេសមានសុខភាពល្អប្រសើរ។** ក្នុងឋានៈជាអ្នកនាំចូលប្រេងកម្ពុជាទទួលបានប្រយោជន៍ពីការធ្លាក់ចុះថ្លៃប្រេងដែលមានឥទ្ធិពលវិជ្ជមានចំពោះឱនភាពគណនីចរន្ត។ ថ្លៃប្រេងទាប រួមជាមួយនឹងការនាំចេញដែលត្រូវបានធ្វើឲ្យប្រសើរឡើង ធ្វើឱ្យឱនភាពគណនីចរន្តរួមតូច ដែលបានធ្លាក់ចុះដល់ 10.8 ភាគរយ នៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ 2015 ធៀបនឹងការប៉ាន់ស្មានក្រោយបានកែសម្រួលស្មើនឹង 11.9 ភាគរយនៃ ផសស ។ ឱនភាពនេះត្រូវបានហិរញ្ញប្បទាន ដោយលំហូរចូលនៃវិនិយោគផ្ទាល់ពីបរទេសយ៉ាងច្រើនប្រហែល 10 ភាគរយ នៃផលិតផលក្នុងស្រុកសរុបនៅក្នុងអំឡុងឆ្នាំ 2012-15 (រូបភាពទី 12) ។ លំហូរចូលវិនិយោគផ្ទាល់ពីបរទេសដែលមានសុខភាពល្អ ហើយការនាំចេញសម្លៀកបំពាក់យ៉ាងច្រើនធ្វើឲ្យទុនបម្រុងអន្តរជាតិដុលកើនឡើងពី 4.6 ពាន់លានដុល្លាអាមេរិកក្នុងឆ្នាំ 2014ដល់ 5.6 ពាន់លានដុល្លាអាមេរិក (ឬការនាំចូលដែលមានរយៈពេល4.4ខែ) នៅចុងឆ្នាំ 2015 ។

**រូបភាពទី 12: លំហូរចូលវិនិយោគផ្ទាល់ពីបរទេសមានសុខភាពល្អបន្តផ្តល់ហិរញ្ញប្បទានចំពោះឱនភាពគណនីចរន្ត។** ជញ្ជីងពាណិជ្ជកម្ម សមតុល្យគណនីចរន្ត និងវិនិយោគផ្ទាល់ពីបរទេស (ភាគរយនៃផសស)




ប្រភពៈ ការប៉ាន់ស្មានរបស់អាជ្ញាធរនិងបុគ្គលិកធនាគារ
e = ប៉ាន់ស្មាន

## ក). ការនាំចេញ

**ដូចដែលបានពិភាក្សានៅក្នុងវិស័យពិត(ផលិត)ខាងលើ ការនាំទំនិញចេញបានបង្កើនល្បឿនកើនឡើង ក្នុងឆ្នាំ 2015 ដែលជំរុញដោយកំណើនខ្ពស់នៅក្នុងការនាំចេញសម្លៀកបំពាក់ និងស្បែកជើង ព្រមទាំងការបន្តនាំចេញកៅស៊ូ។** គាំទ្រដោយស្ថិរភាពទីផ្សារការងារល្អ និងដោយការប្តូរបន្តិចម្តងៗទៅរកផលិតផលដែលមានតម្លៃបន្ថែមខ្ពស់ជាង ការនាំចេញសម្លៀកបំពាក់ និងស្បែកជើងបានកើនឡើងនូវបរិមាណទឹកប្រាក់ក្នុងអត្រាកំណើន 12.3 ភាគរយ និង 40.0 ភាគរយ នៅឆ្នាំ 2015 ធៀបនឹង 9.2 ភាគរយ និង 30.7 ភាគរយ រៀងគ្នា នៅឆ្នាំ 2014 ។ កំណើនក្នុងការនាំចេញសរុប បានកើនឡើងដល់ 15 ភាគរយ ក្នុងឆ្នាំ 2015 ធៀបទៅនឹង 7.5 ភាគរយ នៅក្នុងឆ្នាំ 2014 រួមចំណែកធ្វើឲ្យសមតុល្យគណនីបច្ចុប្បន្ន រួមតូច។

## ខ).ការនាំចូល

**កំណើននាំចូលនៅ ត្រូវបានជំរុញដោយតម្រូវការក្នុងស្រុកយ៉ាងច្រើន សម្រាប់ទាំងការវិនិយោគ និងការប្រើប្រាស់។** ខណៈពេលដែលនៅតែរឹងមាំ កំណើននៃការនាំចូលបានធ្លាក់ចុះពី 11.9 ភាគរយ នៅឆ្នាំ 2014 មកត្រឹម 10.5 ភាគរយ ក្នុងឆ្នាំ 2015 ធៀបនឹងឆ្នាំមុន។ សន្ទុះរីកចំរើននៃវិស័យសំណង់ បានរួមចំណែកដល់កំណើនការនាំចូលសម្ភារៈសំណង់ ចំណែកឯការធ្លាក់ចុះថ្លៃប្រេងបច្ចុប្បន្នកំពុងទ្រទ្រង់ដល់កំណើនតម្រូវការនាំចូលប្រេង និងនាំចូលរថយន្ត (រូបទី 13) [10]។ សម្ពាធតម្រូវការក្នុងស្រុកក៏ជំរុញការនាំចូលទំនិញ ជាពិសេសអាហារ និងភេសជ្ជៈ។ ការនាំចូលអាហារ និងភេសជ្ជៈបានកើនឡើងបន្ថែមទៀត គឺកើនឡើង 64 ភាគរយ ក្នុងឆ្នាំ 2015 ធៀបនឹងឆ្នាំមុន។

**រូបទី 13: ខណៈពេលដែលការនាំចូលយានយន្តកើនឡើងដោយសារកំណើនតម្រូវការក្នុងស្រុក ការនាំចូលប្រេងឥន្ទនៈថយចុះ ខណៈថ្លៃប្រេងធ្លាក់ចុះ។** (លានដុល្លាសហរដ្ឋអាមេរិក)




ប្រភពៈ អាជ្ញាធរកម្ពុជា

## អតិផរណា

**ជាលទ្ធផលនៃការកើនឡើង នូវតម្រូវការក្នុងស្រុក សម្ពាធអតិផរណាបានកើនឡើង។** អតិផរណាបានកើនឡើងដល់ 2.3 ភាគរយ នៅខែកុម្ភៈឆ្នាំ 2016 ធៀបនឹង 1.2 ភាគរយនៅចុងឆ្នាំ 2014 (រូបទី 14) ។ ភាគច្រើនជំរុញដោយសម្ពាធតម្រូវការក្នុងស្រុក ការកើនឡើងនូវអនុសន្ទស្សន៍ម្ហូបអាហារ ភោជនីយដ្ឋាន សុខភាព និងគ្រឿងសង្ហារឹម បានជំរុញអតិផរណាឲ្យកើនឡើងចាប់តាំងពីត្រីមាសទីបួននៃឆ្នាំ 2015។ អនុសន្ទស្សន៍មួយចំនួនផ្សេងទៀត ដូចជា អនុសន្ទស្សន៍ទាក់ទងនឹងផ្ទះ ទឹក ភ្លើងនិងការដឹកជញ្ជូន នៅតែមានកម្រិតអវិជ្ជមាន ។

[10] មុខទំនិញនាំចូលសំខាន់មួយទៀតគឺក្រណាត់សម្រាប់ផលិតសម្លៀកបំពាក់ដែលស្ទើរតែសម្រាប់នាំចេញទាំងស្រុង

**រូបទី 14: អតិផរណាបានកើនឡើងបន្តិចដោយសារតែការកើនឡើងនូវថ្លៃស្បៀងអាហារ ថ្លៃទំនិញ និងថ្លៃសេវាផ្សេងទៀត (ភោជនីយដ្ឋាន សុខភាព និងគ្រឿងសង្ហារឹម)** ។ ការរួមចំណែកអតិផរណា 12 ខែ (ភាគរយ)




ប្រភព: អាជ្ញាធរកម្ពុជា

**ទោះជាស្បៀងអាហារនិងប្រេងឡើងថ្លៃក្តី អតិផរណាក្នុងតំបន់មានលក្ខណៈចម្រុះ។** អតិផរណានៅប្រទេសថៃ និងសិង្ហបុរី បានប្រែទៅជាអវិជ្ជមាននៅពាក់កណ្តាល ឆ្នាំ 2015 (រូបទី 15) ។ ប៉ុន្តែអតិផរណានៅកម្ពុជា ចិន និងម៉ាឡេស៊ីបានកើនឡើងបន្តិច។

**រូបភាពទី 15: អតិផរណាក្នុងតំបន់មានលក្ខណៈចម្រុះ។ អតិផរណានៅប្រទេសមួយចំនួន ពោលគឺ កម្ពុជា ចិន និង ម៉ាឡេស៊ីបានកើនឡើង។** (បំរែបំរួលជា % ធៀបនឹងឆ្នាំមុន)




ប្រភព: ការិយាល័យស្ថិតិរបស់បណ្តាប្រទេសក្នុងតំបន់

## វិស័យរូបិយវត្ថុ

### ក). រូបិយវត្ថុសរុប អត្រាការប្រាក់និងអត្រាប្តូរប្រាក់

**កំណើនរូបិយវត្ថុទូទៅ បានធ្លាក់ចុះទោះបីជាការពង្រីកយ៉ាងឆាប់រហ័សនៃវិស័យហិរញ្ញវត្ថុបន្តទៀតដើម្បីតម្រូវទៅតាមកំណើនសេដ្ឋកិច្ចក្តី។** ដោយសារតែការធ្លាក់ចុះនៃកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស រូបិយវត្ថុទូទៅបានធ្លាក់ចុះមកត្រឹម 14.7 ភាគរយ នៅខែមិថុនាឆ្នាំ 2015 ធៀបនឹង 29.9 ភាគរយ នៅឆ្នាំ 2014 (រូបភាពទី 16) ។ មួយផ្នែកគឺដោយការមានការថយចុះបរិមាណសាច់ប្រាក់ងាយស្រួលនៅលើសកលលោក ត្បិតមានការរំពឹងថាសហរដ្ឋអាមេរិកនឹងបង្កើនការប្រាក់។ ក្នុងអំឡុងពេលដូចគ្នានេះ ការរួមចំណែករបស់ប្រាក់បញ្ញើបច្ចុប្បន្នពីបរទេសចំពោះរូបិយវត្ថុទូទៅ បានធ្លាក់ចុះពី 25.1 ភាគរយ ក្នុងឆ្នាំ 2014 មកត្រឹម 8.3 ភាគរយ ក្នុងឆ្នាំ 2015 ។

**រូបភាពទី 16: កំណើនផ្គត់ផ្គង់សាច់ប្រាក់ទូទៅធ្លាក់ចុះខណៈដែលប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសបានធ្លាក់ចុះ។** ការរួមចំណែកដល់កំណើនផ្គត់ផ្គង់សាច់ប្រាក់ទូទៅ (បំរែបំរួលគិតជា % ធៀបនឹងឆ្នាំមុន)




ប្រភព: អាជ្ញាធរកម្ពុជា

**ប្រាក់បញ្ញើរូបិយប័ណ្ណបរទេសមានកំណើនទាប អាចនឹងមានសម្ពាធមួយចំនួនលើការផ្តល់ប្រាក់កម្ចី និងលើអត្រាការប្រាក់បញ្ញើ ដែលបានកើនឡើងចាប់តាំងពីដើមឆ្នាំ 2015** (រូបទី 17) ។ ជាមធ្យម អត្រាការប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិករយៈពេល 12 ខែ បានកើនឡើងដល់ 4.45 ភាគរយ ក្នុងឆ្នាំ 2015 គឺកើនឡើងពី 4.3 ភាគរយ ក្នុងឆ្នាំ 2014 ខណៈពេលដែលអត្រាការប្រាក់កម្ចីប្រាក់ដុល្លារអាមេរិករយៈពេល 12 ខែ បានកើនឡើងពី 11.54 ភាគរយ ដល់ 11.61 ភាគរយ ក្នុងរយៈពេលដូចគ្នានេះ។ គម្លាតអត្រាការប្រាក់ ដែលជាភាពខុសគ្នារវាងអត្រាការផ្តល់ប្រាក់កម្ចី និងអត្រាការប្រាក់បញ្ញើ បានថយចុះបន្តិចគឺថយចុះពី 7.24 ភាគរយ នៅក្នុងឆ្នាំ 2014 មកត្រឹម 7.16 ភាគរយ ក្នុងឆ្នាំ 2015 ដែលកំណើនអត្រាការ

ប្រាក់កម្ចីមានកម្រិតខ្ពស់ កំណើនអត្រាការប្រាក់បញ្ញើ។ ទោះជាយ៉ាងណាក្តីគម្លាតអត្រាការប្រាក់ នៅតែមានទំហំធំ។

**រូបភាពទី 17: ប្រាក់បញ្ញើរយៈពេល 12 ខែ និងអត្រាការប្រាក់ផ្តល់ប្រាក់កម្ចី**




ប្រភព: អាជ្ញាធរកម្ពុជា

**ស្ថិរភាពថ្លៃជារួមនៅតែទ្រទ្រង់ ដោយប្រាក់រៀលកម្ពុជាដែលមានស្ថិរភាព ធៀបនឹងអត្រាប្តូរប្រាក់ដុល្លាអាមេរិក។** ប្រាក់រៀលឡើងថ្លៃបន្តិច ឡើងដល់ 4,008 រៀលក្នុងមួយដុល្លាសហរដ្ឋអាមេរិកក្នុងខែកុម្ភៈឆ្នាំ 2016 ធៀបនឹង 4,075 ប្រាក់ដុល្លារក្នុងមួយដុល្លារអាមេរិកក្នុងខែធ្នូ ឆ្នាំ 2014។ ប្រាក់រៀលក៏បន្តឡើងថ្លៃធៀបនឹងប្រាក់បាតថៃ (និងប្រាក់ដុងវៀតណាម) ផងដែរគឺឡើងដល់ដល់ 114.9 រៀលក្នុងមួយបាតក្នុងខែកុម្ភៈ ឆ្នាំ 2016 ធៀបនឹង 125.3 រៀលក្នុងមួយបាតក្នុងខែធ្នូ ឆ្នាំ 2014 (រូបភាពទី 18)។

**រូបភាពទី 18: ប្រាក់រៀលបានបន្តឡើងថ្លៃធៀបនឹងប្រាក់បាត និងប្រាក់ដុង ហើយឥឡូវកំពុងឡើងថ្លៃធៀបនឹងប្រាក់ដុល្លាសហរដ្ឋអាមេរិក**




ប្រភព: អាជ្ញាធរកម្ពុជា

**អត្រាប្តូរប្រាក់ជាក់ស្តែង (NEER) និងអត្រាប្តូរប្រាក់ខ្វែងពិត (REER) បានឡើងថ្លៃក្នុងឆមាសទីពីរនៃឆ្នាំ 2015។** សន្ទស្សន៍អត្រាប្តូរប្រាក់ជាក់ស្តែង (2010 = 100) បានកើនឡើងពី 106.7 ក្នុងខែធ្នូ ឆ្នាំ 2014 ដល់ 113.8 ក្នុងខែមករា ឆ្នាំ 2016 ខណៈពេលដែលសន្ទស្សន៍អត្រាប្តូរប្រាក់ខ្វែងពិត (2010 = 100) បានកើនឡើងពី 113.1 នៅក្នុងខែធ្នូ ឆ្នាំ 2014 ដល់ 122.9 ក្នុងខែមករា ឆ្នាំ 2016។ ការឡើងថ្លៃនេះធ្វើឲ្យ មានសម្ពាធមកលើជញ្ជីងទូទាត់ និងកំណើន។

## ខ). វិស័យធនាគារ

**បន្តការពង្រឹងហិរញ្ញវត្ថុស៊ីជំរៅយ៉ាងឆាប់រហ័ស។** កំណើនឥណទានក្នុងវិស័យឯកជន នៅតែមានកម្រិតខ្ពស់ ក្នុងកម្រិត 27 ភាគរយ ធៀបនឹងឆ្នាំមុន ឬស្មើនឹង 9,8 ពាន់លានដុល្លាសហរដ្ឋអាមេរិក នៅជំណាច់ឆ្នាំ 2015 ធៀបនឹង 24.8 ភាគរយ នៅចុងឆ្នាំ 2014 (រូបទី 19) ។ ប៉ុន្តែ កំណើនប្រាក់បញ្ញើនៃវិស័យឯកជនបានធ្លាក់ចុះពាក់កណ្តាល គឺធ្លាក់ពី 30.6 ភាគរយ នៅចុងឆ្នាំ 2014 មកត្រឹម 16.6 ភាគរយ ធៀបនឹងឆ្នាំមុន ឬត្រឹម 10.3 ពាន់លានដុល្លាអាមេរិកក្នុងខែមិថុនា ឆ្នាំ 2015 ។ ដូច្នេះ អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើបានកើនឡើង ដល់ 95.6 ភាគរយ។ ចំពោះការពិភាក្សាលម្អិតបន្ថែមទៀតអំពី *"Recent Developments of the Financial sector: Opportunities and Risks (កិច្ចអភិវឌ្ឍន៍ថ្មីៗនៃវិស័យហិរញ្ញវត្ថុៈឱកាស និងហានិភ័យ)"* សូមមើលផ្នែកប្រធានបទពិសេសខាងក្រោមនេះ។

**ការធ្លាក់ចុះប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសអាចគោរពតាមស្ថានភាពក្រៅប្រទេស។** ជាមួយនឹងសេដ្ឋកិច្ចដុល្លារូបនីយកម្មកម្រិតខ្ពស់របស់ខ្លួន និងជាមួយនឹងការនាំចេញទៅសហរដ្ឋអាមេរិកចំនួនមួយភាគបី ប្រទេសកម្ពុជាហាក់ដូចជាបានរងឥទ្ធិពល នៃគោលនយោបាយរូបិយវត្ថុ និងវដ្តធុរកិច្ចរបស់សហរដ្ឋអាមេរិក។ វដ្តសេដ្ឋ-កិច្ចរបស់ប្រទេសកម្ពុជាហាក់ដូចជាបានផ្លាស់ប្តូរស្របគ្នាជាមួយនឹងសេដ្ឋកិច្ចអាមេរិក។

**រូបទី19: ឥណទានបន្តមានកំណើនខ្ពស់ខណៈដែលកំណើនប្រាក់បញ្ញើថយចុះពាក់កណ្តាល ក្នុងឆ្នាំ 2015។** (បំរែបំរួលគិតជា % ធៀបនឹងឆ្នាំមុន)




ប្រភព: អាជ្ញាធរកម្ពុជា

**រូបទី 20: ឥណទាន និងនិក្ខេបលើវិស័យសំណង់ និងអចលនទ្រព្យ បានកើនឡើងបន្ថែមក្នុងឆ្នាំ 2015។** (ភាគរយនៃចំនួនសរុប)




ប្រភព: អាជ្ញាធរកម្ពុជា

**ចំណែកនៃឥណទានក្នុងស្រុកផ្តល់ទៅឱ្យវិស័យសំណង់ និងអចលនទ្រព្យបានកើនឡើងបន្ថែមទៀត ឡើងដល់ 20 ភាគរយនៃឥណទានក្នុងស្រុកសរុបក្នុងឆ្នាំ 2015** ធៀបនឹង 19 ភាគរយ (ឬ 1.8 ពាន់លានដុល្លា) ក្នុងឆ្នាំ 2014 (រូបលេខ 20)។ ទោះជាយ៉ាងណាក្តី ចំណែកនេះនៅតែទាបជាងកំណើនខ្ពស់បំផុត 23 ភាគរយ ក្នុងឆ្នាំ 2008 នៅមុនពេលមានវិបត្តិហិរញ្ញវត្ថុពិភពលោក នៅពេលដែលពពុះលំនៅដ្ឋាន នៅរាជធានីភ្នំពេញ ទីបំផុតបានបែកធ្លាយ។ ប៉ុន្តែ សភាពការណ៍នេះមានផលប៉ះពាល់តិចតួចមកលើសេដ្ឋកិច្ច និងមកលើវិស័យធនាគារ ព្រោះថានាពេលនោះវិស័យសំណង់ និងអលនទ្រព្យបានទទួលហិរញ្ញប្បទានមួយផ្នែកធំពី បរទេស។

**ការពង្រឹកវិស័យធនាគារបន្តដាក់សម្ពាធលើទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារ។** បច្ចុប្បន្ននេះ កំណើនបំណុលបរទេសមានទំហំហួសពីអាចកាត់កងបាន នូវកំណើនទ្រព្យសកម្មបរទេស (រូបភាពទី 21)។ នៅក្នុងទិដ្ឋភាពនេះ ធនាគារកណ្តាលបានតម្រូវឲ្យដាក់ទុនបម្រុង 12.5 ភាគរយចំពោះការខ្ចីពីបរទេស។

ដើម្បីពង្រឹងវិស័យធនាគារបន្ថែមទៀត អនុបាតស្តីពីការគ្របដណ្តប់សាច់ប្រាក់ងាយស្រួល ហើយអ្វីដែលសំខាន់ជាងនេះ គឺប្រកាសណែនាំថ្មីៗចុះថ្ងៃទី 22 មីនា 2016 ស្តីពីទុនចុះបញ្ជីអប្បបរមារបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ដែលចេញដោយធនាគារកណ្តាល ត្រូវបានដាក់ឲ្យអនុវត្ត។ ប្រកាសនោះបានចែងថាកិច្ចតម្រូវថ្មីអំពីទុននេះ (តារាងទី 11) ត្រូវអនុវត្តតាមក្នុងរវាងរយៈពេលពីរឆ្នាំនៃការចុះហត្ថលេខា។

**តារាង 11: ទុនភាគព្វកិច្ចអប្បបរមា** (សមមូលនឹងលានដុល្លាសហរដ្ឋអាមេរិក)

| ប្រភេទគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ | ទុនភាគព្វកិច្ច | |
|---|---|---|
| | ពីមុន | ថ្មី |
| ធនាគារពាណិជ្ជចុះបញ្ជីក្នុងស្រុក | 37.5 | 75 |
| បុត្រសម្ព័ន្ធធនាគារបរទេស | 12.5 | 75 |
| បុត្រសម្ព័ន្ធធនាគារបរទេសលំដាប់វិនិយោគ | 12.5 | 50 |
| ធនាគារឯកទេស | 7.5 | 15 |
| មីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | 2.5 | 30 |
| មីក្រូហិរញ្ញវត្ថុ | 0.625 | 1.5 |

ប្រភព: អាជ្ញាធរកម្ពុជា

**ដោយមានលំហូរចូលវិនិយោគផ្ទាល់ពីបរទេស និងមានការនាំចេញ ទុនបម្រុងអន្តរជាតិសរុបរបស់ធនាគារកណ្តាលបានកើនដល់ 5.6 ពាន់លានដុល្លារអាមេរិក** (ឬអាចនាំចូល 4ខែ) នៅចុងឆ្នាំ 2015[11]។ តួលេខនេះធៀបជាមួយ 4,4 ពាន់លានដុល្លាអាមេរិកនៅចុងឆ្នាំ 2014។

**រូបភាពទី 21: ទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារធ្លាក់ចុះដោយសារកំណើនបំណុលបរទេសមានទំហំលើសពីអាចកាត់កងកំណើនទ្រព្យសកម្មបរទេស។** (លានដុល្លារអាមេរិក)




សំគាល់: FC: រូបិយប័ណ្ណបរទេស GIR: ទុនបំរុងអន្តរជាតិសរុប NFA: ទ្រព្យសកម្មបរទេសសុទ្ធ DMB: ធនាគារទទួលប្រាក់បញ្ញើជារូបិយវត្ថុ
ប្រភព: អាជ្ញាធរ

## វិស័យសារពើពន្ធ

**ការពង្រឹងសារពើពន្ធគាំទ្រស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការរួមចំណែកដល់ការបង្កើនប្រាក់បញ្ញើរបស់ រាជរដ្ឋាភិបាល។** ទោះបីជាសេដ្ឋកិច្ចធ្លាក់ចុះបន្តិចក្តី ការលើកកម្ពស់ក្នុងការគ្រប់គ្រងចំណូល បានជំរុញការប្រមូលចំណូលក្នុងស្រុក ដែលត្រូវបានប៉ាន់ស្មានថាបានឡើងដល់ 17.5 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2015។ ចំណាយសរុបត្រូវបានរក្សាក្នុងកម្រិត 20.5 ភាគរយ នៃ ផលិតផលក្នុងស្រុកសរុប ខណៈដែលការកើនឡើងប្រាក់ខែក្នុងវិស័យសាធារណៈ ត្រូវបានកាត់កងដោយការធ្លាក់ចុះនៃក្នុងចំណាយមូលធន។ ស្ថានភាពនេះធ្វើឱ្យប្រសើរឡើងនូវឱនភាពសារពើពន្ធរួម (រាប់ទាំងជំនួយឥតសំណង) ចំនួន 0.8 ភាគរយ នៃ ផសស នៅឆ្នាំ 2015 ធៀបនឹង 1.4 ភាគរយ ក្នុងឆ្នាំ 2014 (រូបភាពទី 25) ។ ការដាក់ឲ្យប្រើប្រាស់ថវិកាផ្អែកលើកម្មវិធីពេញលេញ ចាប់តាំងពីឆ្នាំ 2015 បានគាំទ្រចំណងទាក់ទងរវាងថវិកា និងគោលនយោបាយ និងការធ្វើឱ្យប្រសើរឡើងគណនេយ្យភាពនិងលទ្ធផល។ អង្គភាពផ្តល់សេវាជាពិសេស សាលារៀនត្រូវបានចាត់ថ្នាក់ថាជាអង្គភាពថវិកា បានចាប់ផ្តើមទទួលមូលនិធិដោយផ្ទាល់ពីថ្នាក់ជាតិ ហើយទទួលខុសត្រូវចំពោះមូលនិធិដែលពួកគេគ្រប់គ្រង។ ទោះជាយ៉ាងណាក្តី បញ្ហាប្រឈមដំបូង ក្នុងការអនុវត្តថវិកាផ្អែកលើកម្មវិធី បានធ្វើឲ្យការបើកប្រាក់ចំណាយយឺតយ៉ាវក្នុងអំឡុងឆមាសទីមួយនៃឆ្នាំ 2015។

### ក). សមាសភាពចំណូល

**ប្រាក់ចំណូលបន្តទទួលលទ្ធផលល្អជាខ្លាំង លើសផែនការ ដែលមានចែងក្នុងយុទ្ធសាស្ត្រប្រមូលប្រាក់ចំណូល 2014-18 (RMS) ។** ចំណូលពន្ធបានកើនឡើងប្រមាណជា 10 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2010 ដល់ 15.1 ភាគរយ ក្នុងឆ្នាំ 2015 ជាអាទិ៍ ដោយសារការធ្វើឱ្យប្រសើរឡើងនូវយន្តការអនុវត្តន៍ និងសវនកម្ម ដែលបានកំណត់ នៅក្នុងយុទ្ធសាស្ត្រប្រមូលប្រាក់ចំណូល។ នៅពេលរួមបញ្ចូលទាំងចំណូលមិនមែនពន្ធ ការប្រមូលចំណូលសរុបមានចំនួនប្រមាណជា 17.5 ភាគរយ នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ 2015 គឺទាបជាងបន្តិចធៀបនឹងចំណូលដែលប្រមូលបានក្នុង 2014 (រូបភាពទី 22)។

[11] រួមមានរូបិយបណ្ណបរទេសទាំងអស់ រាប់ទាំងប្រាក់យាន់របស់ចិនដែលត្រូវបានប្រើជារូបិយបណ្ណបម្រុង

**រូបភាពទី 22: ជាលទ្ធផលនៃការធ្វើឱ្យប្រសើរឡើងនូវផ្នែករដ្ឋបាលប្រាក់ចំណូលក្នុងស្រុកបានកើនឡើងយ៉ាងច្រើនចាប់តាំងពីឆ្នាំ 2014** ។ប្រាក់ចំណូលទូទៅរបស់រដ្ឋាភិបាល។ (ភាគរយនៃផសស)




b=ថវិកា e=ប៉ាន់ស្មាន

ប្រភព: ការប៉ាន់ស្មានរបស់អាជ្ញាធរនិងបុគ្គលិកធនាគារ

**សមាសភាគនៃការប្រមូលប្រាក់ចំណូលហាក់ដូចជាធ្វើដំណើរយឺតៗ ឆ្ពោះទៅរកការកើនឡើងនៃពន្ធផ្ទាល់។** ការកើនឡើង ក្នុងការប្រមូលពន្ធដោយផ្ទាល់ត្រូវបានសង្កេតឃើញក្នុងឆ្នាំ 2015 ខណៈដែលការប្រមូលចំណូលដែលទាក់ទងនឹងការធ្វើពាណិជ្ជកម្ម បានធ្លាក់ចុះតាមកិច្ចតម្រូវ ក្រោមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន។

**ការប្រៀបធៀបក្នុងតំបន់បានបង្ហាញថាកម្ពុជា ប្រមូលប្រាក់ចំណូលបានល្អ នៅពេលដែលប្រៀបធៀបជាមួយនឹងប្រទេសជិតខាងមួយចំនួន** (រូបទី 23)។ ប្រទេសកម្ពុជាបានប្រមូលប្រាក់ចំណូលបានល្អប្រសើរ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ និងបានបង្ហាញកម្រិតបច្ចុប្បន្ន ស្រដៀងគ្នា ទៅនឹងនៃបណ្តាប្រទេសអាស៊ានផ្សេងទៀត។ ទាក់ទងនឹងផលិតផលក្នុងស្រុកសរុប ប្រទេសកម្ពុជាបានប្រមូលប្រាក់ចំណូល ក្នុងឆ្នាំ 2014 បានច្រើនជាងប្រទេសហ្វីលីពីននិងឡាវបានប្រមូលក្នុងឆ្នាំ2012 (ផ្អែកលើទិន្នន័យប្រាក់ចំណូលថ្មីបំផុតដែលមាន)។

**រូបភាពទី 23: ការប្រមូលប្រាក់ចំណូលរបស់ប្រទេសកម្ពុជាមានសភាពល្អប្រសើរធៀបនឹងប្រទេសជិតខាង។** ប្រាក់ចំណូលមិនរួមបញ្ចូលជំនួយឥតសំណងឡើយ (ភាគរយនៃ ផសស ឆ្នាំ 2012)




ប្រភព: World Develoment Indicators

**ឥឡូវនេះធនាគារពិភពលោកបានចូលរួមក្នុងការពង្រឹងរដ្ឋបាលប្រាក់ចំណូលនៅតាមទីភ្នាក់ងារប្រាក់ចំណូលសំខាន់ៗមួយចំនួន** ជាពិសេស នៅអគ្គនាយកដ្ឋានពន្ធដារ។ នេះជាការគាំទ្របន្ថែម ក្នុងការធ្វើកំណែទម្រង់រួមនៃហិរញ្ញវត្ថុសាធារណៈ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បច្ចុប្បន្ន ការគាំទ្ររបស់ធនាគារពិភពលោកផ្តោតលើការគ្រប់គ្រងដែល ផ្តោតលើការគ្រប់គ្រងអនុលោមភាព រួមបញ្ចូលទាំងការផ្តល់សេវាដល់អ្នកជាប់ពន្ធ និងសវនកម្មពន្ធផងដែរ។

## ខ). សមាសភាពចំណាយ

បង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា និងសម្រេចឲ្យបាននូវការអភិវឌ្ឍសេដ្ឋកិច្ច ដែលមានតុល្យភាពបន្ថែមទៀត។ ក្រសួងភាគច្រើន បន្តពឹងផ្អែកលើម្ចាស់ជំនួយក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ ចំណែកឯសមត្ថភាពក្នុងការកសាងដោយខ្លួនឯងរបស់ពួកគេ នៅតែមានកម្រិតនៅឡើយ។

**រូបភាពទី 24: ការកើនឡើងនូវបញ្ជីប្រាក់ខែត្រូវបានកាត់កងដោយការធ្លាក់ចុះនៃការវិនិយោគដែលទទួលហិរញ្ញប្បទានពីបរទេស តាមរយៈការកាត់បន្ថយចំណាយរួមៗ** ចំណាយរបស់រាជ (ភាគរយៃនផសស)




b=ថវិកា e=ប៉ាន់ស្មាន
ប្រភព: ការប៉ាន់ស្មានរបស់អាជ្ញាធរនិងបុគ្គលិកធនាគារ

**ដើម្បីទប់ទល់នឹងនិន្នាការនេះ អាជ្ញាធរនានាកំពុងរៀបចំផែនការបង្កើនវិនិយោគ ដែលផ្តល់ហិរញ្ញប្បទានដោយវិស័យសាធារណៈ។** មូលធនដែលហិរញ្ញប្បទានក្នុងស្រុក ពិសេស ប្រតិបត្តិការ និងការថែរក្សា បានកើនឡើងពី 1.9 ភាគរយនៃ ផសស ក្នុងឆ្នាំ 2014 មកត្រឹម 2.3 ភាគរយ នៅឆ្នាំ 2015 ហើយត្រូវបានប្រមើលទុកថានឹងកើនឡើងបន្ថែមទៀតក្នុងថវិកាឆ្នាំ2016។ រាជរដ្ឋាភិបាលក៏កំពុងពិនិត្យមើលឡើងវិញ នូវនីតិវិធីគ្រប់គ្រងវិនិយោគសាធារណៈ ក៏ដូចជាពិនិត្យឡើងវិញនូវច្បាប់សម្បទាន ដើម្បីឱ្យមានក្របខណ្ឌរឹងមាំបំផុតសម្រាប់ទាំងការវិនិយោគសាធារណៈ និងភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។

## គ). សមតុល្យសារពើពន្ធ

**ការប្រមូលប្រាក់ចំណូលបានច្រើន និងការកាត់បន្ថយចំណាយសរុប ធ្វើឲ្យឱនភាពសារពើពន្ធសរុបរួមតូច (រាប់ទាំងជំនួយឥតសំណង) ត្រូវបានប៉ាន់ប្រមាណថាស្មើ 0.8 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2015។** បរិមាណនេះធៀបនឹង 1.4 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2014។ បើមិនគិតជំនួយឥតសំណង ឱនភាពសារពើពន្ធសរុប ក៏រួមត្រឹម 3.0 ភាគរយ នៃ ផសស ធៀបនឹង 3.8 ភាគរយនៃ ផសស ក្នុងឆ្នាំ 2014 ។ ឱនភាពសារពើពន្ធបន្តទទួលហិរញ្ញប្បទានពីមូលនិធិមកពីបរទេស។

**ការកើនឡើងនូវប្រាក់ចំណូលក្នុងស្រុកបានបន្ត ដើម្បីបង្កលក្ខណៈឱ្យរដ្ឋាភិបាលបង្កើនប្រាក់បញ្ញើ។** ប្រាក់បញ្ញើបានកើនឡើងដល់ 9.0 ភាគរយ នៃផលិតផលក្នុងស្រុកសរុប ឬ 1.6 ពាន់លានដុល្លា នៅចុងឆ្នាំ 2015 ។ការបង្កើនប្រាក់បញ្ញើរបស់រដ្ឋាភិបាលផ្តល់លទ្ធភាពឲ្យរាជរដ្ឋាភិបាលអាចប្រើក្នុងអំឡុងពេលដែលមានវិបត្តិមួយ។ កាលពីមុន កម្ពុជាបានដាក់ឲ្យប្រើប្រាស់នូវការជំរុញផ្នែកសារពើពន្ធ មានចំនួនប្រហែល 2 ភាគរយនៃ ផសស ក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុពិភពលោកឆ្នាំ 2008-09 ។ គោលនយោបាយសារពើពន្ធមួយផ្នែកធំជាឧបករណ៍គោលនយោបាយតែមួយគត់ ក្នុងការរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងដើម្បីកាត់បន្ថយវិបត្តិ ដោយសារគោលនយោបាយរូបិយវត្ថុរបស់កម្ពុជាជួបការលំបាក ព្រោះតែដុល្លារូបនីយកម្មមានកម្រិតខ្ពស់ ។

**រូបភាពទី 25: ឱនភាពសារពើពន្ធបានល្អប្រសើរដោយសារកិច្ចខិតខំប្រឹងប្រែងពង្រឹងសារពើពន្ធ។** ឱនភាពសារពើពន្ធទូទៅរបស់រដ្ឋាភិបាល (ភាគរយនៃផលិតផលក្នុងស្រុកសរុប)




b=ថវិកា; e=ប៉ាន់ស្មាន
ប្រភព: ការប៉ាន់ស្មានរបស់អាជ្ញាធរនិងបុគ្គលិកធនាគារ

## ឃ). ថវិកាប្រចាំឆ្នាំសម្រាប់ឆ្នាំ 2016

**ថវិកាប្រចាំឆ្នាំ 2016 អាចត្រូវបានចែកប្រភេទជាថវិកាវិត្ថារកម្ម។** តាមន័យបច្ចេកទេសគេថា ការចំណាយសរុបសម្រាប់ឆ្នាំ 2016 ត្រូវបានរៀបចំថវិកាកើនឡើងដល់ 18,288 ពាន់លានរៀល ពោលគឺកើនឡើង 2,948 ពាន់លានរៀល ឬ 3.6 ភាគរយ នៃ ផសស ធៀបកម្រិតប៉ាន់ស្មានដែលបានបើកផ្តល់ចំនួន 15,340 ពាន់លានរៀល

នៅឆ្នាំ 2015។[12] នេះជាការកើនឡើងធំបំផុតក្នុងបណ្តាប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ (រូបភាពទី 26) ។ ក្នុងទឹកប្រាក់សរុបចំនួន 3.6 ភាគរយ នៃកំណើនផលិតផលក្នុងស្រុកសរុបចំណាយវិនិយោគ ចំណាយមិនមែនប្រាក់បៀវត្ស និងចំណាយប្រាក់បៀវត្សត្រូវបានបង្កើនរៀងគ្នាចំនួន 1.7 ភាគរយ 1.4 ភាគរយនិង 0.5 ភាគរយ នៃ ផសស ។ ចំណាយសរុបក្នុងថវិកាឆ្នាំ 2016 ស្មើនឹង 22.3 ភាគរយ នៃផលិតផលក្នុងស្រុកសរុប។

**រូបភាពទី 26: ការកើនឡើងនូវចំណាយសរុប ត្រូវបានរៀបចំជាថវិកាក្នុងឆ្នាំ 2016។** កំណើនថវិកាធៀបនឹងថវិកាអនុវត្តឆ្នាំមុន (លទ្ធផលអនុវត្តន៍ឆ្នាំ 2015 ជាតួលេខប៉ាន់ស្មាន) (ភាគរយនៃផលិតផលក្នុងស្រុកសរុប)




ប្រភព: ការប៉ាន់ស្មានរបស់អាជ្ញាធរនិងបុគ្គលិកធនាគារពិភពលោក

**ក្នុងថវិកាឆ្នាំ 2016 បញ្ជីប្រាក់ខែត្រូវបានរៀបចំតម្លើងថវិកាដល់កម្រិតខ្ពស់បំផុត ស្មើនឹង 7.2 ភាគរយ នៃ ផសស ។** ផ្អែកលើផែនការនៃការសម្រេចឲ្យបាននូវប្រាក់ខែគោលអប្បរមានៃវិស័យសាធារណៈចំនួន 1 លានរៀល (ឬសមមូលនឹង 250 ដុល្លាអាមេរិក) ក្នុងមួយខែ ក្នុងឆ្នាំ 2018 ចាំបាច់ត្រូវតាមដានម៉ត់ចត់នូវការបង្កើនថវិកាប្រាក់ខែប្រចាំឆ្នាំ[13]។

**សមាសភាគមិនមែនប្រាក់ខែ ទទួលបាននូវការបង្កើនធំបំផុតក្នុងឆ្នាំ 2016 ដែលត្រូវបានផ្តួចផ្តើមចាប់តាំងពីឆ្នាំ 2011 មក។** កំណើនសមាសភាគមិនមែនប្រាក់ខែ អាចជួយធានាបាននូវការចំណាយអាទិភាព រួមមាន ថវិកាប្រតិបត្តិការ និងថវិកាថែទាំ ត្រូវបានផ្តល់មូលនិធិបានគ្រប់គ្រាន់។ ប៉ុន្តែ គ្មានទិន្នន័យថវិកាលម្អិតដើម្បីបញ្ជាក់ឡើយ។

**ទោះជាយ៉ាងណាក្តី ថវិកាមូលធនសម្រាប់ឆ្នាំ 2016 នៅតែបន្តត្រូវបានកាត់បន្ថយ។** សមាសភាគដែលផ្តល់ហិរញ្ញប្បទានពីបរទេស (ផ្តល់ដោយដៃគូអភិវឌ្ឍន៍) ត្រូវបានគ្រោងថវិកាកាត់បន្ថយដល់ 4.7 ភាគរយ នៃ ផសស នៅឆ្នាំ 2016 គឺថយចុះពី 5.1 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2015។ ការធ្វើបែបនេះអាចនឹងបង្កឱ្យមានបញ្ហាប្រឈមនាពេលអនាគត ដោយហេតុថាគេត្រូវធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធជាបន្ទាន់ ដើម្បីបង្កើនភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជា និងសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចកាន់តែមានតុល្យភាព។

**ការប្រមូលចំណូលបានល្អ ត្រូវបានរំពឹងថានឹងបន្តទៅទៀតក្នុងឆ្នាំសារពើពន្ធ 2016 ។** ដូច្នេះ គេបានព្យាករណ៍ថាអាជ្ញាធរនឹងសម្រេចបានផែនការ 17.5 ភាគរយ នៃ ផសសក្នុងឆ្នាំ 2016 ដូចបានគ្រោងទុក។ ខណៈដែលថវិកាចំណូលក្នុងស្រុកសម្រាប់ក្នុងឆ្នាំសារពើពន្ធ 2016 ត្រូវបានគ្រោងចំនួន 17.5 ភាគរយ នៃ ផសគឺស្រដៀងគ្នាទៅនឹងកម្រិត នៃការប្រមូលចំណូលប៉ាន់ស្មានក្នុងឆ្នាំ 2015 ថវិកានេះមានចំនួនខ្ពស់ជាងយ៉ាងច្រើនធៀបនឹងកម្រិត 16.3 ភាគរយនៃផលិតផលក្នុងស្រុកសរុបដែលបានកំណត់នៅក្នុង RMS ។ ចំណូលសម្រាប់ឆ្នាំ 2016 នៅតែពឹងផ្អែកលើការបង់ពន្ធដោយប្រយោល ប៉ុន្តែគេគ្រោងឲ្យចំណែកនៃពន្ធដោយផ្ទាល់ ដែលមានទំហំធំជាង កើនឡើងដល់ 3.2 ភាគរយនៃផលិតផលក្នុងស្រុកសរុប (គឺកើនពី 2.8 ភាគរយ នៃផលិតផលក្នុងស្រុកសរុប ដែលបានគ្រោងក្នុងឆ្នាំ 2015) ។ ចំណូលមិនមែនសារពើពន្ធដែលមានចំនួន 2.26 ភាគរយនៃ ផសស ដែលបានគ្រោងថវិកាសម្រាប់ឆ្នាំ 2016 មានកម្រិតទាបជាងការរួមចំណែកចំនួន 2.4 ភាគរយ នៃផលិតផលក្នុងស្រុកសរុបដែលបានកំណត់នៅក្នុង RMS។

[12] កំណើនធៀបមានទំហំតិចជាងប្រសិនបើថវិកាបើកផ្តល់ជាក់ស្តែងសម្រាប់ឆ្នាំ 2015 មានចំនួនច្រើនជាងការប៉ាន់ស្មានថវិកាបើកផ្តល់ចំនួន 15,340 ពាន់លានរៀល។

[13] វេទិកាសាធារណៈស្តីពីច្បាប់ថវិកាឆ្នាំ 2015 (ផ្នែកហានិភ័យ និងបញ្ហាប្រឈម) ថ្ងៃទី 22 ខែធ្នូ ឆ្នាំ 2015 ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ដូច្នេះ ឱនភាពសារពើពន្ធរួមមានជំនួយឥតសំណងត្រូវបានគ្រោងថវិកាឲ្យឡើងដល់ 4.1 ភាគរយនៃ ផសស នៅឆ្នាំ 2016 ធៀបនឹង 0.8 ភាគរយ នៃផលិតផលក្នុងស្រុកសរុប ដែលបានប៉ាន់ស្មានសម្រាប់ឆ្នាំ 2015។** មួយផ្នែកធំគឺដោយសារការកើនឡើង នូវការគ្រោងថវិកាចំណាយសរុប រួមជាមួយនឹងការធ្លាក់ចុះនៃសមាសភាគជំនួយឥតសំណង។

**រូបភាពទី 27: ក្រសួងអប់រំ យុវជន និងកីឡាទទួលបាននូវការបង្កើនថវិកាឆ្នាំ 2016 ខណៈពេលដែលថវិកាក្រសួងសុខាភិបាលពុំមានការផ្លាស់ប្តូរធៀបនឹងផសស។** ថវិកាហិរញ្ញប្បទានដោយប្រភពក្នុងស្រុក (ភាគរយនៃផលិតផលក្នុងស្រុកសរុប)




ប្រភព: ការប៉ាន់ស្មានរបស់អាជ្ញាធរកម្ពុជា

b: ថវិកា

**វិភាជន៍ក្នុងវិស័យសង្គមបន្តប្រសើរឡើងក្នុងឆ្នាំ 2016។** ថវិកាហិរញ្ញប្បទានក្នុងស្រុកសម្រាប់ក្រសួងអប់រំយុវជន និងកីឡា បន្តកើនឡើង ដល់ 2.5 ភាគរយ នៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ 2016 (រូបភាពទី 27) ។ ទោះជាយ៉ាងណាក្តី ថវិកា ឆ្នាំ 2016 របស់ក្រសួងសុខាភិបាល នៅតែស្មើនៅ 1.4 ភាគរយ នៃ ផសស ខណៈដែលត្រូវបន្តពង្រឹងប្រសិទ្ធភាពចំណាយបន្ថែមទៀត។ ក្នុងន័យបច្ចេកទេស ថវិកាសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា បានកើនឡើងដល់ 2,069 ពាន់លានរៀល សមមូលនឹង 510 លានដុល្លាអាមេរិក (ឬមានកំណើន 29 ភាគរយ ធៀបនឹងឆ្នាំមុន) និងថវិកាសម្រាប់ក្រសួងសុខាភិបាល បានកើនឡើង 1,110 ពាន់លានរៀល សមមូលនឹង 274 លានដុល្លា(ឬកើនឡើង 8.4 ភាគរយ ធៀបនឹងឆ្នាំមុន) ។

**រូបភាពទី 28: ការដឹកជញ្ជូនមានចំណែកធំបំផុតនៃថវិកាមូលធន។** ថវិកាមូលធនតាមវិស័យក្នុងឆ្នាំ 2016 ។ (ភាគរយនៃ ផសស និងចំណែកភាគរយ)




ប្រភព: អាជ្ញាធរកម្ពុជា

**ចំណាំ**: វិស័យអប់រំនេះគ្របដណ្តប់ក្រសួងអប់រំ និងក្រសួងបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យកសិកម្មគ្របដណ្តប់ក្រសួងកសិកម្ម អភិវឌ្ឍជនបទ ធនធានទឹក និងក្រសួងបរិស្ថាន និងវិស័យដឹកជញ្ជូនមានរួមបញ្ចូលក្រសួងសាធារណៈការនិងដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**វិស័យដឹកជញ្ជូន នៅតែបន្តទទួលបានអាទិភាពខ្ពស់បំផុត ដែលបានស្រូបយកច្រើនជាងមួយភាគបីនៃថវិកាមូលធនសរុប។** វិស័យកសិកម្ម ថាមពល និងវិស័យសុខភាពជាវិស័យអាទិភាពបន្ទាប់ ទទួលបានចំណែក 20 ភាគរយ 10 ភាគរយនិង 5 ភាគរយ រៀងគ្នានៃថវិកាមូលធនសរុបរៀងគ្នា។

**ថវិកាឆ្នាំ 2016 អនុម័តកាលពីចុងឆ្នាំមុន បានបន្តការធ្វើកំណែទម្រង់ថវិកា អមដោយការពង្រីកថវិកានីយកម្មតាមកម្មវិធីពេញលេញ។** ចំណុចនេះមានកំណត់នៅក្នុងឯកសារទស្សនទានស្តីពីទិសដៅយុទ្ធសាស្ត្រ នៃកំណែទម្រង់ប្រព័ន្ធថវិកា (2013-20)។

ការអនុវត្តថវិកាកម្មវិធីពេញលេញ ត្រូវបានពង្រីកដើម្បីគ្របដណ្តប់ក្រសួងនិងស្ថាប័នបន្ថែមទៀតចំនួន 15[14] ។ ឥឡូវនេះ ថវិកាកម្មវិធីមានចំនួនប្រហែល 57 ភាគរយនៃ

[14] ក្រសួង/ស្ថាប័នទាំង 15 គឺ: ក្រសួងព័ត៌មាន បរិស្ថាន សង្គមកិច្ច រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ក្រសួងពាណិជ្ជកម្ម ប្រៃសណីយ៍និងទូរគមនាគមន៍ ទេសចរណ៍ ធនធានទឹកនិងឧតុនិយម តុលាការកំពូល សាលាឧទ្ធរណ៍ រដ្ឋសភា ព្រឹទ្ធសភា ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អាជ្ញាធរសវនកម្មជាតិ និងអង្គភាពប្រឆាំងអំពើពុករលួយ។

ប្រភព: ច្បាប់ថវិកា 2016។ ក្នុងឆ្នាំ 2015 ថវិកាកម្មវិធីគ្របដណ្តប់ត្រឹមតែដប់ក្រសួងប៉ុណ្ណោះគឺ ក្រសួងអប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ កសិកម្ម កិច្ចការនារី ការងារ នគរូបនីយកម្មនិងសំណង់ សាធារណការ យុត្តិធម៌ និងហិរញ្ញវត្ថុ។ សម្រាប់ព័ត៌មានលម្អិត សូមអាន www.pfm.org.gov។

ថវិកាថវន្តសរុប (ផ្តល់ហិរញ្ញប្បទានក្នុងស្រុក) ដែលបាន បម្រុងទុកឲ្យក្រសួងនិងស្ថាប័ន។

**ការវិភាគអំពីនិរន្តរភាពបំណុលពីសំណាក់ធនាគារពិភពលោក / មូលនិធិរូបិយវត្ថុអន្តរជាតិ (DSA) ដែលបានធ្វើនៅឆ្នាំ 2015 បង្ហាញថា ចំណាត់ថ្នាក់សម្ពាធបំណុលរបស់ប្រទេសកម្ពុជានៅមានកម្រិតទាប** ជាមួយនឹងសូចនាករបន្ទុកបំណុលទាំងអស់ដែលបានព្យាករថានឹងស្ថិតក្រោមកម្រិតគោលរបស់ខ្លួន។ លទ្ធផលនេះក៏បង្ហាញផងដែរថានិរន្តរភាពបំណុល នៅតែបន្តងាយរងគ្រោះពីវិបត្តិនានាចំពោះកំណើនសេដ្ឋកិច្ច ការនាំចេញ និងស្ថានភាពសារពើពន្ធ ដែលតម្រូវឲ្យធ្វើកំណែទម្រង់រចនាសម្ព័ន្ធជាបន្ត ដើម្បីបង្កើនភាពធន់នៃសេដ្ឋកិច្ចតបនឹងវិបត្តិក្រៅស្រុក និងដើម្បីប្រមូលចំណូលក្នុងស្រុក។ នៅចុងឆ្នាំ 2014 ចំនួនប៉ាន់ស្មាននៃបំណុលសាធារណៈរបស់កម្ពុជាជាមួយបរទេស រួមទាំងបំណុលកកស្ទះផងដែរ មានចំនួនប្រហែល 5.5 ពាន់លានដុល្លាអាមេរិក ឬ 33 ភាគរយនៃផលិតផលក្នុងស្រុកសរុប។

**គួរកត់សម្គាល់ថា ចំណាត់ថ្នាក់សម្ពាធបំណុលរបស់ប្រទេសកម្ពុជាតែងមានកម្រិតទាប ចាប់តាំងពីឆ្នាំ 2011 មក។** ស្ថានភាពនេះត្រូវបានទ្រទ្រង់ជាចម្បងដោយសារគោលការណ៍នៃការកសាងថវិកាមានតុល្យភាពនៃស្ថានភាពសារពើពន្ធ ហើយខ្ចីប្រាក់ដោយផ្អែកលើលក្ខខណ្ឌសម្បទានតែប៉ុណ្ណោះ[15]។

## គ. ទស្សនៈវិស័យនិងហានិភ័យ

**កំណើនត្រូវបានរំពឹងថានឹងឡើងដល់ 6.9 ភាគរយ នៅឆ្នាំ 2016 មួយចំណែកគឺដោយសារការកើនឡើងក្នុងការចំណាយរបស់រាជរដ្ឋាភិបាល។** ការនាំចេញច្រើនក្នុងវិស័យកាត់ដេរ ត្រូវបានរំពឹងថានឹងជួយក្នុងការទូទាត់ភាពទន់ខ្សោយនៅក្នុង វិស័យកសិកម្មខណៈដែលវិស័យសំណង់ ដែលបានជំរុញដោយវិនិយោគផ្ទាល់ពីបរទេស នឹងបន្តដើរតួជាក្បាលម៉ាស៊ីនចម្បងនៃកំណើន។ ក្នុងរយៈពេលមធ្យម កំណើនត្រូវបានរំពឹងថានៅតែមានកម្រិតទាបជាង 7 ភាគរយ (តារាងទី 12)។

**មានការរំពឹងថា នឹងមានកាត់បន្ថយភាពក្រីក្របន្ថែមទៀត សម្រាប់គ្រួសារទាំងនៅទីក្រុងនិងនៅជនបទ ទូទាំងឆ្នាំ 2015-2016 ។** សម្រាប់គ្រួសារនៅតាមទីក្រុងកើតឡើងតាមរយៈ វិស័យសេដ្ឋកិច្ចដែលពួកគេចូលរួម (ភាគច្រើនគឺវិស័យ សំណង់ និងសេវាកម្ម) ។ សម្រាប់គ្រួសារនៅជនបទ លទ្ធភាពកាត់បន្ថយភាពក្រីក្រកើតឡើងតាមរយៈកំណើនប្រភពនៃប្រាក់ចំណូលបានមកក្រៅពីការងារកសិកម្មដែលពួកគេរកបានដោយខ្លួនឯង ។

**កំណើននាំចេញខ្ពស់ ក៏នឹងគាំទ្រដល់ឱនភាពគណនីចរន្ត ដែលមានទំហំកាន់តែតូច ត្រូវបានព្យាករថានឹងមានកម្រិតក្រោម 10 ភាគរយ នៅឆ្នាំ 2016 និងឆ្នាំ 2017** ។ ដោយសារការងើបឡើងវិញនៃសេដ្ឋកិច្ចនៅអឺរ៉ុប ការនាំចេញទំនិញត្រូវបានរំពឹងថា នឹងរួមចំណែកបង្កើនកំណើន និងកើនឡើងក្នុងតួលេខចំនួនពីរខ្ទង់។ កំណើននៃការនាំចូល ត្រូវរំពឹងថាថមថយបន្តិចម្តងៗ ខណៈដែលការមានការធ្លាក់ចុះ នូវការចេញអនុម័តលិខិតអនុញ្ញាតសាងសង់ក្នុងឆ្នាំ 2015។

**គោលនយោបាយសារពើពន្ធត្រូវបានរំពឹងថានឹងនៅតែបង្កើនការផ្គត់ផ្គង់សាច់ប្រាក់** ក្នុងរយៈពេលខ្លីទៅមធ្យម។ ថវិកាឆ្នាំ 2016 ឆ្លុះបញ្ចាំងពីគោលនយោបាយសារពើ-ពន្ធ បង្កើនសាច់ប្រាក់ ដោយបង្កើនចំណាយ 3.6 ភាគរយនៃ ផសស ក្នុងនោះ 1.4 ភាគរយ គឺបង្កើនលើប្រាក់ខែ ឯចំណែកនៅសល់បង្កើនចំណាយមូលធន និងចំណាយមិនមែនប្រាក់ខែ។ និន្នាការនេះទំនងជាបន្តនៅឆ្នាំ 2017 និងឆ្នាំ 2018 នៅក្នុងបរិបទនៃការបោះឆ្នោតឃុំសង្កាត់ និងការបោះឆ្នោតសាកល។

[15] កម្ចីសម្បទានគឺកម្ចីទាំងឡាយណាសែលមានជំនួយឥតសំណងចំនួន 35 ភាគរយយ៉ាងតិច។

**ការប្រកួតប្រជែងក្រៅប្រទេសខ្លាំងឡើង អាចធ្វើឲ្យកំណើនមានកម្រិតទាបជាងការរំពឹងទុក ក្នុងរយៈពេលមធ្យមទៅរយៈពេលវែង។** ខណៈដែលមូលដ្ឋានផលិតកម្ម និងមូលដ្ឋាននាំចេញមានទំហំតូច និងការនាំចេញសម្លៀកបំពាក់ (ប្រហែល 70 ភាគរយនៃចំនួនសរុប) បានប្រមូលផ្តុំយ៉ាងខ្លាំងនៅក្នុងទីផ្សារអឺរ៉ុប និងអាមេរិក សេដ្ឋកិច្ចកម្ពុជាត្រូវប្រឈមមុខទៅនឹងការប្រកួតប្រជែងកាន់តែច្រើន។ ជាមួយនឹងភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) រវាងវៀតណាមនិង EU មានហានិភ័យយ៉ាងច្រើនអំពីការបង្វែរការវិនិយោគនិងការនាំចេញ ឆ្ងាយពីប្រទេសកម្ពុជា វៀរលែងតែឧបសគ្គចម្បងៗ ដូចជា ការចំណាយខ្ពស់លើថាមពល ឧបសគ្គផ្នែកបទប្បញ្ញត្តិក្នុងការធ្វើអាជីវកម្ម និងឧបសគ្គផ្នែកហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានដោះស្រាយដោយជោគជ័យ[16]។ ជាបណ្តើរៗ ស្ថានភាពនេះអាចធ្វើឲ្យប៉ះពាល់ដល់កំណើន លុះត្រាតែកំណែទម្រង់រចនាសម្ព័ន្ធសំខាន់ៗដែលបានពិភាក្សានៅក្នុងផ្នែកអនុសាសន៍ខាងក្រោម ត្រូវបានយកចិត្តទុកដាក់ដោះស្រាយ ។

**វិស័យហិរញ្ញវត្ថុ ដែលមានការរីកចម្រើនយ៉ាងឆាប់រហ័សបានជួយឲ្យមានកំណើន ប៉ុន្តែក៏អាចបង្កឱ្យមានបញ្ហាប្រឈមមួយចំនួនផងដែរ។** កំណើនឥណទានផ្តល់ឲ្យវិស័យសំណង់ចំនួន 38 ភាគរយ បានបន្តកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងឆ្នាំ 2015។ ខណៈពេលដែលកំពុងត្រូវបាន ការពារពីការប្រែប្រួលផ្នែកហិរញ្ញវត្ថុនៅក្រៅប្រទេស សេដ្ឋកិច្ចកម្ពុជានៅតែពឹងផ្អែកលើលំហូរប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសក្នុងធនាគារ។ ដោយសារមានលទ្ធភាពតិចតួច សម្រាប់ការគោលនយោបាយរូបិយវត្ថុ ហើយធនាគារកណ្តាលមិនអាចដើរតួនាទី ជាអ្នកផ្តល់ប្រាក់កម្ចីក្នុងជម្រើសចុងក្រោយ ដោយសារតែដុល្លារូបនីយកម្មមានកម្រិតខ្ពស់ ក៏ដូចជាគ្មានទីផ្សារអន្តរធនាគារ កំណើនខ្ពស់នៃឥណទានក្នុងស្រុក ធ្វើឲ្យហានិភ័យកើនឡើងចំពោះស្ថិរភាពហិរញ្ញវត្ថុនៅប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក្តី ប្រកាសរបស់ធនាគារកណ្តា ដែលបានចេញនៅខែមីនា ឆ្នាំ 2016 បានតម្រូវឲ្យធនាគារបង្កើនការដើមទុនចំនួនទ្វេដង ត្រូវបានរំពឹងថានឹងជួយពង្រឹងភាពធន់របស់ពួកគេ ចំពោះការពង្រីកសកម្មភាពធនាគារយ៉ាងឆាប់រហ័ស។

**ហានិភ័យផ្សេងទៀតចំពោះទស្សនវិស័យនេះ** រួមមានសក្តានុពលនៃភាពចលាចលផ្នែកការងារ ការបន្តឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិកនៅក្នុងបរិបទ នៃដុល្លារូបនីយកម្ម ការងើបឡើងវិញយឺតនៃសេដ្ឋកិច្ចនៅអឺរ៉ុប និងផលប៉ះពាល់ពីការធ្លាក់ចុះ នៃសេដ្ឋកិច្ចប្រទេសចិន។ ការធ្លាក់ចុះយ៉ាងគំហុកនៃសេដ្ឋកិច្ចចិននឹងប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច ជាចម្បងដោយសារតែចំនួនភ្ញៀវទេសចរចិនអាចមានចំនួនតិច និងលំហូរចូលវិនិយោគផ្ទាល់ពីបរទេស មានចំនួនតិចក្នុងរយៈពេលមធ្យម។ ខណៈពេលដែលកម្ពុជាទំនងជាត្រូវបានការពារ ពីការប្រែប្រួលផ្នែកហិរញ្ញវត្ថុដោយសារការទីផ្សារមូលធននៅកម្ពុជាមានកម្រិត លំហូរចូលធនាគារនៅតែមានភាពងាយប៉ះពាល់ដល់ទំនុកចិត្តសាធារណៈ និងទស្សនៈអំពីទីផ្សារ។

[16] សូមអានរបាយការណ៍ពីស្តារស្តីពី Cambodia Investment Climate Assessment (2014) លើគេហទំព័រ http://documents.worldbank.org/curated/en/2014/01/23946799/cambodia-investment-climate-assessment-2014-creating-opportunities-firms-cambodia

**តារាង 12: សូចនាករសេដ្ឋកិច្ច និងការព្យាករណ៍មួយចំនួន ពីឆ្នាំ 2016 - 2018**

| | 2014 | 2015e | 2016p | 2017f | 2018f |
|---|---|---|---|---|---|
| ផសស ពិត (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 7.1 | 7.0 | 6.9 | 6.8 | 6.8 |
| ផសស តាមមុខចំណាយតាមថ្លៃទីផ្សារ (%ប្រែប្រួលធៀបនឹងឆ្នាំមុន) | 6.8 | 7.1 | 6.8 | 6.8 | 6.7 |
| កសិកម្ម | 0.3 | 0.2 | 0.1 | 1.4 | 1.1 |
| ឧស្សាហកម្ម | 10.1 | 11.7 | 9.7 | 7.3 | 6.8 |
| សេវាកម្ម | 8.4 | 7.4 | 8.0 | 9.1 | 9.2 |
| អតិផរណា (ប្រែប្រួលចុងគ្រា គិតជា%) | 1.2 | 2.8 | 3.0 | 3.5 | 3.8 |
| ជញ្ជីងសារពើពន្ធ គិតទាំងជំនួយឥតសំណង (% នៃ ផសស) | -1.4 | -0.8 | -2.8 | -2.9 | -4.1 |
| នាំចេញ ទំនិញនិងសេវា (%ប្រែប្រួលធៀបនឹងឆ្នាំមុន) | 8.6 | 9.2 | 14.9 | 9.1 | 11.7 |
| នាំចូល ទំនិញនិងសេវា (%ប្រែប្រួលធៀបនឹងឆ្នាំមុន) | 10.7 | 7.4 | 9.6 | 9.9 | 11.6 |
| សមតុល្យគណនីចរន្ត មិនគិតបង្វែរផ្ទេរការ (%នៃ ផសស) | -11.9 | -10.8 | -9.3 | -9.3 | -10.0 |
| វិនិយោគផ្ទាល់ពីបរទេស គិតជាលានដុល្លារអាមេរិក | 1,677 | 1,803 | 1,653 | 1,748 | 1,780 |

ប្រភព: អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មាន និងព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក
e = ប៉ាន់ស្មាន p = ចំណោល f=ការព្យាករណ៍

## ឃ. សារគន្លឹះ និងជម្រើសគោលនយោបាយ

**ហានិភ័យនៃការពឹងផ្អែកយ៉ាងខ្លាំងលើទីផ្សារអឺរ៉ុប និង ទីផ្សារអាមេរិកកំពុងកើនឡើងចំពោះផលិតផលប្រមូលផ្តុំលើសម្លៀកបំពាក់។** សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជារងផលប៉ះពាល់ពីការប្រកួតប្រជែងកាន់តែខ្លាំង ខណៈអាចមានផលប៉ះពាល់អវិជ្ជមាន មកលើប្រទេសកម្ពុជានៃកិច្ចព្រមព្រៀង TPP និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងវៀតណាម និង EU ក្នុងក្របខ័ណ្ឌរយៈពេលមធ្យមទៅរយៈពេលវែង។ ដូចបានកំណត់ក្នុងការវាយតម្លៃបរិយាកាសវិនិយោគចុងក្រោយបង្អស់ ឧបសគ្គចម្បងៗ ដូចជា ថ្លៃចំណាយលើថាមពលខ្ពស់ ឧបសគ្គផ្នែកបទប្បញ្ញត្តិក្នុងការធ្វើធុរកិច្ច និងឧបសគ្គផ្នែកហេដ្ឋារចនាសម្ព័ន្ធ ចាំបាច់ត្រូវដោះស្រាយឱ្យបានសកម្ម ដើម្បីបង្កើនភាពប្រកួតប្រជែងក្រៅប្រទេស។

**ការកែលម្អបរិយាកាសធុរកិច្ចជារួម នឹងបង្កើនភាពប្រកួតប្រជែងតាមវិស័យនានា ដែលទ្រទ្រង់ពិពិធកម្មផលិតផល និងទីផ្សារ** ដូចមានកំណត់នៅក្នុងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម (IDP) ហើយក៏ជួយក្រុមហ៊ុនឲ្យរៀបចំឱ្យបានល្អក្នុងការទាញយកឧត្តមភាពពីទីផ្សារនិងមូលដ្ឋានផលិតកម្មតែមួយដែលបានកំណត់ដោយសហគមន៍សេដ្ឋកិច្ចអាស៊ាន ។ ការដោះស្រាយឧបសគ្គចម្បងៗ ពោលគឺថ្លៃចំណាយខ្ពស់លើថាមពល និងឧបសគ្គផ្នែកហេដ្ឋារចនាសម្ព័ន្ធ បង្ហាញអំពីតម្រូវការក្នុងការបង្កើនការវិនិយោគសាធារណៈដើម្បីទ្រទ្រង់ភាពប្រកួតប្រជែងនៅក្រៅប្រទេស។

**កម្លាំងពលកម្មដែលបានទទួលការបណ្តុះបណ្តាល និងមានជំនាញល្អប្រសើរជាងមុន ប្រាកដជានឹងជួយទាញយកឧត្តមភាព ពីភាគលាភប្រជាសាស្ត្ររបស់ប្រទេសកម្ពុជាជាក់ជាមិនខាន។** ដើម្បីបំពេញភាពជាដៃគូសាកល សម្រាប់ការអប់រំដែលគម្រោងអប់រំជាមូលដ្ឋានកំពុងដំណើរការ រាជរដ្ឋាភិបាលបានស្នើសុំមូលនិធិ IDA ដើម្បីបង្កើនលទ្ធផលក្នុងមធ្យមសិក្សាបឋមភូមិ។ ថវិកាអប់រំបានកើនឡើងយ៉ាងខ្លាំងដល់ 17.1 ភាគរយនៃថវិកាជាតិនៅឆ្នាំ 2015 (16.2% នៅឆ្នាំ 2014) ។ ប្រព័ន្ធការវាយតំលៃថ្នាក់ជាតិ (NAS) ត្រូវបានបង្កើតឡើង ហើយលទ្ធផលនៃការវាយតម្លៃត្រូវបានប្រើសម្រាប់ជូនដំណឹងដល់ ការរៀបចំផែនការគោលនយោបាយ។ បញ្ហាប្រឈមចម្បងៗតទៅអនាគត រួមមាន ការធ្វើឱ្យប្រសើរឡើង នូវគុណភាពនៃការផ្តល់សេវាសាធារណៈ។

**ដើម្បីឲ្យនៅតែមានលក្ខណៈប្រកួតប្រជែង អាជ្ញាធរក៏អាចពិចារណា បន្តបង្កើនវិភាជន៍ថវិកាទៅកាន់គម្រោងវិនិយោគដែលមានផលិតភាព និងមានលក្ខណៈប្រកួតប្រជែងផងដែរ។** នៅពេលដែលប្រទេសកម្ពុជាបានក្លាយទៅជាសេដ្ឋកិច្ច ដែលមានប្រាក់ចំណូលកណ្តាលកម្រិតទាប កម្ពុជាកំពុងជួបប្រទះការធ្លាក់ចុះបន្តិចម្តងៗនៃការផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ពិសេសគឺការធ្លាក់ចុះនូវជំនួយឥតសំណង។ បច្ចុប្បន្ននេះប្រទេស កម្ពុជា គឺ

នៅតែជាពឹងផ្អែកលើដៃគូអភិវឌ្ឍន៍ក្នុងការ កសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត (ពីផ្លូវថ្នល់ដល់សាលារៀន)។ រយៈពេលមធ្យមខណៈដែលកម្ចីសម្បទានក្នុងរយៈពេលមធ្យម អាចមានប្រភពមកពីក្នុងតំបន់ច្រើនឡើងៗ ដូចជា ការបង្កើតធនាគារវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់អាស៊ី (AIIB) ព្រមទាំងមកពីប្រភពទ្វេភាគីដូចជា ជប៉ុន និងចិន ការចុះជាលំដាប់នៃការវិនិយោគសាធារណៈដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ក៏តម្រូវឱ្យមានការឆ្លើយតបរយៈពេលខ្លី ពីសំណាក់ថវិកាវិភាជន៍រាជរដ្ឋាភិបាល។ ការផ្តល់ អាទិភាពដោយប្រយ័ត្នប្រយែងចំពោះការចំណាយ និងការបន្តប្រមូលប្រាក់ចំណូលបានល្អប្រសើរ នឹងជួយឱ្យកិច្ចការនេះអាចអនុវត្តបាន ប្រសិនបើអាចទប់បញ្ជីចំណាយលើប្រាក់ខែបាន។ ទន្ទឹមនឹងនេះដែរ ចាំបាច់ត្រូវពង្រឹងបន្ថែមនូវច្បាប់ និងបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងគម្រោងវិនិយោគទុន ដូចការប្រមើលមើលក្នុងការវាយតម្លៃការគ្រប់គ្រងការវិនិយោគសាធារណៈដែលកំពុងស្ថិតក្រោមការពិភាក្សា។

**ការវាយតម្លៃការគ្រប់គ្រងវិនិយោគ សាធារណៈ (PIM) ដែលស្ថិតក្រោមការពិភាក្សា នឹងអាចជួយពង្រឹងក្របខណ្ឌទុន ដែលផ្តល់ហិរញ្ញប្បទានដោយរាជរដ្ឋាភិបាល ។** ខណៈដែលកម្ពុជាប្រើប្រាស់ស្តង់ដារនីតិវិធីប្រតិបត្តិការចំពោះគម្រោង ដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ គោលការណ៍ណែនាំវិនិយោគផ្ទាល់របស់រាជរដ្ឋាភិបាលមានភាពធូររលុង និងមានភាពខុសគ្នាពីក្រសួងមួយទៅក្រសួងមួយទៀត។ ការងារ PIM កំពុងដំណើរការ ត្រូវបានគាំទ្រដោយធនាគារពិភពលោក ត្រូវបានរំពឹងថានឹងជួយពង្រឹងសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការរៀបចំផែនការ វាយតម្លៃ រៀបចំថវិកា អនុវត្ត និងតាមដានគម្រោងហេដ្ឋារចនាសម្ព័ន្ធតាមរយៈការកំណត់វិធានការដែលអាចអនុវត្តបាន ដើម្បីកែលម្អក្នុងផ្នែកផ្សេងៗគ្នា។ រដ្ឋាភិបាលក៏ពិនិត្យមើលឡើងវិញនូវច្បាប់សម្បទាន ដើម្បីអនុញ្ញាតិឲ្យមានក្របខ័ណ្ឌមួយរឹងមាំបំផុតសម្រាប់វិនិយោគសាធារណៈ និងភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន។

**ការបង្កើនការត្រួតពិនិត្យ និងការសម្របសម្រួលអន្តរស្ថាប័ន អាចត្រូវបានចាត់ទុកថាដើម្បីការពារស្ថិរភាពហិរញ្ញវត្ថុ។** កង្វះព័ត៌មាន និងកង្វះទីផ្សារ "ធនាគារស្រមោល" ធ្វើឱ្យលំបាកក្នុងការកំណត់ទំហំហានិភ័យ ឲ្យបានច្បាស់លាស់"។ ដំបូងហើយសំខាន់បំផុត ចាំបាច់ត្រូវដោះស្រាយភាពខុសគ្នាមួយចំនួន ក្នុងការប្រមូលទិន្នន័យ ដូចជា ឥណទានមិនដំណើរ គ្រោះបណ្តាលមកពីសម្ព័ន្ធភាពគូភាគី និងគ្រោះបណ្តាលមកពីហានិភ័យប្រទេស។ ភារកិច្ចទាំងនេះអាចត្រូវបានដោះស្រាយនៅក្នុងរយៈពេលខ្លី។ ការកែលម្អសមត្ថភាពត្រួតពិនិត្យបន្ថែមទៀត ខណៈពេលពង្រឹង និងបង្កើតសូចនាករចាំបាច់ ដើម្បីគាំទ្រដល់ប្រព័ន្ធជូនដំណឹងជាមុន ដើម្បីអាចបង្កើត វិធានការសម្រាប់កាត់បន្ថយហានិភ័យដែលមានលក្ខណៈជាប្រព័ន្ធ អាចត្រូវបានដោះស្រាយនៅក្នុងរយៈពេលមធ្យម។ ជាមួយគ្នានេះផងដែរ សំខាន់ត្រូវកែលម្អការសម្របសម្រួលអន្តរស្ថាប័ន ដោយពង្រឹងកិច្ចសហការដែលមានស្រាប់ ពង្រឹងការចែករំលែកទិន្នន័យ ភាពច្បាស់លាស់ស្តីពីតួនាទី និងការទទួលខុសត្រូវក្នុងពេលមានវិបត្តិ ព្រមទាំងការលើកកម្ពស់សមត្ថភាពត្រៀមលក្ខណៈចំពោះវិបត្តិ។

**គប្បីពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ ដើម្បីធានាឱ្យមានស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ។** ការបន្តកើនឡើងនៃអនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ រួមចំណែកមួយផ្នែកចំពោះសន្ទុះរីកចំរើននៃវិស័យសំណង់ តម្រូវឲ្យមានការត្រួតពិនិត្យម៉ត់ចត់ផងដែរ។ ថ្មីៗនេះ អាជ្ញាធរបានដាក់ចេញនូវវិធានការសំខាន់ៗមួយចំនួន រួមមាន ការបង្កើនទុនកាតព្វកិច្ចរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ទុនបម្រុងកាតព្វកិច្ច ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់កម្ចីពីបរទេស និងអនុបាតគ្របដណ្តប់សាច់ប្រាក់ងាយស្រួល។

**កំណើនយ៉ាងឆាប់រហ័សនៃវិស័យមីក្រូហិរញ្ញវត្ថុ ក៏តម្រូវឱ្យមានការការពារអតិថិជន និងការបង្កើនចំណេះដឹង**

**ផ្នែកហិរញ្ញវត្ថុផងដែរ។** នៅពេលដែលមានសាធារណជនកាន់តែច្រើនប្តូរទៅរកការសន្សំផ្លូវការ ចាំបាច់ត្រូវកសាងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុ ដែលទ្រទ្រង់ដោយការត្រួតពិនិត្យ ដែលមានលក្ខណៈប្រុងប្រយ័ត្នជាខ្លាំង ក៏ដូចជាការចែករំលែកព័ត៌មានទៀងទាត់ រវាងរាជរដ្ឋាភិបាលនិងនិយ័តករ និងមានការរៀបចំបម្រុងថវិការបស់រាជរដ្ឋាភិបាល។ នៅកម្រិតគ្រួសារ ការពង្រីកមីក្រូហិរញ្ញវត្ថុ និងឥណទានធនាគារយ៉ាងឆាប់រហ័សធ្វើឱ្យប្រទេសកម្ពុជារីកចម្រើនឆាប់រហ័ស ក្នុងការពង្រីកសេវាហិរញ្ញវត្ថុដល់ពលរដ្ឋក្រីក្រ និងទៅកាន់តំបន់ជនបទ។ ទោះជាយ៉ាងណាក្តី ទីផ្សារមីក្រូឥណទានអាចផ្តល់ ឥណទានច្រើនហួស ហើយមានរឿងដំណាលជាច្រើនដែលសំដៅដល់គ្រួសារក្រីក្របំផុត ដែលជំពាក់បំណុលវ័ណ្ឌក ខណៈពួកគេមានចំណេះដឹងផ្នែកហិរញ្ញវត្ថុតិចតួច ដែលអាចមានការរំលោភបំពានពីទីផ្សារ។ ដូច្នេះ សំខាន់ត្រូវធ្វើឲ្យប្រាកដថា ការអនុវត្តន៍ប្រកាសថ្មីៗ ដែលតម្រូវឲ្យបង្កើនទុនទ្វេដងនេះ ទទួលបានជោគជ័យ តាមរយៈការជំរុញការច្របាច់ និងរួមបញ្ចូលគ្នា ដែលអាចជួយគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលដំណើរការមិនល្អ ឲ្យក្លាយជាគ្រឹះស្ថានដែលមានដំណើរការល្អ។

**បទពិសោធន៍អន្តរជាតិបង្ហាញក្របខ័ណ្ឌមួយ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ ការគ្រប់គ្រងល្អលើវិស័យធនាគារ ដែលអាចអនុវត្តជាសាកល។** ទាំងនេះរួមមានៈ (i) ការកំណត់យ៉ាងច្បាស់នូវអំណាចត្រួតពិនិត្យ (ii) ការទទួលខុសត្រូវ និងគណនេយ្យភាពនៅក្នុងចំណោមសមត្ថកិច្ចត្រួតពិនិត្យ និង (iii) បទប្បញ្ញត្តិប្រុងប្រយ័ត្នសមស្រប។ បុរេលក្ខខណ្ឌមួយចំនួនសម្រាប់ការត្រួតពិនិត្យវិស័យធនាគារដែលមានប្រសិទ្ធភាពគឺ (i) ការបង្កើតក្របខ័ណ្ឌបានល្អដើម្បីធានាដល់ការរៀបចំគោលនយោបាយស្ថិរភាពហិរញ្ញវត្ថុ (ii) ការក្របខ័ណ្ឌមួយច្បាស់លាស់សម្រាប់ដោះស្រាយស្ថានភាពវិបត្តិ និង(iii) កម្រិតសមស្របនៃការការពារ ដែលមានលក្ខណៈជាប្រព័ន្ធ (ឬប្រព័ន្ធសំណាញ់សុវត្ថិភាពសាធារណៈ) ។ ចំពោះការពិភាក្សាលម្អិតបន្ថែមទៀត និងអនុសាសន៍ សូមមើលប្រធានបទពិសេសស្តីពី "ការអភិវឌ្ឍន៍កាលពីពេលថ្មីៗនៃវិស័យហិរញ្ញវត្ថុៈ ឱកាស និងហានិភ័យ" ដូចខាងក្រោម។

## ង. ប្រធានបទពិសេស៖ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ: ឱកាស និងហានិភ័យ

### ក). ទិដ្ឋភាពទូទៅ និងនិន្នាការនៃវិស័យហិរញ្ញវត្ថុ

**ចាប់ផ្តើមពីមូលដ្ឋានទាប ទីផ្សារហិរញ្ញវត្ថុកម្ពុជាត្រូវបានអភិវឌ្ឍស៊ីជម្រៅយ៉ាងលឿន ទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច រឹងមាំ។** អនុបាតនៃរូបិយវត្ថុទូទៅ (M2) ធៀបនឹងផលិតផលក្នុងស្រុកសរុប បានកើនឡើងពីទៅ 53.4 ភាគរយ ក្នុងឆ្នាំ 2013 ទៅ 66.3 ភាគរយ នៅចុងឆ្នាំ 2015[17]។ គ្រឹះស្ថានហិរញ្ញវត្ថុ[18]មានទ្រព្យសកម្មស្មើនឹង 109 ភាគរយនៃផសស មានប្រាក់បញ្ញើស្មើនឹង 57 ភាគរយនៃ ផសស និងមានប្រាក់កម្ចី 54 ភាគរយនៃ ផសស នៅចុងឆ្នាំ 2015 ។ ទ្រទ្រង់ដោយការកើនឡើងនូវទំនុកចិត្ត វិស័យហិរញ្ញវត្ថុ[19]បានឆ្លងកាត់ការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ជាមួយនឹងផលិតផលហិរញ្ញវត្ថុកាន់តែច្រើន ត្រូវបានបង្កើតឡើង និងត្រូវបានដាក់ឲ្យប្រើប្រាស់។ ខណៈដែលវិស័យធនាគារនៅតែបន្តគ្របដណ្តប់ទីផ្សារហិរញ្ញវត្ថុ ជាមួយនឹងការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនធនាគារដែលចូលមកប្រទេសកម្ពុជាក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ វិស័យមីក្រូហិរញ្ញវត្ថុក៏កំពុងពង្រីកខ្លួនយ៉ាងឆាប់រហ័សដែរ។ គិតត្រឹមខែកុម្ភៈឆ្នាំ 2016 ប្រព័ន្ធហិរញ្ញវត្ថុមានធនាគារពាណិជ្ជ[20] ចំនួន 36 មានធនាគារឯកទេស[21]ចំនួន 11 មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន 34 មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួនប្រាំពីរ មានប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានចុះឈ្មោះចំនួន 36 នាក់ មានក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួនប្រាំមួយ និងមានភ្នាក់ងារទូទាត់ទីបីចំនួនប្រាំ ។ វិស័យធានារ៉ាប់រងមានក្រុមហ៊ុនធានារ៉ាប់រងចំនួនប្រាំបួន (ធានារ៉ាប់រងមិនមែនជីវិតចំនួនប្រាំមួយ និងធានារ៉ាប់រងជីវិតចំនួនបី) ធានារ៉ាប់រងបន្តមួយ និងធានារ៉ាប់រងខ្នាតតូចចំនួនបី[22]។ ជាមួយនឹងការដាក់ឲ្យដំណើរការផ្សារមូលបត្រកម្ពុជា មានក្រុមហ៊ុនចំនួនបីបានចុះបញ្ជី មានភ្នាក់ងារធានាទិញមូលបត្រចំនួនប្រាំមួយ ក្រុមហ៊ុនជួញដូរមូលបត្រមួយ និងជើងសារការីចំនួនបី បានកើតឡើង។ ចំនួននៃគ្រឹះស្ថានហិរញ្ញវត្ថុបានកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ និងបានធ្វើឱ្យកើនឡើងចំនួនប្រាំមួយដង នូវទិន្នន័យបរិយាប័នហិរញ្ញវត្ថុ( Financial Inclusion) ដល់ 23 ភាគរយ ក្នុងការស្ទង់សន្ទស្សន៍ហិរញ្ញវត្ថុសាកល(Global Findex) នាឆ្នាំ 2014 (រូប S1 និង S2) ហើយបានកើនឡើងដល់ 51.41 ភាគរយ ក្នុងឆ្នាំ 2015 ដោយផ្អែកលើទិន្នន័យជាសាធារណៈ[23]។ ទោះជាយ៉ាងនេះក្តី គម្លាតការប្រាក់នៅកម្ពុជា រវាងប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក សម្រាប់ឥណប្រតិទានមួយឆ្នាំនៅតែមានទំហំធំក្នុងកម្រិត 9.43 ភាគរយ និង 7.16 រៀងគ្នា ក្នុងខែកក្កដាឆ្នាំ 2015។

---

[17] ដូចមានរាយការណ៍នៅក្នុងអង្កេតរូបិយវត្ថុ ខែ ធ្នូ ឆ្នាំ 2015

[18] គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ

[19] វិស័យហិរញ្ញវត្ថុរួមមានគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលស្ថិតក្រោមបទប្បញ្ញត្តិតបស់ធនាគារជាតិនៃកម្ពុជា ក្រុមហ៊ុនធានារ៉ាប់រងនិងអ្នកផ្តល់សេវាមិនមែនហិរញ្ញវត្ថុ ដូចជាឈ្មួញជើងសារអចលនទ្រព្យ ក្រុមហ៊ុនសវនកម្ម និងគណនេយ្យ ស្ថិតក្រោមបទប្បញ្ញត្តិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំណែកឯក្រុមហ៊ុនមូលប័ត្រ ឈ្មួញជើងសារ ឈ្មួញទិញលក់មូលប័ត្រ ស្ថិតក្រោមបទប្បញ្ញត្តិគ្រប់គ្រងរបស់គណៈកម្មាធិការមូលប័ត្រកម្ពុជា (SECC).

[20] ក្នុងចំណោមធនាគារទាំង 36 មានធនាគារពាណិជ្ជចុះបញ្ជីក្នុងស្រុកចំនួន 13 បុត្រសម្ព័ន្ធបរទេសចំនួន 12 និងសាខាបរទេសចំនួន 11។

[21] ក្នុងចំណោមធនាគារឯកទេសចំនួន 11 មានធនាគាររដ្ឋមួយ ធនាគារដែលមានកម្មសិទ្ធិភាគច្រើនជាជនជាតិខ្មែរចំនួនបួន ធនាគារដែលមានកម្មសិទ្ធិភាគច្រើនជាជនបរទេសចំនួនប្រាំមួយ។.

[22] មានអង្គការក្រៅរដ្ឋាភិបាលមួយដែលបានទទួលអាជ្ញាបណ្ណជាអ្នកផ្តល់ការធានារ៉ាប់រងសុខភាពនៅសហគមន៍។

[23] ការគណនាបរិយាប័នហិរញ្ញវត្ថុ(ផ្អែកលើទិន្នន័យចុងក្រោយដែលមាន)មានដូចតទៅ: អ្នកដាក់ប្រាក់បញ្ញើចំនួន 2.3 លាននាក់ក្នុងវិស័យធនាគារ (2015) អ្នកខ្ចីប្រាក់ចំនួន 2.3 លាននាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (2014) និងមានម្ចាស់គណនីចំនួន 0.6 លាននាក់ជាមួយក្រុមហ៊ុន WING សរុប 5.244 លាននាក់។ ចំនួនប៉ាន់ស្មានៃចំនួនប្រជាជនពេញវ័យគឺ 10.2 លាននាក់ក្នុងចំណោមប្រជាជនចំនួន 15 លាននាក់។ ហេតុនេះ បរិប័នហិរញ្ញវត្ថុស្មើនឹង 51.4 ភាគរយ (5.244/10.2)។ ទោះជាយ៉ាងណាក្តី ទិន្នន័យស្តីពីបរិយាប័នហិរញ្ញវត្ថុមិនទំហំដូចគ្នាឡើយពីប្រភពមួយទៅប្រភពមួយ ប្រភពខ្លះមានបរិយាប័នហិរញ្ញវត្ថុច្រើន ឯប្រភពខ្លះទៀតមានតិច។

**រូបលេខ S1 និង S2៖ ការប្រៀបធៀបបរិយាប័ន្នហិរញ្ញវត្ថុ: (1) កម្ពុជាមានកំណើនជាង 19 ភាគរយ ពីឆ្នាំ 2011 ដល់ឆ្នាំ 2014 និង (2) ក្រុមពលរដ្ឋក្រីក្របំផុតចំនួន 40 ភាគរយក៏កើនឡើងយ៉ាងខ្លាំងផងដែរ**




ប្រភព: 2014 World Bank's Global Findex Report

## ខ). វិស័យធនាគារ

**ប្រព័ន្ធធនាគារ ដែលកំពុងពង្រីកខ្លួនយ៉ាងឆាប់រហ័សគាំទ្រដល់កំណើនសេដ្ឋកិច្ច ខណៈដែលការប្រកួតប្រជែងក្នុងចំណោមធនាគារ កាត់បន្ថយអត្រាការប្រាក់កម្ចី និងធ្វើអោយប្រសើរឡើងនូវលទ្ធភាពទទួលបានហិរញ្ញវត្ថុ។** ឥណទានសរុបដែល ផ្តល់ដោយប្រព័ន្ធធនាគារបានកើនឡើងដល់ 54 ភាគរយ នៃផលិតផលក្នុងស្រុកសរុប ដែលកំពុងផ្តល់ឲ្យអ្នកខ្ចី 2,3 លាននាក់ក្នុងឆ្នាំ 2015 ធៀបនឹង 27 ភាគរយ នៃ ផសស ខណៈដែលប្រាក់កម្ចី ត្រូវបានផ្តល់ឲ្យអ្នកខ្ចីត្រឹមតែជាងម្ភៃប្រាំម៉ឺននាក់ប៉ុណ្ណោះ ក្នុងឆ្នាំ 2010[24]។ ចំណាយលើប្រាក់កម្ចីត្រូវបានកាត់បន្ថយយ៉ាងខ្លាំង ដោយសារអត្រាការប្រាក់មធ្យមលើឥណទានរយៈពេលខ្លីបានធ្លាក់ចុះដល់ 11.6 ភាគរយ ក្នុងមួយឆ្នាំ នៅឆ្នាំ 2015 គឺធ្លាក់ចុះពី 22.04 ភាគរយ ក្នុងមួយឆ្នាំ ក្នុងឆ្នាំ 2010។

**រូបភាព S3: ឥណទានសរុបលើវិស័យសំណង់ (% នៃផសស) បានកើនឡើងបីដងក្នុងរយៈពេលប្រាំឆ្នាំកន្លងមក។**




ប្រភព: ធនាគារជាតិនៃកម្ពុជា

**ទោះជាមានការប្រកួតប្រជែងយ៉ាងខ្លាំងក្តី ប្រព័ន្ធធនាគារនៅតែមានលក្ខណៈប្រមូលផ្តុំ។** ធនាគារធំបំផុតទាំងប្រាំមានទ្រព្យសកម្មជាងពាក់កណ្តាលនៃទ្រព្យសកម្មវិស័យធនាគារទាំងមូល។ ប្រព័ន្ធធនាគារមានអត្រាកំណើនទ្រព្យសកម្មប្រហែល 30 ភាគរយ ជារៀងរាល់ឆ្នាំ នៅក្នុងអំឡុងឆ្នាំ 2010-14 ។ ការធ្វើឱ្យប្រសើរឡើងនូវទំនុកចិត្តក្នុងប្រព័ន្ធធនាគារ លើកទឹកចិត្តវិស័យឯកជនឲ្យដាក់ប្រាក់បញ្ញើ ដែលបានកើនឡើងក្នុងអត្រាជាមធ្យម 23 ភាគរយ ក្នុងមួយឆ្នាំ ធៀបនឹង រយៈពេលដូចគ្នា។ ទោះយ៉ាងនេះក្តី កាលពីពេលថ្មីៗនេះកំណើនទ្រព្យសកម្ម និងប្រាក់បញ្ញើរបស់ធនាគារបានថយចុះដល់ 22.1 ភាគរយ និង 16.6 ភាគរយ រៀងគ្នានៅចុងឆ្នាំ 2015។ ទន្ទឹមនឹងនេះដែរ ឥណទានក្នុងចរាចរណ៍ ដែល ផ្តល់ដោយប្រព័ន្ធធនាគារបន្តកើនឡើងយ៉ាងឆាប់រហ័ស ឡើងដល់ប្រមាណជា 30 ភាគរយ ធៀបនឹងឆ្នាំមុន ក្នុងរយៈពេលប្រាំឆ្នាំ

[24] របាយការណ៍ឆ្នាំ 2010 របស់ធនាគារជាតិនៃកម្ពុជា និងរបាយការណ៍ឆ្នាំ 2015 របស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA)

កន្លងមក។ ដូច្នេះ អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើធនាគារ បានកើនពី 87 ភាគរយនៅចុងឆ្នាំ 2014 ដល់ 96 ភាគរយនៅចុងឆ្នាំ 2015 ។

**កំណើនឥណទានបានបន្តផ្តល់ហិរញ្ញប្បទានចាំបាច់ដើម្បីសម្រួលដល់ការកើនឡើងក្នុងការវិនិយោគ និងកំណើនប្រើប្រាស់ក្នុងស្រុក ជាមួយនឹងការកើនឡើងនូវវណ្ណៈកណ្តាល ក្នុងបរិបទនៃបរិយាកាសនយោបាយ និងស្ថាប័នដែលមានសថេរភាពយ៉ាងធំ។** អាជ្ញាធរបានត្រូវបានលើកទឹកចិត្តឱ្យយកចិត្តទុកដាក់ជាពិសេសចំពោះឥណទានសម្រាប់វិស័យប្រថុយប្រថាន (Speculative sectors) និង/ឬអ្នកខ្ចីដែលអាចមានសមត្ថភាពខ្សោយក្នុងការទូទាត់សង។ ក្នុងត្រីមាសទីបីនៃឆ្នាំ 2015 ការផ្តល់ឥណទានដល់វិស័យពាណិជ្ជកម្មមានចំនួន 34 ភាគរយ និងសំណង់[25] 20 ភាគរយ នៃឥណទានសរុប។ ជាភាគរយនៃ ផសស ការផ្តល់ឥណទានដល់វិស័យសំណង់ (រួមទាំងអចលនទ្រព្យ និងនិក្ខេប) បានកើនឡើង បីដងក្នុងរយៈពេលប្រាំឆ្នាំកន្លងមក គឺកើនឡើងពី 4 ភាគរយ នៅឆ្នាំ 2010 ដល់ 13 ភាគរយ នៅឆ្នាំ 2015 (រូបភាព S3) ។ កំណើនឥណទានខ្ពស់ជារៀងរហូតក៏ធ្វើឲ្យមានភាពតានតឹងមកលើសាច់ប្រាក់ងាយស្រួលរបស់ធនាគារផងដែរ។ ហេតុនេះ អនុបាតសាច់ប្រាក់ងាយស្រួលមធ្យមរបស់ធនាគារ ធ្លាក់ចុះ និងធ្លាក់ពី 85 ភាគរយ ក្នុងត្រីមាសទីពីរនៃឆ្នាំ 2014 ទៅ 80 ភាគរយ នៅត្រីមាសទីបួននៃឆ្នាំដដែល។

**ដើម្បីកាត់បន្ថយសម្ពាធសាច់ប្រាក់ងាយស្រួល ទីផ្សារអន្តរធនាគារមួយត្រូវបានបង្កើតឡើងដោយអាជ្ញាធរជាមួយនឹងដាក់ឲ្យប្រើប្រាស់នូវវិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចជួញដូរបាននៅឆ្នាំ 2013។** ទោះយ៉ាងណាក្តី ក្នុងពេលអវត្តមាននៃទីផ្សារសញ្ញាប័ណ្ណរដ្ឋាភិបាល ទីផ្សារអន្តរធនាគារដែលទើបចាប់កំណើត ដែលមានសារសំខាន់សម្រាប់ធនាគារមួយចំនួនដែលប្រឈមមុខនឹងកង្វះសាច់ប្រាក់ងាយស្រួល នៅតែពឹងផ្អែកយ៉ាងខ្លាំងលើការជឿទុកចិត្ត និងកិច្ចសហការក្នុងចំណោមធនាគារដើម្បីពង្រីកបន្ថែម និងអភិវឌ្ឍឲ្យកាន់តែស៊ីជម្រៅ។ ការបង្កើតទីផ្សារសញ្ញាប័ណ្ណរដ្ឋាភិបាលអាចផ្តល់ប្រយោជន៍ដល់ប្រទេសកម្ពុជា សម្រាប់គ្រប់គ្រងស្ថានភាពសារពើពន្ធរបស់រដ្ឋាភិបាលឲ្យបានល្អប្រសើរជាងមុន ដោយផ្តល់ផលិតផលហិរញ្ញវត្ថុយ៉ាងច្រើនដែលអាចវិនិយោគបាន ក៏ដូចជាគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ស្ថាប័នហិរញ្ញវត្ថុឲ្យកាន់តែល្អប្រសើរជាងមុន និងបង្កើតឡើងនូវគោលការណ៍ទទួលផល។

**អនុបាតសាធនភាពសរុប ពិសេសសម្រាប់ថ្នាក់ទី 1 នៅតែមានសុខភាពល្អ ព្រោះថាវាមានកម្រិតខ្ពស់ជាងកិច្ចតម្រូវប្រុងប្រយ័ត្នចំនួន 15 ភាគរយ។** អនុបាតសាធនភាពនៃវិស័យធនាគារបានធ្លាក់ចុះបន្តិច ពីកម្រិតកំពូលនៅក្នុងត្រីមាសទីពីរនៃឆ្នាំ 2012 មកត្រឹម 21.50 ភាគរយ នៅត្រីមាសទីបួននៃឆ្នាំ 2014។ ប៉ុន្តែស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារមួយចំនួនហាក់ដូចជាមិនសូវពេញចិត្តប៉ុន្មានឡើយ។ ប្រព័ន្ធធនាគារប្រមូលផ្តុំធ្វើឲ្យធនាគារចំនួនប្រាំទទួលផលចំណេញពីហ៊ុនវិនិយោគ (ROE) លើសពី 25 ភាគរយ ចំណែកឯចំណេញពីហ៊ុនវិនិយោគមធ្យមរបស់វិស័យធនាគារស្មើនឹង 16 ភាគរយ នៅចុងឆ្នាំ 2014 [26]។

ការរីកចម្រើនយ៉ាងឆាប់រហ័សនៃប្រព័ន្ធធនាគារអាចនាំមកនូវហានិភ័យមួយចំនួន ដោយសារតែការពឹងផ្អែកលើការផ្តល់មូលនិធិពីបរទេស។ ចំពោះស្ថានភាពហានិភ័យរួម ចំណាត់ថ្នាក់របស់ Standard & Poor នៃវិស័យធនាគារនៅក្នុង

[25] រួមមានវិស័យសំណង់ អចលនទ្រព្យ និងនិក្ខេប

[26] ធនាគារប្រាំបួនទៀតរកបានលើសពី 10 ភាគរយ ចំណែកឯធនាគារផ្សេងទៀតរកបានតិចជាងកម្រិតគោលនេះ។

ប្រទេសកម្ពុជាស្ថិតនៅក្នុងក្រុម "9" ក្រោម"ការវាយតម្លៃឧស្សាហកម្មធនាគារនិងហានិភ័យប្រទេស[27]" ចុះថ្ងៃទី 24 ខែ ធ្នូ ឆ្នាំ 2015។ ប្រព័ន្ធធនាគារទទួលមូលនិធិបរទេសកើនឡើង ហេតុនេះត្រូវប្រឈមមុខចំពោះការប្រែប្រួលកាន់តែធំនៃទីផ្សារទុនអន្តរជាតិ។ ធនាគារបរទេសចូលមកកាន់ប្រទេសកម្ពុជា មានធនាគារបរទេសតូចៗនិងមធ្យមជាច្រើនមានសមត្ថភាពតិចតួចក្នុងការកៀរគរប្រាក់សន្សំក្នុងស្រុក ហើយពឹងផ្អែកជាខ្លាំងលើការចាក់បញ្ចូលមូលនិធិពីបរទេស។ ទោះជាយ៉ាងនេះក្តីក្នុងរយៈពេលពីរឆ្នាំកន្លងមក ធនាគារទាំងនោះបានរីកលូតលាស់យ៉ាងឆាប់រហ័ស ហើយឥឡូវមានចំណែកជិត 40 ភាគរយ នៃការផ្តល់ឥណទានថ្មីសរុប។ ប្រការនេះបានជម្រុញឱ្យមានការដាក់ចេញនូវទុនបម្រុងកាតព្វកិច្ចចំនួន 12.5 ភាគរយនៃប្រាក់កម្ចីពីបរទេស ។

**ម៉្យាងវិញទៀត កម្រិតរាយការណ៍អំពីឥណទានមិនដំណើរការ នៅតែមានស្ថិរភាពក្នុងកម្រិតទាប។** កម្រិតឥណទានមិនដំណើរការ (NPL) នៅក្នុងធនាគារដែលបានរាយការណ៍ពេលបច្ចុប្បន្ននេះ ស្ថិតនៅក្រោម 3 ភាគរយ នៃឥណទានសរុប ចាប់តាំងពីត្រីមាសទីមួយនៃឆ្នាំ 2011 មក ហើយមិនស្ថិតក្នុងចំណោមកម្រិតខ្ពស់បំផុតនោះទេ បើប្រៀបធៀបជាលក្ខណៈអន្តរជាតិ[28] ។ ធនាគារជាតិនៃកម្ពុជាបានធ្វើឱ្យប្រសើរឡើងនូវការត្រួតពិនិត្យហានិភ័យឥណទាន ដោយរឹតបន្តឹងចំណាត់ថ្នាក់ឥណទានមិនដំណើរការ ។ ទោះជាយ៉ាងណាក្តី គេអាចចាត់ការបន្ថែមទៀត ដោយតម្រូវឱ្យធនាគារបង្កើតប្រព្រឹត្តកម្មប្រុងប្រយ័ត្នចំពោះឥណទានដែលបានរៀបចំឡើងវិញ និងពង្រឹងកិច្ចតម្រូវក្នុងការរាយការណ៍ និងការបង្ហាញឥណទានមិនដំណើរការ ។ តារាង S1 ខាងក្រោមបង្ហាញសូចនាករអនុវត្តន៍របស់ធនាគារ។

**តារាង S1: សូចនាករអនុវត្តន៍របស់ធនាគារនៃប្រទេសកម្ពុជា**

| សូចនាករ (%) | 1Q2013 | 2Q2013 | 3Q2013 | 4Q2013 | 1Q2014 | 2Q2014 | 3Q2014 | 4Q2014 | 3Q2015 |
|---|---|---|---|---|---|---|---|---|---|
| កំណើនឥណទានសរុប (កំណើនធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន) | 32.11 | 31.97 | 31.96 | 25.58 | 29.43 | 22.90 | 27.30 | 27.00 | 31.8 |
| អនុបាតឥណទានធៀបនឹងផសស | 40.40 | 43.08 | 47.39 | 47.74 | 50.26 | 50.42 | 53.40 | 56.71 | N/A |
| អនុបាតប្រាក់កម្ចីរបស់អតិថិជនធៀបនឹងអនុបាតប្រាក់បញ្ញើរបស់អតិថិជន | 86.46 | 90.46 | 104.05 | 97.24 | 97.75 | 90.68 | 92.96 | 95.86 | N/A |
| ឥណទានមិនដំណើរការធៀបនឹងឥណទានសរុប | 2.31 | 2.52 | 2.55 | 2.70 | 2.59 | 2.63 | 2.56 | 2.22 | N/A |

ប្រភព: ធនាគារជាតិនៃកម្ពុជា
1Q=ត្រីមាសទី1 2Q=ត្រីមាសទី2 3Q=ត្រីមាសទី3 4Q=ត្រីមាសទី4

## គ). វិស័យមីក្រូហិរញ្ញវត្ថុ

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI) បានដើរតួនាទីយ៉ាងសំខាន់ ដោយផ្តល់លទ្ធភាពទទួលបានហិរញ្ញវត្ថុដល់ប្រជាជនជនបទភាគច្រើន ប្រសិនបើមិនដូច្នេះទេពួកគេនឹងពឹងផ្អែកលើអ្នករកស៊ីចងការឯកជនដែលគ្មានច្បាប់គ្រប់គ្រងឡើយ។** វិស័យមីក្រូហិរញ្ញវត្ថុដែលទើបស្ថិតក្នុងដំណាក់កាលដំបូងមានកំណើនយ៉ាងខ្ពស់ (រូបភាព S 4) ។ នៅឆ្នាំ 2015 គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន 34 និងគ្រឹះស្ថានទទួលបញ្ញើខ្នាតតូចចំនួនប្រាំពីរ (MDI) បានបង្កើនកំណើនឥណទានរបស់ខ្លួនដល់ 46 ភាគរយ ធៀបនឹងឆ្នាំមុន និងកើនឡើងដល់កម្រិតមួយខ្ពស់ជាមួយនឹងឥណទានក្នុងចរាចរណ៍ចំនួន 2.9 ពាន់លានដុល្លារអាមេរិក ដែលផ្តល់ឲ្យអ្នកខ្ចីចំនួន 2 លាននាក់ ធៀបនឹងឥណទានក្នុងចរាចរណ៍ចំនួន 426 លានដុល្លាអាមេរិក និងអ្នកខ្ចីចំនួន 0,9 លាននាក់ នៅចុងឆ្នាំ 2010[29] ។ លទ្ធផលអនុវត្តន៍របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានលក្ខណៈគួរឱ្យកត់

---

[27] BICRAដាក់ពិន្ទុសេដ្ឋកិច្ច និងហានិភ័យវិស័យធនាគារ ហើយចាត់ថ្នាក់ពីលេខ 1 (ហានិភ័យទាប) ដល់លេខ 10 (ហានិភ័យខ្ពស់)។ ហានិភ័យសេដ្ឋកិច្ច រួមមាន ភាពធន់នៃសេដ្ឋកិច្ច និងអតុល្យភាពដែលបណ្តាលមកពីកំណើនឥណទានខ្ពស់ ចំណែកឯមួយទៀតពិនិត្យមើលក្របខ័ណ្ឌបញ្ញត្តិកម្ម និងត្រួតពិនិត្យ ឋាមភាពប្រកួតប្រជែង និងប្រភពផ្តល់មូលនិធិទូទាំងប្រព័ន្ធនៃវិស័យធនាគារ។

[28] យោងតាមសូចនាករអំពីភាពត្រឹមត្រូវផ្នែកហិរញ្ញវត្ថុរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ នៅចុងឆ្នាំ 2015 បណ្តាប្រទេសដែលមានកម្រិតឥណទានមិនដំណើរការខ្ពស់បំផុត ធៀបនឹងប្រទេសម៉ុលដូវ៉ា 16% ប៉ាគីស្ថាន 12.5% ម៉ាសេដូនី (ឆ្នាំហិរញ្ញកិច្ច) 11.2% កាហ្សាក់ស្ថាន 9.2% និងសហព័ន្ធរុស្ស៊ី 7.4%។

[29] របាយការណ៍ឆ្នាំ 2011 របស់ធនាគារជាតិនៃកម្ពុជា និងរបាយការណ៍របស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ឆ្នាំ 2015។

សម្គាល់ ដោយមានផលចំណេញពីហ៊ុនវិនិយោគ (ROE) ចំនួន 22 ភាគរយ និងបន្តមានកំណើនផ្តល់ឥណទាន យ៉ាងឆាប់រហ័ស។

**រូប S4: កំណើនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានចុះថយខណៈពេលដែលកំណើនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDIs) មាននិន្នាការកើនឡើងបណ្តើរៗ។**




ប្រភព: ធនាគារជាតិនៃកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

**រូប S5: ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកើនឡើងយ៉ាងឆាប់រហ័សក្នុងគ្រប់វិស័យសេដ្ឋកិច្ច**




ប្រភព: ធនាគារជាតិនៃកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

**រូបភាពទី S6: កំណើនឥណទានគួរឱ្យកត់សម្គាល់នៅក្នុងវិស័យសំណង់ និងគ្រួសារ**




ប្រភព: ធនាគារជាតិនៃកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

**រូបភាពទី S7: ទំហំឥណទានមធ្យមក្នុងចរាចរណ៍ តាមភូមិសាស្ត្រ** (ពាន់រៀល)




ប្រភព:អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ 2014 វិទ្យាស្ថានជាតិស្ថិតិ

**កម្រិតប្រមូលផ្តុំនៃវិស័យមីក្រូហិរញ្ញវត្ថុមានកម្រិតខ្ពស់ជាងវិស័យធនាគារ។** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ/គ្រឹះស្ថានទទួលប្រាក់បញ្ញើខ្នាតតូចនៅកម្ពុជាធំបំផុត ចំនួន 12 មានទីកប្រាក់ឥណទានសរុប 98 ភាគរយ នៃទីផ្សារមីក្រូហិរញ្ញវត្ថុ និងមានចំនួនអតិថិជនអ្នកខ្ចីប្រាក់ចំនួន 97 ភាគរយ ។ ឥណទានមីក្រូហិរញ្ញវត្ថុមានការរីកចម្រើនឆាប់រហ័សក្នុងគ្រប់វិស័យ សេដ្ឋកិច្ច (រូប S5 និង S6) ។ ទោះយ៉ាងណាក្តី កំណើនឥណទានមីក្រូហិរញ្ញវត្ថុមានលក្ខណៈមិនស្មើគ្នាឡើយ ពោលគឺមានតែតួអង្គពីរបីប៉ុណ្ណោះដែលគ្របដណ្តប់[30] ។ ទន្ទឹមនឹងនេះដែរ ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធៀបនឹងការផ្តល់ឥណទានរបស់គ្រឹះស្ថានធនាគារ បានកើនឡើងពី 16.2 ភាគរយ ក្នុងត្រីមាសទីមួយនៃឆ្នាំ 2013 ដល់ជាង 20 ភាគរយ ក្នុងឆ្នាំ 2015។ ចំណុចនេះឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រកំណើនដែលកាន់តែមានលក្ខណៈប្រកួតប្រជែងរបស់គ្រឹះស្ថានមីក្រូ

[30] យោងតាមការស្រាវជ្រាវទីផ្សាររបស់ MIX ។

ហិរញ្ញវត្ថុ ធៀបនឹងធនាគារពាណិជ្ជ និងប្រហែលជាសាធារណជនមានចំណាប់អារម្មណ៍លើផលិតផល និងប្រជាប្រិយភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាងផលិតផលរបស់ធនាគារ។ កំណើនឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានលក្ខណៈគួរឱ្យកត់សម្គាល់នៅក្នុងវិស័យសំណង់ និងវិស័យគ្រួសារ។

**ការពង្រីកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឆាប់រហ័សនេះ មានសក្តានុពលដើម្បីលើកកម្ពស់លទ្ធភាពបានទទួលហិរញ្ញវត្ថុ ជាពិសេសសម្រាប់ប្រជាជនជនបទ។** ប៉ុន្តែ ការពង្រីកនេះ រួមចំណែកមួយផ្នែកទៅនឹងនិន្នាការឆ្ពោះទៅរកការទទួលបានប្រាក់កម្ចីពីច្រើនប្រភព ដែលអ្នកខ្ចីគ្មានលទ្ធភាពសង។ ក្នុងឆ្នាំ 2014 អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាបានរកឃើញថា គ្រួសារនីមួយៗបានខ្ចីប្រាក់កាន់តែច្រើន ពិសេសគឺគ្រួសារនៅជនបទ ខណៈពេលដែលប្រាក់កម្ចីរបស់គ្រួសារនៅរាជធានីភ្នំពេញនៅមានស្ថិរភាព (រូបភាព S7) ។ ការសិក្សាថ្មីមួយដោយ Oikocredit ក្នុងខែវិច្ឆិកា ឆ្នាំ 2015 បានគូសបញ្ជាក់ពីការបង្កើនប្រាក់កម្ចីច្រើនប្រភពនៅក្នុងប្រទេសកម្ពុជា ដែលប្រការនេះបង្ហាញនិន្នាការមួយឆ្ពោះទៅរកការជំពាក់បំណុលរបស់អ្នកខ្ចី ដែលអាចគ្មាននិរន្តរភាព។ លើសពីនេះទៀត ស្ថាប័នទទួលប្រាក់បញ្ញើមួយចំនួនបានបង្ហាញពីការធ្លាក់ចុះនូវកម្រិតសាធនភាព ក្នុងរយៈពេលពីរឆ្នាំកន្លងមក ហើយស្ថិតនៅកៀកនឹងកម្រិតកំណត់ប្រុងប្រយ័ត្ន។ សភាពការណ៍នេះបានកើតឡើងក្នុងបរិបទអវត្តមាននៃគម្រោងការពារប្រាក់បញ្ញើ និងកំណើនឆាប់រហ័ស (45 ភាគរយ ក្នុងឆ្នាំ 2015) នៃមូលដ្ឋានប្រាក់បញ្ញើ ដែលបានឡើងដល់ 1,3 ពាន់លានដុល្លារអាមេរិក ពីអ្នកដាក់ប្រាក់បញ្ញើចំនួន 1.4 លាននាក់។ ភាពជំពាក់បំណុលកំពុងកើនឡើង ជាពិសេសនៅតាមតំបន់ជនបទ ហើយកង្វះព័ត៌មាននៅតែជាបញ្ហាប្រឈមនៅប្រទេសកម្ពុជា។

### ឃ). វិស័យធានារ៉ាប់រង

**វិស័យធានារ៉ាប់រងរបស់កម្ពុជាមានទំហំតូច ប៉ុន្តែមានការពង្រីកខ្លួនជាបណ្តើរៗ ដោយមាន ចំណូលបុព្វលាភសរុបចំនួន 60 លានដុល្លារអាមេរិក ក្នុងឆ្នាំ 2014។** ភាគច្រើននៃបរិមាណបុព្វលាភបានមកពីធានារ៉ាប់រងទូទៅ (លើផ្នែកទ្រព្យសម្បត្តិ)និងធានារ៉ាប់រងជីវិត។ ការធានារ៉ាប់រងសុខភាពមានតិចតួចណាស់ ដែលតាមធម្មតាធានារ៉ាប់រងនេះផ្តល់ដោយក្រុមហ៊ុនបរទេស និងផ្តល់សេវាដល់ក្រុមហ៊ុនបរទេសដែលមានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុនធានារ៉ាប់រងធំជាងគេបំផុត មានបរិមាណបុព្វលាភធានារ៉ាប់រងស្មើនឹង 45 ភាគរយនៃចំណែកទីផ្សារ មានតំណែងនាំមុខគេក្នុងការធានារ៉ាប់រងទូទៅ។

**ច្បាប់ស្តីពីការធានារ៉ាប់រងថ្មីបានអនុម័តនៅក្នុងខែកក្កដាឆ្នាំ 2014 បានតម្រូវឱ្យមានការធានារ៉ាប់រងយានយន្តចំពោះតតិយភាគី (MTPL) និងសកម្មភាពធានារ៉ាប់រងខ្នាតតូចនៅកម្ពុជា។** ចំពោះ MTPL មានយានយន្តមួយចំនួនតូចប៉ុណ្ណោះដែលស្ថិតនៅក្រោម MTPL ទោះបីជានៅកម្ពុជាមានការកើនឡើងនូវចំនួនអ្នកបើកបរក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះក្តី ដោយមានការប៉ាន់ប្រមាណថាជារៀងរាល់ថ្ងៃ មានអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ចំនួន 10 នាក់ ។ ចំពោះការធានារ៉ាប់រងខ្នាតតូច ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចនាំមុខគេមួយ ទទួលបានជោគជ័យគួរឲ្យកត់សម្គាល់នៅក្នុងគម្រោងសាកល្បងក្នុងខេត្តចំនួនពីរ ដែលបានពង្រីកការធានារ៉ាប់រងខ្នាតតូចនៅទូទាំងប្រទេស ចំពោះការស្លាប់ ការរងរបួសដោយចៃដន្យ និងការជំនួសប្រាក់បៀវត្សក្នុងពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ ចំណុចខ្លាំងនៃផលិតផលនេះស្ថិតនៅលើភាពសាមញ្ញរបស់វា ដែលអនុញ្ញាតឱ្យងាយស្រួលក្នុងការលក់ ជាមួយនឹងការព័ត៌មានជាមូលដ្ឋានផ្សព្វផ្សាយទីកាន់ទីផ្សារដែលមានប្រាក់ចំណូល។ ខណៈដែលច្បាប់ថ្មីនេះបានបើកឱកាសថ្មីនៅកម្ពុជា បញ្ហាប្រឈមទូទៅនៅក្នុងវិស័យធានារ៉ាប់រងនៅតែត្រូវដោះស្រាយ។ ឧទាហរណ៍ មានឧបករណ៍វិនិយោគរយៈពេលវែងតិចតួចសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង

ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិនិងបំណុលរបស់ពួកគេ។ លើសពីនេះទៀត ការគ្រប់គ្រងផ្អែកលើហានិភ័យ ចាំបាច់ត្រូវកែលម្អបន្ថែមទៀត។

### ង). ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ការប្រឆាំងការលាងលុយកខ្វក់ និងការរាយការណ៍

**ទីផ្សារភាគហ៊ុនដែលទើបបង្កើតថ្មីមានទំហំជួញដូរទាប**[31] ។ ការជួញដូរផ្សារហ៊ុនថ្មីមានទំហំតិចតួចស្ដួចស្ដើង ដោយមានក្រុមហ៊ុនចុះបញ្ជីត្រឹមតែបី ដែលកំហិតវិសាលភាពសម្រាប់ធ្វើពិពិធកម្មកញ្ចប់វិនិយោគ និងពិពិធកម្មហានិភ័យ ពីសំណាក់វិនិយោគិនម្នាក់ៗ។ ការបង្កើនមូលធនតាមរយៈទីផ្សារមូលធននៅមានកម្រិតតិចតួច ប្រមាណជា 0.2 ភាគរយនៃ ផសស ហើយការបង្កើតមូលធននៅទីផ្សារមានចំនួន 0.86 ភាគរយនៃ ផសស គិតត្រឹមថ្ងៃទី 1 ខែមីនា ឆ្នាំ 2016។ សន្ទស្សន៍ផ្សារមូលបត្រកម្ពុជា (CSX) បានឡើងខ្ពស់បំផុតនៅថ្ងៃទី 20 ខែមេសា ឆ្នាំ 2012 ត្រឹម 1,096.77 ដែលការជួញដូរមានទំហំស្មើនឹង 488,000 ភាគហ៊ុន ប៉ុន្តែសន្ទស្សន៍នេះបានបិទត្រឹមតែ 390.73 កាលពីថ្ងៃទី 2 ខែ មីនា ឆ្នាំ 2016 ដែលទំហំជួញដូរមានត្រឹមតែ 8,759 ហ៊ុនប៉ុណ្ណោះ។

**ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានសម្រាប់ផ្ដល់ឥណទានត្រូវបានធ្វើឲ្យប្រសើរឡើងគួរឱ្យកត់សម្គាល់ សមស្របជាមួយការពង្រីកយ៉ាងឆាប់រហ័សនៃវិស័យហិរញ្ញវត្ថុ។** ការដាក់ឲ្យប្រើប្រាស់ដោយជោគជ័យនូវការិយាល័យព័ត៌មានឥណទាននៅកម្ពុជា (CBC) ដែលធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ត្រូវតែចូលរួម គាំទ្រការកែលម្អនៅក្នុងការសម្របសម្រួល និងពង្រឹងការត្រួតពិនិត្យ។ គិតត្រឹមខែមេសាឆ្នាំ 2015 CBC បានគ្របដណ្ដប់អតិថិជនចំនួន 4.2 លាននាក់ រួមបញ្ចូលទាំងព័ត៌មានឥណទានវិជ្ជមាន និងអវិជ្ជមាន ដែលធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណត្រូវចូលរួមចែករំលែក និងដើម្បីពិនិត្យមើលក្នុងដំណើរការនៃការសម្រេចចិត្តផ្ដែកឥណទាន។ ជាលទ្ធផល ធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានរាយការណ៍អំពីភាពប្រសើរឡើងយ៉ាងច្រើនអំពីគុណភាពឥណទាន ចាប់តាំងពីការចូលរួមជាមួយ CBC ដូចជា ការកាត់បន្ថយហានិភ័យរបស់ពួកគេចំពោះអ្នកខ្ចីប្រាក់ច្រើនពីច្រើនប្រភពជាដើម។

**កម្ពុជាត្រូវបានគេដកចេញពីបញ្ជីប្រទេសដែលក្រុមការងារសកម្មភាពហិរញ្ញវត្ថុ (FATF) ត្រូវតាមដាន ក្រោមការប្រឆាំងការលាងលុយកខ្វក់ជាសាកល (AML) និងត្រូវអនុលោមតាមដំណើរការប្រយុទ្ធប្រឆាំងនឹងការផ្ដល់ហិរញ្ញប្បទានដល់ភេរវកម្ម (CFT)។** បន្ទាប់ពីមានការពិនិត្យមើលឡើងវិញអំពីអនុលោមភាពតាមស្ដង់ដា AML និង CFT ក្នុងខែកុម្ភៈឆ្នាំ 2015 FATF បានសង្កេតឃើញមានការរីកចម្រើនយ៉ាងច្រើនលើរបប AML/CFT របស់កម្ពុជា និងបានកត់សម្គាល់ថា កម្ពុជាបានបង្កើតក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ដើម្បីបំពេញតាមការប្ដេជ្ញាចិត្តរបស់ខ្លួនក្នុងផែនការសកម្មភាពរបស់ខ្លួន[32]។

**វិស័យសហគ្រាសដ៏មានថាមពលរបស់កម្ពុជាបានជំរុញឱ្យមានកំណើនក្នុងសកម្មភាពគណនេយ្យនិងសវនកម្មក្នុងរយៈពេល 10 ឆ្នាំកន្លងទៅ ទោះបីជាពីមូលដ្ឋានដ៏ទាបក្ដី។** យោងតាមក្រុមប្រឹក្សាជាតិគណនេយ្យ (NAC)[33] ចាប់តាំងពីឆ្នាំ 2010

[31] ផ្សារមូលប័ត្រកម្ពុជា (CSX) ត្រូវបានបើកឲ្យដំណើរការកាលពីថ្ងៃទី 18 ខែ មេសា ឆ្នាំ 2012។

[32] ទោះជាយ៉ាងណាក្តី រាជរដ្ឋាភិបាលកម្ពុជាបន្តធ្វើការជាមួយក្រុមអាស៊ីប៉ាស៊ីហ្វិកក្នុងកិច្ចប្រឹងប្រែងកំពុងប្រព្រឹត្តទៅ ដើម្បីដោះស្រាយបញ្ហាប្រឆាំងការលាងលុយកខ្វក់/ប្រយុទ្ធប្រឆាំងនឹងការផ្ដល់ហិរញ្ញប្បទានដល់ភេរវកម្ម ដែលបានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃសង្គហកិច្ចរបស់ខ្លួន។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជាកំពុងធ្វើស្វ័យវាយតម្លៃអំពីហានិភ័យនៃការលាងលុយកខ្វក់ និងហានិភ័យនៃការផ្ដល់ហិរញ្ញប្បទានដល់ភេរវកម្មក្រោមដំណើរការវាយតម្លៃហានិភ័យថ្នាក់ជាតិ (NRA)។

[33] ក្រុមប្រឹក្សាជាតិគណនេយ្យ (NAC) នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺជាស្ថាប័នកំណត់ស្តង់ដារសម្រាប់វិជ្ជាជីវៈ និងច្បាប់គណនីសាជីវកម្ម (2002) បានបង្កើតក្របខ័ណ្ឌគតិយុត្តសម្រាប់ស្តង់ដារគណនេយ្យ។

មករាល់អង្គភាពសាធារណៈត្រូវរាយការណ៍ស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS)[34] ចំណែកឯសហគ្រាសមិនមែនហិរញ្ញវត្ថុផ្សេងទៀត ត្រូវរាយការណ៍តាមស្តង់ដារ IFRS សម្រាប់សហគ្រាសធុនតូចនិងមធ្យម (SME) ដែលជា ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុសាមញ្ញ។ កម្មវិធីវាយតំលៃវិស័យហិរញ្ញវត្ថុឆ្នាំ 2010 (FSAP) បានគូសបញ្ជាក់ពីចំណុច ទន់ខ្សោយមួយចំនួនក្នុងក្របខ័ណ្ឌគណនេយ្យ និងសវនកម្មនៅប្រទេសកម្ពុជា។ កម្មវិធីនោះបានសង្កត់ធ្ងន់ពីសារៈសំខាន់នៃការកែលម្អគុណភាពនៃទិន្នន័យពីស្ថាប័នហិរញ្ញវត្ថុ ដើម្បីបង្កលក្ខណៈវាយតម្លៃសមស្របនូវហានិភ័យនានា និងដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រមួយសម្រាប់ការផ្លាស់ប្តូរទៅកាន់ IFRS [35]។

## ច). សារគន្លឹះ

**កាលពីពេលថ្មីៗកន្លងទៅនេះ អាជ្ញាធរបានដាក់ចេញនូវវិធានការសំខាន់ៗមួយចំនួនក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវភាពធន់នៃវិស័យហិរញ្ញវត្ថុ។** ការអនុវត្តន៍ប្រកាសថ្មី ចុះថ្ងៃទី 22 ខែមិនាឆ្នាំ 2016 ស្តីពីទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ជាសារៈសំខាន់ក្នុងការពង្រឹងបន្ថែមទៀតនូវវិស័យធនាគារ និងរួមទាំងសិស័យមីក្រូហិរញ្ញវត្ថុផងដែរ។ ការតម្រូវបែបនេះនឹងលើកទឹកចិត្តដល់ការច្របាច់ និងរួមបញ្ចូលគ្នាក្នុងវិស័យធនាគារ[36]។ ការដាក់ឲ្យអនុវត្តអំពីទុនបម្រុងកាតព្វកិច្ចចំនួន 12.5 ភាគរយ ចំពោះការខ្ចីពីបរទេស និងអនុបាតគ្របដណ្តប់សាច់ប្រាក់ងាយស្រួលក៏មុខជាទ្រទ្រង់ដល់ការពង្រឹងវិស័យធនាគារផងដែរ។ ប្រកាសថ្មីមួយផ្សេងទៀត បញ្ញត្តិអំពីទំនាក់ទំនងរបស់សាមីម្ចាស់ផ្ទះ ទាក់ទងនឹងការចែករំលែកព័ត៌មាន ព្រមទាំងជំនួយសង្គ្រោះបន្ទាន់ជាសាច់ប្រាក់ងាយស្រួល (ELA) ។

វិធានការបន្ថែមដែលអាចជួយផ្លាស់ប្តូរបន្ថែមទៀតដើម្បីកែលម្អការត្រួតពិនិត្យ និងការផ្លាស់ប្តូរព័ត៌មានក្នុងរយៈពេលខ្លី និងមធ្យម រួមមាន:

(i) **ការធ្វើវិសុទ្ធកម្មចំពោះការប្រមូលទិន្នន័យ។** គប្បីអនុវត្តប្រព្រឹត្តកម្មប្រុងប្រយ័ត្នដែលមានចរិតអភិរក្សឲ្យបានច្រើនបន្ថែមទៀតសម្រាប់ឥណទានដែលត្រូវបានរៀបចំឡើងវិញ និងរៀបចំប្រតិទិនសងសារជាថ្មី និងឥណទានមិនដំណើរការ នៅក្នុងវិស័យនីមួយៗ ដែលមានផលប៉ះពាល់ធំៗ មានផលប៉ះពាល់ទាក់ទងនឹងភាគីពាក់ព័ន្ធ ផលប៉ះពាល់ធំបំផុតៗទាំង 20 របស់ធនាគារ និងផលប៉ះពាល់ដោយសារហានិភ័យរបស់ប្រទេស។ យកល្អ ត្រូវកែលម្អឧបករណ៍វិភាគតាមរយៈការផ្តល់អនុសាសន៍បញ្ជាក់អំពីបញ្ញត្តិស្តីពីអនុបាតគ្របដណ្តប់ អនុបាតផលប៉ះពាល់ដែលមានទំហំធំ និងអនុបាតសាច់ប្រាក់ងាយស្រួល និងធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្រវិភាគកម្រិតប្រព័ន្ធ។

(ii) **ធានាថាចំណាត់ថាក់ឥណទានត្រូវបានអនុវត្តដូចៗគ្នាពីធនាគារមួយទៅធនាគារមួយ** ខណៈដែលគប្បីពិនិត្យឡើងវិញនូវវិធានដែលមានស្រាប់ ដែលអនុញ្ញាតឱ្យធ្វើចំណាត់ថ្នាក់សារជាថ្មីជាបន្ទាន់ នូវឥណទានដែលត្រូវបានរៀបចំឡើងវិញ។ ភារកិច្ចទាំងនេះអាចអនុវត្តទៅរួចក្នុងរយៈពេលខ្លី។

---

[34] ទោះជាយ៉ាងណាក្តី និយមន័យនៃសហគ្រាសសាធារណៈ មិនត្រូវបានគេយល់ពេញលេញឡើយ រីឯការអនុវត្តក៏មិនបានល្អដែរ។

[35] អាជ្ញាធរគ្រោងកំណត់ដំណាក់កាលអនុវត្ត IFRS ពីសំណាក់គ្រឹះស្ថានហិរញ្ញវត្ថុ និងកំពុងពិចារណាកែសម្រួលក្របខ័ណ្ឌបញ្ញត្តិកម្មប្រុងប្រយ័ត្ន និងវិសោធនកម្មបញ្ញត្តិកម្មប្រុងប្រយ័ត្ន និងការតព្វកិច្ចរាយការណ៍ផ្នែកហិរញ្ញវត្ថុ និងសវនកម្មផ្ទៃក្រៅ ដើម្បីឲ្យស៊ីគ្នាជាមួយ IFRS។

[36] ដោយសារក្របខ័ណ្ឌសម្រាប់ការច្របាច់បញ្ចូលគ្នាមិនត្រូវបានបង្កើតបានល្អនៅកម្ពុជា ការអនុវត្តកាតព្វកិច្ចថ្មីអំពីទុនត្រូវគ្រប់គ្រងដោយប្រយ័ត្នប្រយែងដើម្បីរក្សាទំនុកចិត្តលើប្រព័ន្ធនេះ។

(iii) **កែសម្រួលរូបមន្តសម្រាប់គណនាសាច់ប្រាក់ងាយស្រួលរបស់ធនាគារដើម្បីក្តោបវិមាត្រពេលវេលា។** គប្បីកែលម្អការវិភាគហានិភ័យសាច់ប្រាក់ងាយស្រួលដោយការពិនិត្យមើលឡើងវិញនូវសូចនាករអនុបាត ដើម្បីរាប់បញ្ចូលតែទ្រព្យសកម្មដែលងាយប្តូរជាសាច់ប្រាក់ ដោយធ្វើការជាមួយនឹងស្ថាប័នហិរញ្ញវត្ថុ ដើម្បីកែលម្អការចាត់ថ្នាក់ទ្រព្យសកម្ម។ គប្បីតាមដានហានិភ័យដែលមានសក្តានុពល ដូចជាការលេចឡើងនូវឥណទានអនិវាសជន និងប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារ។

(iv) **វិធានការប្រុងប្រយ័ត្នបន្ថែមអាចធានាស្ថិរភាពបន្ថែមទៀតដល់វិស័យនេះក្នុងរយៈពេលមធ្យម។** ដោយសារធនាគារបានបង្កើនការប្រមូលផ្តុំរបស់ពួកគេ និងបង្កើនការពឹងផ្អែកកាន់តែខ្លាំងលើការផ្តល់មូលនិធិពីបរទេសទាំងអស់នេះអាចនឹងបង្កើតបន្ថែមនូវហានិភ័យជាប្រព័ន្ធ។ វាជាករណីដែលអាចកើតមាន ពិសេសចំពោះធនាគារដែលមានចំណែកប្រាក់បញ្ញើលក់រាយ ប្រាក់បញ្ញើរបស់ក្រុមហ៊ុន និងប្រាក់បញ្ញើអន្តរធនាគារដែលមានទំហំធំ។ ជាមួយគ្នានេះផងដែរ ក៏អាចមានការផ្តល់ឥណទានពី "ធនាគារស្រមោល" ដែលមានទំហំធំ និងកាន់តែច្រើនទៅឲ្យវិស័យសំណង់និងអចលនទ្រព្យផងដែរ។ អាស្រ័យហេតុនេះ ឧបករណ៍បន្ថែមទៀតដើម្បីកាត់បន្ថយហានិភ័យឥណទានឲ្យនៅទាប ដូចជាតម្រូវឱ្យមានអនុបាតឥណទានធៀបនឹងតម្លៃទីកប្រាក់កម្ចីម៉ត់ចត់ ចំពោះការឲ្យខ្ចីដែលមានវត្ថុបញ្ចាំទៅកាន់អាជីវកម្មប្រថុយប្រថាន អាចនឹងជួយឱ្យប្រសើរឡើងនូវភាពធន់។ ភារកិច្ចទាំងនេះទំនងជាតម្រូវឱ្យមានរយៈពេលមធ្យមដើម្បីអនុវត្ត។

(v) **ការដាក់កំហិតលើការផ្តល់ឥណទានសម្រាប់ប្រើប្រាស់ ធៀបនឹងទំហំផលប័ត្រក៏អាចត្រូវបានធានាផងដែរ** ដើម្បីទប់ស្កាត់ការផ្តល់ឥណទានច្រើនហួសក្នុងទីផ្សារឥណទាន ។ ក្នុងន័យនេះ ការយកចិត្តទុកដាក់បន្ថែមទៀតក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់អតិថិជន ពិសេសចំពោះប្រជាជនជនបទ។

(vi) កែលម្អបន្ថែមទៀតចំពោះប្រព័ន្ធព័ត៌មានឥណទាន ដោយពង្រីក CBC ឲ្យគ្របដណ្តប់នីតិបុគ្គល។ ក្នុងន័យនេះ CBC កំពុងធ្វើការជាមួយក្រសួងពាណិជ្ជកម្ម ដែលរក្សាការចុះបញ្ជីសហគ្រាសចំនួន 500.000 ដើម្បីភ្ជាប់ព័ត៌មានស្តីពីការចុះបញ្ជីសហគ្រាសទៅកាន់សារតារឥណទានរបស់ពួកគេ។

(vii) កែលម្អគុណភាពទិន្នន័យ និងលើកទឹកចិត្តបន្ថែមទៀត ឲ្យមានគោលនយោបាយបង្ហាញព័ត៌មាន។ ទំនុកចិត្តទីផ្សារអាចត្រូវបានធ្វើឱ្យប្រសើរបន្ថែមទៀតតាមរយៈការបង្ហាញជាសាធារណៈនូវលទ្ធផលអនុវត្តន៍ផ្នែកហិរញ្ញវត្ថុនៃវិស័យហិរញ្ញវត្ថុ។ ការងារនេះអាចធ្វើបាន ដោយកែលម្អកិច្ចប្រតិបត្តិផ្នែកគណនេយ្យ និងសវនកម្ម នៅក្នុងវិស័យហិរញ្ញវត្ថុ។

(viii) **ធ្វើលំហាត់ប្រដូច (Simulation exercise) ទៅនឹងពេលមានវិបត្តិធ្ងន់ធ្ងរ ។** លំហាត់ប្រាណនេះមានគោលបំណងបង្កើតឱកាសឱ្យអាជ្ញាធរប្រើប្រាស់ការចាត់ចែងគ្រប់គ្រងវិបត្តិដែលមានស្រាប់របស់ពួកគេ លើផ្នែកឧបករណ៍ ច្បាប់ក្របខ័ណ្ឌប្រតិបត្តិការ អន្តរទីភ្នាក់ងារ ការចែករំលែកព័ត៌មានក្នុងទីភ្នាក់ងារ និងការចាត់ចែងអំពីការសម្របសម្រួល និងប្រាស្រ័យទាក់ទងជាមួយភាគីពាក់ព័ន្ធសំខាន់ៗ និងជាមួយសាធារណជន។

អាជ្ញាធរកំពុងខំប្រឹងប្រែងលុបចន្លោះប្រហោងក្នុងការត្រៀមលក្ខណៈចំពោះវិបត្តិ និងក្របខ័ណ្ឌគ្រប់គ្រងវិបត្តិរបស់ប្រទេស ដែលមានលក្ខណៈធ្ងន់ធ្ងរឡើងដោយសាររចនាសម្ព័ន្ធដុល្លានៃប្រព័ន្ធសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[37]។ ការងារដើម្បីបង្កើនក្របខណ្ឌគ្រប់គ្រងវិបត្តិបំពេញការពិនិត្យមើលឡើងវិញរបស់អ្នកជំនាញចំពោះច្បាប់នៃធនាគារជាតិនៃកម្ពុជា និងច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងស្ថាប័នហិរញ្ញវត្ថុ និងសេចក្តីព្រាងវិសោធនកម្មដែលចែងអំពីលទ្ធភាពរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តដំណោះស្រាយធនាគារចំពោះធនាគារដែលមានលក្ខណៈជាប្រព័ន្ធ និងធនាគារដែលគ្មានលក្ខណៈជាប្រព័ន្ធ។ ជាមួយគ្នានេះក៏មានការផ្តល់អនុសាសន៍ឲ្យបង្កើតគណៈកម្មាធិមួយសម្រាប់រក្សាស្ថិរភាពហិរញ្ញវត្ថុ[38] ដែលបានផ្តល់អំណាចដើម្បីត្រួតពិនិត្យស្ថិរភាពហិរញ្ញវត្ថុ និងដោះស្រាយជាមួយនឹងវិបត្តិដែលមានលក្ខណៈជាប្រព័ន្ធផងដែរ[39]។ អាស្រ័យដោយដំណើរការវិសោធនកម្មច្បាប់ត្រូវការរយៈពេលវែង កិច្ចការនេះត្រូវតែជាសកម្មភាពសម្រាប់រយៈកាលមធ្យម ។

**សម្រាប់រយៈពេលមធ្យមទៅរយៈពេលវែង អាជ្ញាធរមានគម្រោងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ 2011 (FSDS) ដោយពិចារណាអំពីកម្មវិធីវាយតម្លៃវិស័យហិរញ្ញវត្ថុ ឆ្នាំ 2010 (FSAP)។** អាជ្ញាធរអាចពិចារណាប្រើ FSDS ដែលបានធ្វើបច្ចុប្បន្នភាព/កែលម្អ ធ្វើជាមូលដ្ឋានសម្រាប់ការសម្រេចចិត្តទិសដៅនាពេលអនាគតជាមួយនឹងគោលបំណងកសាងវិស័យហិរញ្ញវត្ថុដែលមានដំណើរការ គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច នាពេលអនាគតសម្រាប់រយៈពេល 5-10ឆ្នាំខាងមុខ។ ការណ៍នេះនឹងណែនាំទិសដៅគោលនយោបាយដើម្បីបង្កើនការអនុវត្តន៍បន្តស្របជាមួយស្តង់ដារអន្តរជាតិ: ក្របខ័ណ្ឌបទប្បញ្ញត្តិ និងគ្រប់គ្រងរួមទាំងរបបសាធនភាពវិធីគ្រប់គ្រងវិបត្តិគុណភាពទិន្នន័យគោលនយោបាយបង្ហាញលទ្ធផលអនុវត្តន៍អភិបាលកិច្ចសាជីវកម្ម វិធីគ្រប់គ្រងហានិភ័យកិច្ចប្រតិបត្តិគណនេយ្យ និងសវនកម្ម និងការការពារអតិថិជន។ លើសពីនេះទៀត FSDS ដែលបានកែសំរួលអាចដោះស្រាយ ភាពមិនស៊ីសង្វាក់អំពីដុល្លាូបនីយកម្មកម្រិតខ្ពស់ ភាពខុសគ្នាអំពីទ្រព្យសកម្មនិងបំណុលទាំងលើភាពមិនស៊ីគ្នានៃរូបិយវត្ថុ និងភាពមិនស៊ីគ្នារវាងបំណុលរយៈពេលវែង និងទ្រព្យសកម្មរយៈពេលខ្លីឧបករណ៍ហិរញ្ញវត្ថុមានចំនួនតិច និងច្រើនចំណុចផ្សេងទៀត។

37 ក្នុងខែកុម្ភៈឆ្នាំ 2014 ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងគណៈកម្មាធិការមូលប័ត្រកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណស្តីពីការបង្កើតក្រុមការងារកម្រិតគោលនយោបាយ ដែលបាននាំទៅដល់ការបង្កើតក្រុមស្នូលផ្នែកបច្ចេកទេសផងដែរ។

38 ការចុះហត្ថលេខាលើអនុស្សរណៈលើកដំបូងក្នុងចំណោមស្ថាប័នត្រួតពិនិត្យបានលើកកម្ពស់សហប្រតិបត្តិការនៅកម្រិតគោលនយោបាយ និងកម្រិតបច្ចេកទេស។ ទោះជាយ៉ាងណាក្តី សហប្រតិបត្តិការចំណោមនិយ័តករហិរញ្ញវត្ថុអាចត្រូវបានកែលម្អបន្ថែមទៀត។ ចាំបាច់ត្រូវមានអាណត្តិច្បាប់ ច្បាស់លាស់សម្រាប់ការត្រួតពិនិត្យប្រុងប្រយ័ត្នលើផ្នែកម៉ាក្រូ និងពិចារណាអនុម័តសំណើច្បាប់កែសម្រួលដែលនឹងផ្តល់អំណាចឲ្យធនាគារជាតិនៃកម្ពុជាមានលទ្ធភាពអនុវត្តដំណោះស្រាយធនាគារ។

39 គណៈកម្មាធិការនេះអាចមានសហប្រធានមកពីធនាគារជាតិនៃកម្ពុជា និងមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

# កម្ពុជា: សូចនាករសំខាន់ៗ

| | 2012 | 2013 | 2014 | 2015e | 2016p | 2017f | 2018f |
|---|---|---|---|---|---|---|---|
| **លទ្ធផល តម្រូវការក្នុងស្រុក និងថ្លៃ** | | | | | | | |
| ផសស ពិត (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 7.3 | 7.4 | 7.1 | 7.0 | 6.9 | 6.8 | 6.8 |
| តម្រូវការក្នុងស្រុក(%ប្រែប្រួលធៀបនឹងឆ្នាំមុន) | 9.9 | 11.3 | 10.1 | 12.6 | 10.7 | 11.1 | 12.5 |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (%ប្រែប្រួលចុងគ្រាធៀបនឹងឆ្នាំមុន | 2.5 | 4.6 | 1.2 | 2.8 | 3.0 | 3.5 | 3.8 |
| **វិស័យសាធារណៈ (%នៃផសស)** | | | | | | | |
| ចំណូលរដ្ឋាភិបាល (% នៃផសស) | 15.3 | 15.1 | 18.0 | 17.5 | 17.5 | 17.5 | 17.0 |
| ចំណាយរដ្ឋាភិបាល(% នៃផសស) | 21.0 | 21.5 | 21.5 | 20.5 | 22.3 | 22.0 | 22.5 |
| តុល្យការរដ្ឋាភិបាលមិនគិតជំនួយឥតសំណង a/ | -5.9 | -6.6 | -3.8 | -3.0 | -4.8 | -4.5 | -5.5 |
| តុល្យការរដ្ឋាភិបាលគិតទាំងជំនួយឥតសំណង a/ | -3.3 | -2.7 | -1.4 | -0.8 | -2.8 | -2.9 | -4.1 |
| | | | | | | | |
| ជញ្ជីងពាណិជ្ជកម្ម (លានដុល្លារអាមេរិក) | -2,455.7 | -2,598.4 | -3,213.0 | -3,217.1 | -3,301.7 | -3,552.6 | -3,693.3 |
| នាំចេញទំនិញ (លានដុល្លារអាមេរិក) | 5,632.8 | 6,890.2 | 7,408.4 | 8,519.6 | 9,550.0 | 10,520.0 | 11,830.0 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 7.9 | 22.3 | 7.5 | 15.0 | 12.1 | 10.2 | 12.5 |
| ការនាំចេញសំខាន់ៗ (% ប្រែប្រួលធៀបនឹងឆ្នាំមុន)1/ | 7.0 | 17.6 | 11.7 | 14.5 | 14.0 | 14.0 | 14.0 |
| ការនាំចូលទំនិញ (លានដុល្លារអាមេរិក) | 8,088.5 | 9,488.6 | 10,621.4 | 11,736.7 | 12,851.7 | 14,072.6 | 15,523.3 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 20.6 | 17.3 | 11.9 | 10.5 | 9.5 | 9.5 | 10.3 |
| សមតុល្យគណនីចរន្ត (លានដុល្លារអាមេរិក) 2/ | -1,376.0 | -1,378.1 | -1,969.9 | -1,984.9 | -1,884.3 | -1,999.2 | -2,332.7 |
| (% នៃផសស) | -9.7 | -9.0 | -11.9 | -10.8 | -9.3 | -9.3 | -10.0 |
| វិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាមេរិក) | 1,697.9 | 1,826.1 | 1,676.9 | 1,802.7 | 1,652.9 | 1,747.7 | 1,780.0 |
| បំណុលបរទេស (លានដុល្លារអាមេរិក) | 4,547.4 | 5,110.7 | 5,555.4 | 6,020.0 | 6,469.3 | 6,894.5 | 7,343.0 |
| (% នៃផសស) | 32.1 | 33.3 | 33.4 | 32.8 | 32.0 | 32.2 | 31.6 |
| អនុបាតសេវាបំណុល (% ការនាំចេញទំនិញនិងសេវា) | 1.0 | 1.1 | 1.3 | 1.4 | 1.5 | 1.6 | 1.7 |
| ទុនបំរុងជារូបិយបណ្ណបរទេសដុល(លានដុល្លារអាមេរិក) | 3,463.0 | 3,642.5 | 4,657.9 | 5,672.1 | 6,398.7 | 6,847.7 | 7,258.9 |
| (ចំនួនខែនៃការនាំចូលទំនិញនិងសេវា) | 3.7 | 3.5 | 4.1 | 4.5 | 4.7 | 4.6 | 4.1 |
| **ទីផ្សារហិរញ្ញវត្ថុ** | | | | | | | |
| ឥណទានក្នុងស្រុក (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 29.6 | 28.6 | 28.4 | 27.0 | 25.8 | 25.0 | 24.5 |
| អត្រាការប្រាក់រយៈពេលខ្លី (%ក្នុងមួយឆ្នាំ) | 11.6 | 11.3 | 11.5 | 11.7 | 12.0 | 11.8 | 11.5 |
| អត្រាប្តូរប្រាក់(រៀល/ដុល្លារអាមេរិក ចុងគ្រា)) | 3,995.0 | 3,995.0 | 4,075.0 | 4,054.0 | 4,058.0 | 4,062.0 | 4,067.0 |
| អត្រាប្តូរប្រាក់ខ្វែងពិត(ឆ្នាំ2010=100) | 105.4 | 109.9 | 113.1 | 119.8 | 121.8 | 124.3 | 127.4 |
| (%ប្រែប្រួលធៀបនឹងឆ្នាំមុន) | 0.5 | 4.3 | 2.0 | 1.3 | 1.7 | 2.0 | 2.5 |
| | | | | | | | |
| ចំណាំ: ផសស ជាក់ស្តែង (លានដុល្លាអាមេរិក) | 14,188 | 15,362 | 16,623 | 18,363 | 20,190.7 | 21,412.1 | 23,243.7 |

ប្រភព:ប្រភពទិន្នន័យជាតិ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

e = ប៉ាន់ស្មាន p = ចំណោល និង f = ព្យាករណ៍.

a/រួមមានការកែតម្រូវចំណាយ

1/សម្លៀកបំពាក់និងស្បែកជើង.

2/មិនគិតបង្វែរផ្លូវការ

WORLD BANK GROUP

ធនាគារពិភពលោក
ការិយាល័យប្រចាំប្រទេសកម្ពុជា
លេខ 113 មហាវិថីនរោត្តម
ភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ: (855-23) 861 300
ទូរសារ: (855-23) 861 301/302
គេហទំព័រ: www.worldbank.org/cambodia